# សង្កេតការណ៍ ១៧

## ដំណើរកាត់ទោសមេដឹកនាំខ្មែរក្រហម

ខែវិច្ឆិកា ឆ្នាំ២០១២



## មាតិកា

សវនាការស្តីពីការវាយតម្លៃ
សមត្ថភាព បញ្ញា ស្មារតី.... ១
សវនាការស្តីពីលក្ខខណ្ឌចំពោះ
ការដោះលែង អៀង ធីរិទ្ធ ២០
សវនាការស្តីពីបញ្ហាសុខភាព
ជនជាប់ចោទ អៀង សារី ៣២
ការអនុវត្តសិទ្ធិនៅស្ទៀម... ៤៣

ក្រុមសង្កេតការណ៍ :
ឆាយ ឈុនលី, លឹម ជ័យច័ន្ទ,
ឌី សុជាតា, និង ចាន ប្រាថ្នា

អៀង សារី និង អៀង ធីរិទ្ធ លើកដៃសំពះបួងសួងនៅក្នុង
ពិធីមួយដែលប្រារព្ធធ្វើនៅក្រុងប៉ៃលិន
(ប្រភពរូបថត : ទីភ្នាក់ងារសារព័ត៌មានបារាំង)



ជនជាប់ចោទ អៀង ធីរិទ្ធ នៅក្នុងបន្ទប់សវនាការ (ប្រភពរូបថត ៖ អ.វ.ត.ក)

# សវនាការស្តីពីការវាយតម្លៃសមត្ថភាពបញ្ញា ស្មារតី និងសេចក្តីសម្រេច ទាក់ទងនឹងជនជាប់ចោទ អៀង ធីរិទ្ធ

## ថ្ងៃទី៣០-៣១ ខែសីហា ឆ្នាំ២០១២

ឆាយ ឈុនលី និង ឌី សុជាតា

## សេចក្តីផ្តើម

នៅថ្ងៃទី៣០-៣១ ខែសីហា ឆ្នាំ២០១២ អង្គជំនុំជម្រះសាលាដំបូងនៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា បានបើកសវនាការសួរដេញដោលអ្នកជំនាញចំនួនបីរូប និងសាក្សីមួយរូបទាក់ទងនឹងរបាយការណ៍ស្តីពីស្ថានភាពសុខភាពរបស់ជនជាប់ចោទ អៀង ធីរិទ្ធ។ អ្នកជំនាញទាំងបីរូបរួមមាន ១) លោកវេជ្ជបណ្ឌិត ចន ខាំប៊ែល ជនជាតិណូវែលហ្សេឡង់ ជាសាស្ត្រាចារ្យជំនាញខាងជំងឺមនុស្សចាស់នៅសាកលវិទ្យាល័យអូតាវ៉ា ប្រទេសណូវែលហ្សេឡង់, ២) លោក ស៊ីណា ហ្វាសែល ជនជាតិអង់គ្លេស ជាសាស្ត្រាចារ្យជាន់ខ្ពស់ផ្នែកវិកលវិទ្យា និងជាអ្នកពិគ្រោះយោបល់ផ្នែកវិកលវិទ្យានៅសាកលវិទ្យាល័យអក់ហ្វដ ប្រទេសអង់គ្លេស, និង៣) លោកវេជ្ជបណ្ឌិត ហួត លីណា ជនជាតិខ្មែរ ជាវេជ្ជបណ្ឌិតឯកទេសវិកលវិទ្យាដែលបានសិក្សាថ្នាក់អនុបណ្ឌិតនៅប្រទេសអូស្ត្រាលី បច្ចុប្បន្នជាសាស្ត្រាចារ្យជំនួយផ្នែកវិកលវិទ្យានៅសាកលវិទ្យាល័យវិទ្យាសាស្ត្រសុខាភិបាល ក្នុងទីក្រុងភ្នំពេញ។ អ្នកជំនាញទាំងបីរូបនេះធ្លាប់ បានមកផ្តល់សក្ខីកម្មនៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូងម្តងរួចមកហើយកាលពីឆ្នាំ២០១១។ ចំណែកឯលោកស្រីវេជ្ជបណ្ឌិត ចក់ ធីតា ជាវេជ្ជ-បណ្ឌិតផ្នែកវិកលវិទ្យានៅមន្ទីរពេទ្យខ្មែរ-សូវៀត និងជាសាស្ត្រាចារ្យ ផ្នែកវិកលវិទ្យានៅសាកលវិទ្យាល័យវិទ្យាសាស្ត្រសុខាភិបាល ត្រូវបានអង្គជំនុំជម្រះកោះអញ្ជើញមក ផ្តល់សក្ខីកម្មនៅក្នុងសវនាការស្តីពីការវាយតម្លៃសមត្ថភាពបញ្ញាស្មារតីជនជាប់ចោទ អៀង ធីរិទ្ធ ក្នុង នាមជាសាក្សីជំនាញកាលពីថ្ងៃទី៣០ ខែកក្កដា ឆ្នាំ២០១២។

នៅក្នុងសវនាការសួរដេញដោលរយៈពេលទាំងពីរថ្ងៃ គឺបានផ្តោតសំខាន់លើការស្តាប់សក្ខីកម្ម របស់សាក្សីជំនាញ ចក់ ធីតា, ការស្តាប់សក្ខីកម្មអំពីការវិវត្តនៃស្ថានភាពសុខភាពជនជាប់ចោទ អៀង ធីរិទ្ធ, ការសន្និដ្ឋានរួមគ្នារបស់អ្នកជំនាញទាំងបីរូប និងការស្តាប់សំណើសុំរបស់ភាគីនីមួយៗទាក់ទងនឹងសម្បទាក្នុងការចូលរួមដំណើរការជំនុំជម្រះរបស់ជនជាប់ចោទ។ អង្គជំនុំជម្រះបានផ្តល់ឱកាសជូនភាគី ដើម្បីសួរសំណួរអ្នកជំនាញវិកលវិទ្យាពាក់ព័ន្ធនឹងសេចក្តីសន្និដ្ឋាននៃរបាយការណ៍អំពីការវាយតម្លៃឡើងវិញនូវបញ្ហាសម្បទារបស់ជនជាប់ចោទ អៀង ធីរិទ្ធ ក្នុងការចូលរួមសវនាការ។



អង្គជំនុំជម្រះសាលាដំបូងនៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា (ប្រភពរូបថត : អ.វ.ត.ក)

## ១) ប្រវត្តិនីតិវិធី

កាលពីថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០១១ ក្រុមមេធាវីការពារក្តីជនជាប់ចោទ អៀង ធីរិទ្ធ បានដាក់បណ្តឹងមួយជូនអង្គជំនុំជម្រះសាលាដំបូងតវ៉ាអំពីបញ្ហាសមត្ថភាពខាងកាយសម្បទា និងបញ្ហាស្មារតីរបស់កូនក្តីខ្លួន ក្នុងការទទួលបានការជំនុំជម្រះប្រកបដោយយុត្តិធម៌ ។ ជាការឆ្លើយតប នៅថ្ងៃទី៤ ខែមេសា ឆ្នាំ២០១១ អង្គជំនុំជម្រះសាលាដំបូងបានតែងតាំងសាស្ត្រាចារ្យ ចន ខាំបែល ដែលជាអ្នកជំនាញព្យាបាលរោគមនុស្សចាស់ឲ្យធ្វើការវាយតម្លៃអំពីស្ថានភាពសម្បទារបស់ជនជាប់ចោទ អៀង ធីរិទ្ធ ។ បន្ទាប់មកសាស្ត្រាចារ្យ ចន ខាំបែល ត្រូវបានអង្គជំនុំជម្រះស្នើសុំឲ្យរៀបចំរបាយការណ៍ជាលាយលក្ខណ៍អក្សរពាក់ព័ន្ធនឹងស្ថានភាពសុខភាព និងបញ្ហាស្មារតីរបស់ជនជាប់ចោទ អៀង ធីរិទ្ធ ដើម្បីឲ្យអង្គជំនុំជម្រះមានលទ្ធភាព ក្នុងការសម្រេចលើសមត្ថភាពខាងសម្បទា និងបញ្ហាស្មារតីរបស់ជនជាប់ចោទក្នុងការចូលរួមសវនាការ ។

ក្នុងរបាយការណ៍ ចុះថ្ងៃទី២៣ ខែមិថុនា ឆ្នាំ២០១១ សាស្ត្រាចារ្យ ខាំបែល បានសន្និដ្ឋានថា ជនជាប់ចោទ អៀង ធីរិទ្ធ មានបញ្ហា ស្មារតី និងប្រព័ន្ធសរសៃប្រសាទ ដែលរារាំងលទ្ធភាពរបស់ជនជាប់ចោទក្នុងការចូលរួមឲ្យបានពេញលេញនៅក្នុងការជំនុំជម្រះក្តី និងរារាំងដល់ការអនុវត្តសិទ្ធិក្នុងការទទួលបានការជំនុំជម្រះប្រកបដោយយុត្តិធម៌របស់ជនជាប់ចោទ ។ បន្ទាប់ពីបានស្តាប់របាយការណ៍របស់ សាស្ត្រាចារ្យ ខាំបែល អង្គជំនុំជម្រះសាលាដំបូងបានតែងតាំងអ្នកជំនាញវិកលវិទ្យាចំនួនបួនរូបដើម្បីធ្វើការវាយតម្លៃបន្ថែមពាក់ព័ន្ធនឹងបញ្ហាស្មារតី និងប្រព័ន្ធសរសៃប្រសាទរបស់ជនជាប់ចោទ អៀង ធីរិទ្ធ ។ អ្នកជំនាញទាំងបួនរូបនោះ មានសមាសភាពដូចតទៅ ៖

១) លោកវេជ្ជបណ្ឌិត ហួត លីនណា ជាវេជ្ជបណ្ឌិតឯកទេសខាងវិកលវិទ្យា ២) លោកវេជ្ជ បណ្ឌិត កើត ឈុនលី ជាវេជ្ជបណ្ឌិតឯកទេសខាងវិកលវិទ្យា ៣) លោកវេជ្ជបណ្ឌិត ស៊ីណា ហ្វាសែល ជាវេជ្ជបណ្ឌិតឯកទេសវិកលវិទ្យា និង៤) វេជ្ជបណ្ឌិត ខាលវិន ប៊ុនស៊ិនឡេង ជាវេជ្ជបណ្ឌិតពិគ្រោះផ្នែកវិកលវិទ្យា ។

អ្នកជំនាញវិកលវិទ្យាទាំងបួនរូប បានពិនិត្យវាយតម្លៃសមត្ថភាពខាងសម្បទា និងបញ្ហាស្មារតីរបស់ជនជាប់ចោទ អៀង ធីរិទ្ធ នៅខែសីហា ឆ្នាំ២០១១ និងបានដាក់របាយការណ៍របស់ខ្លួនជូនអង្គជំនុំជម្រះ និងភាគីពាក់ព័ន្ធនៅថ្ងៃទី១១ ខែកញ្ញា ឆ្នាំ២០១១ ។ នៅថ្ងៃទី១៩ និងថ្ងៃទី២០ ខែតុលា ឆ្នាំ២០១១ អង្គជំនុំជម្រះសាលាដំបូង បានបើកសវនាការជាសាធារណៈដើម្បីអនុញ្ញាតឲ្យភាគីអាចសួរដេញដោលលើរបាយការណ៍របស់អ្នកជំនាញទាំងបួនរូប ។



រាប់ពីឆ្វេង វេជ្ជបណ្ឌិត ហួត លីនណា វេជ្ជបណ្ឌិត ស៊ីណា ហ្វាសែល និង សាស្ត្រាចារ្យ ចន ខាំបែល ដែលមានជំនាញឯកទេសផ្នែកវិកលវិទ្យា និងព្យាបាលរោគមនុស្សចាស់ (ប្រភព ៖ មជ្ឈមណ្ឌលឯកសារកម្ពុជា)

បន្ទាប់ពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់អ្នកជំនាញដែលអង្គជំនុំជម្រះបានតែងតាំងមក នៅថ្ងៃទី១៧ ខែវិច្ឆិកា ឆ្នាំ២០១១ អង្គជំនុំជម្រះសាលាដំបូងបានសម្រេចថា ៖

ជនជាប់ចោទ អៀង ធីរិទ្ធ បានរងគ្រោះពីស្ថានភាពធ្លាក់ដុនដាបផ្នែកសតិបញ្ញាស្មារតីជាបន្តបន្ទាប់ និងអាចជាជំងឺបាត់បង់ការចងចាំដែលធ្វើឲ្យជនជាប់ចោទពុំមានសមត្ថភាពសម្បទាគ្រប់គ្រាន់ ដើម្បីចូលរួមនៅក្នុងសវនាការជំនុំជម្រះក្តីមកលើខ្លួន ។ ដោយផ្អែកលើការរកឃើញខាងលើអង្គជំនុំជម្រះសាលាដំបូងបានបង្គាប់ឲ្យដោះលែងជនជាប់ចោទ អៀង ធីរិទ្ធ ជាបន្ទាន់ និងបានផ្អាកកិច្ចដំណើរការនីតិវិធីប្រឆាំងនឹងជនជាប់ចោទ ដោយអះអាងថាពុំមានលទ្ធភាពសមស្របណាមួយដើម្បីបន្តកិច្ចដំណើរការនីតិវិធីប្រឆាំងនឹងជនជាប់ចោទទៀតឡើយ ។

នៅថ្ងៃទី១៣ ខែធ្នូ ឆ្នាំ២០១១ បន្ទាប់ពីមានបណ្តឹងសាទុក្ខរបស់សហព្រះរាជអាជ្ញា អង្គជំនុំជម្រះតុលាការកំពូលនៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាបានសម្រេចថា អង្គជំនុំជម្រះសាលាដំបូង ត្រូវប្រើឲ្យអស់វិធានការដែលមាន ដែលអាចជួយឲ្យជនជាប់ចោទ អៀង ធីរិទ្ធ មានសមត្ថភាពគ្រប់គ្រាន់ឡើងវិញ ដើម្បីចូលរួមសវនាការនិងបានបញ្ជូនកិច្ចការនេះត្រឡប់ទៅអង្គជំនុំជម្រះសាលាដំបូងវិញ ។

ក្រោយពីទទួលបានការណែនាំរបស់អង្គជំនុំជម្រះតុលាការកំពូល អង្គជំនុំជម្រះសាលាដំបូងបានចាត់តាំងអ្នកជំនាញវេជ្ជសាស្ត្រដើម្បីពិនិត្យ និងព្យាបាល និងរកវិធីសាស្ត្រធ្វើឲ្យមុខងារបញ្ញាស្មារតីរបស់ជនជាប់ចោទ អៀង ធីរិទ្ធ មានភាពល្អប្រសើរ ។ អ្នកជំនាញបានលើកឡើងនូវវិធានការចំនួនពីរ ដែលអាចធ្វើឲ្យបញ្ញាស្មារតីរបស់ អៀង ធីរិទ្ធ មានភាពល្អប្រសើរឡើងវិញ ៖ ១) ការកាត់បន្ថយម្តងបន្តិចៗ នូវឱសថក្លូណាហ្សេប៉ាម (Clonazepam) ឬឡិចសូមៀល (Lexomil) និង២) ការប្រើប្រាស់បិទព្យាបាលរីវ៉ាស្ទីជមីន (Rivastigmine) ។

ការព្យាបាលតាមរយៈការលើកកម្ពស់សតិបញ្ញាស្មារតីក៏ត្រូវបានណែនាំដោយអ្នកជំនាញ ដើម្បីបំពេញបន្ថែមដល់របបឱសថ បើទោះបីជាមានការកត់សម្គាល់ថា ពុំមានភស្តុតាងសំខាន់ណាមួយបង្ហាញថា ការព្យាបាលដោយចលនាតែមួយមុខអាចកែប្រែការធ្លាក់ចុះផ្នែកសតិបញ្ញាស្មារតីបានក៏ដោយ ។ អ្នកជំនាញ វេជ្ជសាស្ត្របានគូសបញ្ជាក់ថា ការព្យាបាលដោយឱសថរីវ៉ាស្ទីជមីន ចំនួន ១៨សប្តាហ៍ និងការព្យាបាលដើម្បីលើកកម្ពស់សតិបញ្ញាស្មារតីរយៈពេលបីខែ នឹងគ្រប់គ្រាន់សម្រាប់ផលប្រយោជន៍ផ្នែកសតិបញ្ញាស្មារតី ។

គ្រូពេទ្យជនជាប់ចោទ អៀង ធីរិទ្ធ បានរាយការណ៍ថាឱសថឡិចសូមៀល ត្រូវបានកាត់បន្ថយក្នុងកម្រិតមួយភាគបួន ជារៀងរាល់សប្តាហ៍ចាប់ពីថ្ងៃទី២៣ ខែមិនា ឆ្នាំ២០១២ និងបានបញ្ចប់ទាំងស្រុងនៅថ្ងៃទី១៣ ខែមេសា ឆ្នាំ២០១២ ។

ការព្យាបាលដោយឱសថ រីវ៉ាស្ទីជមីន បានចាប់ផ្តើមនៅថ្ងៃទី២៧ ខែមិនា ឆ្នាំ២០១២ ហើយជនជាប់ចោទ អៀង ធីរិទ្ធ បានទទួលការព្យាបាលដោយឱសថនេះគ្រប់ចំនួន១៨សប្តាហ៍ នៅចុងខែកក្កដា ឆ្នាំ២០១២ ។

កម្មវិធីលើកកម្ពស់សតិបញ្ញាស្មារតីសម្រាប់ជនជាប់ចោទ អៀង ធីរិទ្ធ បានចាប់ផ្តើមនៅថ្ងៃទី២៨ ខែឧសភា ឆ្នាំ២០១២ និងដំណើរការគ្រប់ចំនួនបីខែគិតត្រឹមថ្ងៃទី២៨ ខែសីហា ឆ្នាំ២០១២ ។ ពាក់ព័ន្ធនឹងការឃុំខ្លួនជនជាប់ចោទ អៀង ធីរិទ្ធ អង្គជំនុំជម្រះត្រូវបានតម្រូវឲ្យសម្រេចនៅដំណាក់កាលដំបូងអំពីផលវិបាកនៃស្ថានភាពសុខភាពរបស់ជនជាប់ចោទ ដែលអាចជះឥទ្ធិពលលើកិច្ចដំណើរការនីតិវិធី និងការឃុំខ្លួនជាបណ្តោះអាសន្ន ។ ហេតុដូច្នេះ អង្គជំនុំជម្រះសាលាដំបូងត្រូវវាយតម្លៃ សារជាថ្មីភ្លាមៗអំពីសមត្ថភាពសម្បទារបស់ជនជាប់ចោទ អៀង ធីរិទ្ធ ក្នុងការចូលរួមសវនាការ បន្ទាប់ពីផុតរយៈពេលនៃការអនុវត្តវិធានការផ្សេងៗតាមសេចក្តីសម្រេចរបស់អង្គជំនុំជម្រះតុលាការកំពូល ។

អង្គជំនុំជម្រះបានសម្រេចកោះអញ្ជើញអ្នកជំនាញ គឺលោកសាស្ត្រាចារ្យ ចន ខាំប៉ែល, លោក វេជ្ជបណ្ឌិត ហួត លីនណា និងលោកវេជ្ជបណ្ឌិត ស៊ីណា ហ្វាសែល ដែលទទួលបន្ទុកការពិនិត្យព្យាបាលជនជាប់ចោទ អៀង ធីរិទ្ធ ដើម្បីមកឆ្លើយបំភ្លឺចំពោះមុខអង្គជំនុំជម្រះអំពីរបាយការណ៍របស់ខ្លួន ដែលបានប្រគល់ជូនអង្គជំនុំជម្រះ ។

នៅថ្ងៃទី២៩ ខែសីហា ឆ្នាំ២០១២ អ្នកជំនាញវិកលវិទ្យាបានដាក់របាយការណ៍ជូនអង្គជំនុំជម្រះ ស្តីពីស្ថានភាពសុខភាព

របស់ជនជាប់ចោទ អៀង ធីរិទ្ធ ។ អង្គជំនុំជម្រះបានស្នើសុំឲ្យអ្នកជំនាញវិកលវិទ្យាទាំងបីរូប ផ្តល់អនុសាសន៍ពាក់ព័ន្ធនឹងស្ថានភាពសុខភាពរបស់ជនជាប់ចោទ អៀង ធីរិទ្ធ ជូនអង្គជំនុំជម្រះ ដើម្បីអាចឲ្យអង្គជំនុំជម្រះមានលទ្ធភាពក្នុងការសម្រេចថា តើស្ថានភាពកាយសម្បទា និងបញ្ហាស្មារតីរបស់ជនជាប់ចោទមានភាពល្អប្រសើរឡើងដែរឬយ៉ាងណា បន្ទាប់ពីអនុវត្តនូវវិធានការវេជ្ជសាស្ត្រនានាដែលស្នើឡើងដោយអង្គជំនុំជម្រះតុលាការកំពូល ។

**២) ការវាយតម្លៃសម្បទារបស់ជនជាប់ចោទ អៀង ធីរិទ្ធ ដោយវេជ្ជបណ្ឌិត ចក់ ធីតា**

**២.ក) ការសួរដេញដោលដោយអង្គជំនុំជម្រះ**

**២.ក.១) ប្រវត្តិសាវតាររបស់វេជ្ជបណ្ឌិត ចក់ ធីតា**

មុនពេលចាប់ផ្តើមដំណើរការនីតិវិធី ប្រធានអង្គជំនុំជម្រះ ចៅក្រម និល ណុន បានសាកសួរសំណួរមួយចំនួនទាក់ទងនឹងប្រវត្តិសាវតាររបស់វេជ្ជបណ្ឌិត ចក់ ធីតា ដែលជាសាក្សីជំនាញ ។



ប្រធានអង្គជំនុំជម្រះ ចៅក្រម និល ណុន
(ប្រភព ៖ មជ្ឈមណ្ឌលឯកសារកម្ពុជា)

ឆ្លើយតបនឹងសំណួររបស់អង្គជំនុំជម្រះ វេជ្ជបណ្ឌិត ចក់ ធីតា បានបញ្ជាក់ថា លោកស្រីកើតនៅថ្ងៃទី២៣ ខែវិច្ឆិកា ឆ្នាំ១៩៦១ អាស័យដ្ឋានបច្ចុប្បន្ននៅសង្កាត់ទួលទំពូង១ ខណ្ឌចំការមន រាជធានីភ្នំពេញ ។ លោកស្រីមានតួនាទីជាអនុប្រធានមន្ទីរពេទ្យមិត្តភាពខ្មែរ-សូវៀត ទទួលបន្ទុកផ្នែកសុខភាពផ្លូវចិត្ត និងជាអនុប្រធានដេប៉ាតឺម៉ង់នៅសាកលវិទ្យាល័យវិទ្យាសាស្ត្រសុខាភិបាល ផ្នែកវិកលវិទ្យា ។ លោកស្រីបានបន្តរៀបរាប់ពីប្រវត្តិសិក្សារបស់ខ្លួនជូនអង្គជំនុំជម្រះដោយសង្ខេបថា លោកស្រីធ្លាប់បានសិក្សាផ្នែកវិជ្ជាពេទ្យទូទៅនៅឆ្នាំ១៩៨២ និងបញ្ចប់ជាស្ថាពរនៅឆ្នាំ១៩៨៨ ។ បន្ទាប់មកលោកស្រីបានបម្រើការងារនៅក្រសួងសុខាភិបាល ដែលមានតួនាទីជាប្រធានមជ្ឈមណ្ឌលសុខភាពផ្សារដើមថ្កូវ ។ នៅខែធ្នូ ឆ្នាំ១៩៩៧ លោកស្រីបានចូលរួមក្នុងការសិក្សាឯកទេសវិកលវិទ្យា និងបានបញ្ចប់ជាស្ថាពរនៅឆ្នាំ២០០១ ហើយបន្តការងារជាអនុប្រធាននៃកម្មវិធីជាតិសុខភាពផ្លូវចិត្តនៃក្រសួងសុខាភិបាល ។ បន្ទាប់មកលោកស្រីបានបន្តចូលរួមបណ្តុះបណ្តាលនិស្សិតឯកទេសវិកលវិទ្យា នៅសាកលវិទ្យាល័យវិទ្យាសាស្ត្រសុខាភិបាលតាំងពីឆ្នាំ២០០១ ។ ចាប់ពីឆ្នាំ២០០៦ រហូតដល់ឆ្នាំ២០០៩ លោកស្រីបានបន្តការសិក្សាផ្នែកវិកលវិទ្យា ដោយទទួលសញ្ញាបត្រពីសកលវិទ្យាល័យមួយរបស់សហរដ្ឋអាមេរិក ។ បន្ទាប់មក លោកស្រីបានបន្តបម្រើការងារ



វេជ្ជបណ្ឌិត ចក់ ធីតា (ប្រភព ៖ មជ្ឈមណ្ឌលឯកសារកម្ពុជា)

នៅមន្ទីរពេទ្យមិត្តភាពខ្មែរ-សូវៀត រហូតមកដល់សព្វថ្ងៃ ។

**២.ក.២) របាយការណ៍លទ្ធផលនៃស្ថានភាពសុខភាព បញ្ហាស្មារតីជនជាប់ចោទ អៀង ធីរិទ្ធ**

បន្ទាប់ពីបញ្ចប់ការសាកសួរទាក់ទងនឹងប្រវត្តិសាវតារ លោកប្រធានអង្គជំនុំជម្រះបានប្រគល់វេទិកាបន្តជូនលោកស្រីចៅក្រម ស៊ីលវៀ ខាតវ៉្រាយត៍ ដើម្បីសាកសួរវេជ្ជបណ្ឌិត ចក់ ធីតា

ទាក់ទងនឹងរបាយការណ៍របស់លោកស្រីដែលបានរកឃើញផ្សេងពីរបាយការណ៍របស់អ្នកជំនាញទាំងបីរូប ។ ឆ្លើយតបនឹងសំណួររបស់លោកស្រីចៅក្រមអន្តរជាតិ វេជ្ជបណ្ឌិត ចក់ ធីតា បានជម្រាបជូនអង្គជំនុំជម្រះថា របាយការណ៍របស់លោកស្រីដែល


ចៅក្រម ស៊ីលវៀ ខាតព្រ៊ាយត៍
(ប្រភព ៖ មជ្ឈមណ្ឌលឯកសារកម្ពុជា)

ធ្វើការវាយតម្លៃលើសុខភាពរបស់ អៀង ធីរិទ្ធ គឺមានភាពខុសគ្នាពីការវាយតម្លៃរបស់អ្នកជំនាញទាំងបីរូប ។ យោងតាមរបាយការណ៍នៅថ្ងៃទី៩ ខែធ្នូឆ្នាំ២០១១ លោកស្រីមិនបានរកឃើញថា អៀង ធីរិទ្ធ ទទួលរងការថមថយនូវបញ្ញាស្មារតី ឬផលប៉ះពាល់នៃការវង្វេងស្មារតីទេ ។ ការសន្និដ្ឋានដូច្នេះ ដោយសារលោកស្រីផ្អែកលើមូលដ្ឋាននៃរោគសញ្ញាទាក់ទងនឹងការវង្វេងស្មារតី ដោយបែកចេញជាពីរផ្នែក ទីមួយគឺរោគសញ្ញាវិកលចរិក និងទីពីរគឺវង្វេងដោយសារការចងចាំ ។ នៅក្នុងការវាយតម្លៃលោកស្រីមិនបានរកឃើញថា អៀង ធីរិទ្ធ មានរោគសញ្ញាវិកលចរិកទេ ប៉ុន្តែការភ្លេចស្មារតីទាក់ទងនឹងការចងចាំ គឺកើតមានបន្តិចបន្តួច ។ មុននឹងឆ្លើយតបសំណួរទាក់ទងនឹងឧបករណ៍សម្រាប់ធ្វើតេស្តលើស្ថានភាពសុខភាពរបស់ អៀង ធីរិទ្ធ លោកស្រីវេជ្ជបណ្ឌិតបានបញ្ជាក់ជូនអង្គជំនុំជម្រះថា ក្នុងនាមលោកស្រីជាវេជ្ជបណ្ឌិតឯកទេសផ្នែកវិកលវិទ្យា លោកស្រីយល់ថាការបង្កើតទំនាក់ទំនងជាមួយអ្នកជំងឺគឺជាកិច្ចការសំខាន់ ។ នៅក្នុងរបាយការណ៍លើកដំបូងដែលលោកស្រីជួបជាមួយ អៀង ធីរិទ្ធ លោកស្រីវេជ្ជបណ្ឌិតបានព្យាយាមបង្កើតទំនាក់ទំនងដោយធ្វើការសំណេះសំណាលអំពីការរស់នៅរបស់ជនជាប់ចោទរហូតមានទំនាក់ទំនងល្អជាមួយគ្នា ដោយមានការរៀបរាប់អំពីបញ្ហាមួយចំនួន ដូចមាននៅក្នុងរបាយការណ៍របស់លោកស្រី ។ វេជ្ជបណ្ឌិត ធីតា បានបញ្ជាក់បន្ថែមថា ជាការចាំបាច់ដែលត្រូវបង្កើតឲ្យមានទំនាក់ទំនងល្អជាមួយជនជាប់ចោទ ដើម្បីឲ្យជនជាប់ចោទមានការធូរស្រាលក្នុងអារម្មណ៍ ដែលអនុញ្ញាតឲ្យខ្លួនអាចធ្វើតេស្តពិសោធន៍លើបញ្ហាជំងឺវង្វេងស្មារតីបាន ។ លោកស្រីបានបន្តថា ការព្យាបាលផ្នែកផ្លូវចិត្ត គឺទាមទារឲ្យមានការទុកចិត្តគ្នា និងទំនាក់ទំនងល្អ ទើបអាចទទួលបានព័ត៌មានដែលអ្នកជំងឺចង់ផ្តល់ឲ្យ ។ ប្រសិនបើគ្មានការបង្កើតទំនាក់ទំនងជាមួយអ្នកជំងឺ ហើយឈានដល់ការវាយតម្លៃតែម្តង គឺនឹងមិនទទួលបានព័ត៌មានអ្វីឡើយ ។ មុនឈានដល់ការវាយតម្លៃ លោកស្រី បានសាកសួរព័ត៌មានពីបុគ្គលិកដែលបម្រើការនៅទីនោះ និងក្រុមគ្រូពេទ្យដែលព្យាបាល អៀង ធីរិទ្ធ ជារៀងរាល់ថ្ងៃ ។ នៅក្នុងជំនួបដំបូងដែលវេជ្ជបណ្ឌិត ធីតា បានជួបជាមួយជនជាប់ចោទ អៀង ធីរិទ្ធ លោកស្រីមិនបានប្រើប្រាស់ឧបករណ៍ធ្វើតេស្តភ្លាមៗទេ ដោយសារគោលដៅទីមួយនៅពេលនោះ គឺត្រូវបង្កើតទំនាក់ទំនងដើម្បីស្គាល់គ្នា និងធ្វើការស្វែងយល់អំពីប្រវត្តិរបស់អ្នកជំងឺជាមុនសិន ។ ដោយយោងលើព័ត៌មានដែលលោកស្រីវេជ្ជបណ្ឌិតទទួលបានពីការធ្វើតេស្តនេះ លោកស្រីបានធ្វើការសន្និដ្ឋានបណ្តោះអាសន្នថា អៀង ធីរិទ្ធ មិនមានរោគសញ្ញាពាក់ព័ន្ធនឹងជំងឺវិកលចរិកទេ ។

បន្ទាប់មកលោកស្រីចៅក្រម ខាតព្រ៊ាយត៍ បានធ្វើការសង្ខេបនូវរបាយការណ៍លើកទីមួយរបស់វេជ្ជបណ្ឌិតឡើងវិញថា បើយោងតាមការលើកឡើងរបស់វេជ្ជបណ្ឌិត អៀង ធីរិទ្ធ អាចឆ្លើយសំណួរបានត្រឹមត្រូវ, អារម្មណ៍មានសភាពធម្មតា, មិនមានការស្រមើស្រមៃ ឬវង្វេងវង្វាន់, មានការនិយាយស្តីត្រឹមត្រូវ អាចយល់បានសមស្រប, មិនបានបង្ហាញឲ្យឃើញពីការភ្លេចភ្លាំង, មិនមានចេតនាធ្វើអត្តឃាត ឬបង្កគ្រោះថ្នាក់ដល់ខ្លួនឯង, អាចស្គាល់អ្នកនៅជិតដូចជា សន្តិសុខភេទស្រី ឬក៏បុគ្គលិកនានា, ស្គាល់ទីកន្លែង ពេលវេលា និងមានការចងចាំល្អ ប៉ុន្តែការផ្តោតអារម្មណ៍ និងការយកចិត្តទុកដាក់របស់ជនជាប់ចោទដូចជាមិនសូវល្អ ។

បន្ទាប់មកចៅក្រម ខាតវ្រ៉ាយត៍ បានបន្តសួរអំពីសេចក្តីសន្និដ្ឋាននៃរបាយការណ៍លើកទីពីរនៅខែតុលា ឆ្នាំ២០១១ ដល់ខែមេសា ឆ្នាំ២០១២ ដែលវេជ្ជបណ្ឌិត ធីតា បានអះអាងថា ជនជាប់ចោទ អៀង ធីរិទ្ធ មិនមានបញ្ហាខាងសតិបញ្ញា និងមិនបានភ្លេចភ្លាំង ឬច្របូកច្របល់នោះឡើយ ប៉ុន្តែពេលខ្លះមានការភ្លេចភ្លាំងខ្លះដែរ ។ ឆ្លើយតបនឹងការលើកឡើងរបស់លោកស្រីចៅក្រមវេជ្ជបណ្ឌិត ធីតា បានបញ្ជាក់ថា ជំនាញសង្គម ជំនាញ



ជនជាប់ចោទ អៀង ធីរិទ្ធ ក្នុងបន្ទប់សវនាការ (ប្រភពរូបថត : អ.វ.ត.ក)

ប្រាស្រ័យទាក់ទងរបស់ជនជាប់ចោទ អៀង ធីរិទ្ធ គឺនៅមានសភាពសមស្រប ។ តាមរយៈការសួរនាំចំពោះអ្នកមើលថែទាំជនជាប់ចោទ អៀង ធីរិទ្ធ ជាប្រចាំវេជ្ជបណ្ឌិត បានបញ្ជាក់ថា អៀង ធីរិទ្ធ មានការរួសរាយរាក់ទាក់ និងស្លូតបូត ប៉ុន្តែនិយាយខ្លាំងៗដាក់បុគ្គលិក និងបិទទ្វារព្រួសសំឡេងខ្លាំងៗទៀតផង ។ ទាក់ទងនឹងអាកប្បកិរិយារបស់ អៀង ធីរិទ្ធ ដែលបាននិយាយដាក់បុគ្គលិកខ្លាំងៗ និងយកឈើច្រត់វាយទ្វារនោះ វេជ្ជបណ្ឌិតចក់ ធីតា បានជម្រាបជូនអង្គជំនុំជម្រះថា ចាប់ពីពេលដែលលោកស្រីចាប់ផ្តើមព្យាបាលជនជាប់ចោទ លោកស្រីមិនធ្លាប់ឃើញមានឥរិយាបថវាយទ្វារទេ ។ ប៉ុន្តែឥរិយាបថនេះកើតមានឡើងក្រោយពេលដែលជនជាប់ចោទ អៀង ធីរិទ្ធ បានដឹងខ្លួនថាត្រូវចេញពីមន្ទីរឃុំឃាំង ។

វេជ្ជបណ្ឌិតបានបញ្ជាក់ថា "ជួនកាលយើងធ្វើតេស្តពីសំណៅដើមផ្ទាល់ ដើម្បីធ្វើតេស្តអ្នកជំងឺ ជួនកាលមិនអាចទទួលបានលទ្ធផលនោះទេ ។ ឧទាហរណ៍ថា សួរគាត់ពីខេត្ត ឬការរស់នៅរបស់កូនគាត់នៅខេត្តប៉ៃលិន ។ ប្រសិនបើយើងសួរគាត់តែខេត្តណាទេ ដោយយើងមិនបានបញ្ជាក់ ជួនកាលគាត់អាចមិនយល់ ហើយឆ្លើយមិនចំនឹងសំណួរដែលយើងចង់បាន" ។ លោកស្រីបានលើកឡើងពីបទពិសោធមួយថា នៅពេលដែលក្រុមលោកសាស្ត្រាចារ្យ ខាំប៊ែល ដែលគាត់បានធ្វើតេស្តកាលពី៦ខែមុន នៅពេលនោះលោកស្រីបានចូលរួមដែរ ។ ពេលធ្វើតេស្តសាស្ត្រាចារ្យ ខាំប៊ែល បានហុចប៊ិចឲ្យ អៀង ធីរិទ្ធ ហើយសួរថា ចេះប្រើទេ? ឬក៏ស្គាល់ទេ? នៅពេលនោះ អៀង ធីរិទ្ធ បានប្រកែកថា មិនស្គាល់ទេ ។ ចំពោះសំណួរដទៃទៀតទាក់ទងនឹងការងារពេលនោះគឺ អៀង ធីរិទ្ធ មិនឆ្លើយនឹងសំណួរទេ ។ រយៈពេល៥នាទីក្រោយមកដោយសារតែវេជ្ជបណ្ឌិតអង្គុយជាប់ជាមួយ អៀង ធីរិទ្ធ លោកស្រីក៏បានកាន់ប៊ិចដដែល ហើយជូនទៅជនជាប់ចោទរួចសួរថា "ពីមុនខ្ញុំធ្លាប់ឃើញអ៊ីសរសេរភាសាបារាំង អានភាសាបារាំងបានល្អ តែខ្ញុំអត់ដឹងថាតើអ៊ីចេះភាសាអង់គ្លេសឬអត់?" ពេលនោះគាត់ទាញប៊ិចពីខ្ញុំហើយសរសេរថា "I go to school (អាយ ហ្គូ ធូ ស្គូល)" ។ លោកស្រីបានបន្តទៀតថា បន្ទាប់មកសាស្ត្រាចារ្យ ខាំប៊ែល បានបង្ហាញឲ្យជនជាប់ចោទគូសរូបដែលមាននៅក្នុងមីនីមេនថលស្តេត(MMSE)ដដែល ។ ពេលនោះជនជាប់ចោទ អៀង ធីរិទ្ធ បានបដិសេធថា ខ្លួនមិនចេះគូសរូបនោះទេ ។ ក្រោយមកបន្តិចលោកស្រីវេជ្ជបណ្ឌិតបានសំណេះសំណាលជាមួយជនជាប់ចោទ ហើយលោកស្រីបានលើកប៊ិច

ប្រគល់ឲ្យជនជាប់ចោទ ដោយនិយាយថា "អ៊ំសាកគូសមើល តើគូសបានទេ?" ។ អៀង ធីរិទ្ធ បានឆ្លើយតបវិញថា ខ្លួនមិនមានបន្ទាត់ ដូច្នេះគូសមិនត្រង់ទេ ។ ពេលនោះលោកស្រី វេជ្ជបណ្ឌិត ធីតា ឆ្លើយតបនឹងជនជាប់ចោទភ្លាមៗថា "គូសមិនត្រង់ក៏បានដែរ ឲ្យតែអ៊ំគូសបាន" ។ ពេលនោះជនជាប់ចោទ អៀង ធីរិទ្ធ យកប៊ិចទៅ ហើយអាចគូសបាន ។

លោកស្រីចៅក្រម ស៊ីលវៀ ខាតវ៉្រាយត៍ បានបន្តសំណួរដោយលើកឡើងពីរបាយការណ៍ពិនិត្យសុខភាពជនជាប់ចោទចុះថ្ងៃទី១៤ ខែសីហា ឆ្នាំ២០១២ ដែលមានការវាយតម្លៃស្ទើរតែដូចគ្នានឹងរបាយការណ៍ដែលធ្វើឡើងនៅខែកក្កដា ដែលបញ្ជាក់ថាជនជាប់ចោទ អៀង ធីរិទ្ធ ស្ថិតនៅក្នុងស្ថានភាពស្រាលផ្នែករាងកាយ មិនមែនជាសញ្ញាបញ្ជាក់ថា មានជំងឺវិកលចរិតទេ ប៉ុន្តែជនជាប់ចោទអាចមានការភ្លេចភ្លាំងបន្តិចបន្តួចដែលបញ្ហារបស់មនុស្សចាស់ទូទៅ និងអាចជាជំងឺវង្វេងវង្វាន់ដំណាក់កាលដំបូង (Pre-Demantia) តែមិនមានសភាពធ្ងន់ធ្ងរទេ ។ បន្ទាប់មក លោកស្រីចៅក្រមបានចោទសួរវេជ្ជបណ្ឌិត ធីតា ថា "តើលោកស្រីចាត់ទុកសភាពផ្លូវចិត្តរបស់គាត់ហ្នឹង គឺដូចគ្នាបន្ទាប់ពីការធ្វើតេស្តរបស់លោកស្រីនៅខែ កក្កដា, តើត្រូវទេ?" វេជ្ជបណ្ឌិត ធីតា បានឆ្លើយថា គឺត្រឹមត្រូវ ។ លោកស្រីធ្វើការវាយតម្លៃលើកទីពីរដោយផ្អែកលើការវាយតម្លៃពីលើកទី១ដែលបានធ្វើខ្លះ ហើយពេលខ្លះទៀត គឺលោកស្រីបានប្រើសំណួរដដែលដើម្បីចង់ដឹងថាតើជនជាប់ចោទមានការចងចាំឬទេ ។ វេជ្ជបណ្ឌិត ធីតា បានបញ្ជាក់ថា របាយការណ៍ដែលលោកស្រីបានធ្វើនៅអំឡុងពេលព្យាបាលជនជាប់ចោទ អៀង ធីរិទ្ធ មានចំនួន១១លើក និងមានការពិនិត្យព្យាបាលញឹកញាប់ជាងនេះ ។ ឧទាហរណ៍ នៅពេលបុគ្គលិកយាមនៅក្នុងមន្ទីរឃុំ ឃាំងបានរាយការណ៍ថា អៀង ធីរិទ្ធ មិនស្រួលគេង មួម៉ៅ ស្រែកឡូឡា ពេលនោះក្រុមគ្រូពេទ្យព្យាបាលផ្លូវកាយ និងផ្លូវចិត្ត បានរួមគ្នាពិនិត្យភ្លាមៗ ។ លោកស្រីវេជ្ជបណ្ឌិតបានបន្តថា ជាទូទៅលោកស្រីបានធ្វើការស្វែងយល់ពីស្ថានភាពសុខភាពរបស់ជនជាប់ចោទតាមរយៈគិលានុបដ្ឋាកដែលយាមនៅទីនោះនិងតាមរយៈគ្រូពេទ្យយាមប្រចាំការរាល់ថ្ងៃដើម្បីទទួលបានព័ត៌មានបន្ថែម លោកស្រីមិនបានធ្វើការពិនិត្យជារៀងរាល់ថ្ងៃទេ ។ ទាក់ទងនឹងការស្រែកឡូឡារបស់ជនជាប់ចោទ អៀង ធីរិទ្ធ លោកស្រីវេជ្ជបណ្ឌិត បានជម្រាបជូនអង្គជំនុំជម្រះថា ចាប់ពីខែកុម្ភៈ ឆ្នាំ២០១១ រហូតដល់បច្ចុប្បន្ន ដែលខ្លួនបានធ្វើការពិនិត្យលោកស្រីមិនធ្លាប់បានជួបប្រទះសភាពស្រែកឡូឡានោះទេ ។ លើសពីនេះទៀត លោកស្រីអាចមានទំនាក់ទំនងល្អ និងចូលទៅជួបជនជាប់ចោទបាន ។ លោកស្រីចាំបានថា ប្រហែលជាពីរដងដែលខ្លួនបានទៅពិនិត្យចំពេលដែលជនជាប់ចោទកំពុងងូតទឹក ហើយលោកស្រីបាននៅរង់ចាំរយៈពេលប្រហែលកន្លះ ម៉ោងទៅ១ម៉ោង បន្ទាប់មកលោកស្រីបានចូលទៅជួបជាមួយ អៀង ធីរិទ្ធ ដោយមិនមានការស្រែកឡូឡា ឬក៏បញ្ហាពាក្យសម្តីគ្រោះគ្រោះបោកឡើយ ។ ជាទូទៅរាល់ជំនួបនីមួយៗជាមួយ អៀង ធីរិទ្ធ លោកស្រីវេជ្ជបណ្ឌិតបានចំណាយពេលពី១ម៉ោង ទៅ២ម៉ោងកន្លះ ។ ចំពោះការធ្វើតេស្តភាគច្រើន លោកស្រីបានធ្វើតេស្តដោយមិនផ្ទាល់ ដែលភាសាអង់គ្លេសហៅថា "អ៊ីនដាយរិច តេស្ត" ដោយសារតែលោកស្រី គិតថាប្រសិនបើយកតេស្តដើមមកធ្វើប្រាកដជាមិនទទួលបានលទ្ធផលទេ ដោយសារតែមិនមានការសហការពីជនជាប់ចោទ ។

## ២.ក.៣) វិធីសាស្ត្រប្រើប្រាស់ក្នុងការវាយតម្លៃអំពីស្ថានភាពបញ្ញា ស្មារតី អៀង ធីរិទ្ធ

ឆ្លើយតបនឹងសំណួររបស់ចៅក្រមទាក់ទងនឹងប្រភេទតេស្ត អឹម.អឹម.អេស.អ៊ី (M.M.S.E=Mini Mental State Examination) វេជ្ជបណ្ឌិត ចក់ ធីតា បានជម្រាបជូនអង្គជំនុំជម្រះថា ខ្លួនធ្លាប់អនុវត្តន៍តេស្តនេះចំពោះអ្នកជំងឺដែលខ្លួនយល់ថា មានបញ្ហាប៉ះពាល់ ។ ប៉ុន្តែការអនុវត្តតេស្តចំពោះប្រជាជនខ្មែរ ដែលមានការយល់ដឹងទាបគឺនាំឲ្យមានការលំបាក ប្រសិនបើប្រើតេស្តជាភាសាអង់គ្លេសដូចមានសរសេរនៅក្នុងឯកសារ ។ ដូច្នេះលោកស្រីបានធ្វើតេស្ត អឹម.អឹម.អេស.អ៊ី ដោយការបកប្រែខ្លះ ប៉ុន្តែមិនធ្វើចំពោះអ្នកជំងឺទាំងអស់ទេ ព្រោះអ្នកជំងឺខ្លះមានការយល់ដឹងខ្ពស់ទើបតម្រូវឲ្យលោកស្រីធ្វើការបត់បែនយ៉ាងណាដើម្បីឲ្យទទួលបានលទ្ធផលប្រហាក់ប្រហែលគ្នា ។

លោកស្រីចៅក្រម ខាតវ៉្រាយត៍ បានបន្តសំណួរទៀតថា តើលោកស្រីវេជ្ជបណ្ឌិតបានធ្វើការពិចារណាអំពីជនជាប់ចោទ

អៀង ធីរិទ្ធ ដែលជាប្រភេទអ្នកជំងឺមានចំណេះដឹងខ្ពស់ដែរឬទេ? លោកស្រី វេជ្ជបណ្ឌិតបានឆ្លើយតបថា លោកស្រីក៏បានគិតអំពីបញ្ហានេះដែរ ប៉ុន្តែការដែលធ្វើតេស្តលើអ្នកដែលមានចំណេះដឹងច្បាស់លាស់ ជននោះអាចនឹងយល់ ហើយខ្លួននឹងមិនទទួលបាននូវព័ត៌មានពេញលេញទេ ពីព្រោះក្នុងករណីនេះខុសពីករណីដែលអ្នកជំងឺមិនទាក់ទងនឹងតុលាការ ។ វេជ្ជបណ្ឌិត ធីតា បានបន្តលើកឡើងថា អៀង ធីរិទ្ធគឺជាជនសង្ស័យមួយរូបដូច្នេះសភាពបែបនេះអាចនឹងជះឥទ្ធិពលដល់ការអនុវត្តតេស្តរបស់លោកស្រី ។ លោកស្រីយល់ឃើញថា ប្រសិនបើ អៀង ធីរិទ្ធ យល់ដឹងថាតេស្តនេះ គឺជាការធ្វើឡើងដើម្បីចង់ដឹងអំពីការចងចាំរបស់ខ្លួន ជនជាប់ចោទ អៀង ធីរិទ្ធ អាចនឹងមិនសហការជាមួយរហូតចប់សព្វគ្រប់នោះឡើយ ។ លោកស្រីបានបន្ថែមថា ជាទូទៅជំងឺខ្វះត្រូវការទាមទារឲ្យមានការពន្យល់ ប៉ុន្តែ ជំងឺខ្វះគឺត្រូវអនុវត្តតែម្តង ។ ចំពោះករណីនេះ លោកស្រីមិនបានពន្យល់ អៀង ធីរិទ្ធ ជាមុននោះទេ គឺចាប់ផ្តើមដោយការចូលរួមសំណេះសំណាលជាមួយជនជាប់ចោទ និងបញ្ចូលការសួរនាំនៅក្នុងនោះ ។

### ២.ក.៤) គុណវុឌ្ឍិសាក្សីក្នុងការពិនិត្យ និងវាយតម្លៃសមត្ថភាពបញ្ញា ស្មារតី អៀង ធីរិទ្ធ

លោកស្រីចៅក្រមបានបន្តសំណួរសំខាន់ៗមួយចំនួនទៀតដើម្បីបញ្ជាក់ពីគុណវុឌ្ឍិ និងបទពិសោធ របស់វេជ្ជបណ្ឌិត ចក់ ធីតា ដោយផ្តោតលើប្រវត្តិនៃការសិក្សា និងបទពិសោធការងារ ដើម្បីដឹងថាតើលោកស្រីវេជ្ជបណ្ឌិតមានគុណវុឌ្ឍិគ្រប់គ្រាន់ដើម្បីធ្វើការវាយតម្លៃអំពីសមត្ថភាពបញ្ញាស្មារតីរបស់ជនជាប់ចោទ អៀង ធីរិទ្ធ ដែរឬយ៉ាងណា ។ ឆ្លើយតបនឹងសំណួរនេះ វេជ្ជបណ្ឌិត ចក់ ធីតា បានរៀបរាប់ឡើងវិញអំពីប្រវត្តិនៃការសិក្សា និងបទពិសោធការងាររបស់លោកស្រីចាប់តាំងពីឆ្នាំ១៩៨២ រហូតដល់ពេលបច្ចុប្បន្ន ។ លោកស្រីបានបញ្ជាក់ជូនអង្គជំនុំជម្រះឡើងវិញថា លោកស្រីមិនបានទៅសិក្សាផ្នែកវិកលវិទ្យា នៅសហរដ្ឋអាមេរិកទេ ប៉ុន្តែកម្មវិធីដែលលោកស្រីបានទទួលការបណ្តុះបណ្តាលរយៈពេលបីឆ្នាំនោះ គឺធ្វើឡើងនៅទីក្រុងភ្នំពេញ ដោយគ្រូមកពីប្រទេសអូស្ត្រាលី និងសហរដ្ឋអាមេរិក ប៉ុន្តែសញ្ញាបត្រដែលលោកស្រីទទួលបាន គឺចេញមកពីរដ្ឋមីនីសូតា សហរដ្ឋអាមេរិក ។

ទាក់ទងនឹងការព្យាបាលជំងឺវង្វេងវង្វាន់ (Demantia) ឬជំងឺភ្លេចភ្លាំង (Alzheimer) វេជ្ជបណ្ឌិត ធីតា បានបញ្ជាក់ថា ក្រៅពីការព្យាបាលចំពោះជនជាប់ចោទ អៀង ធីរិទ្ធ លោកស្រីបានព្យាបាលអ្នកជំងឺផ្សេងទៀតស្ទើររៀងរាល់ថ្ងៃ នៅមន្ទីរពេទ្យមិត្តភាពខ្មែរ-សូវៀត ដោយក្នុងមួយសប្តាហ៍ ជាមធ្យមមានចំនួនពី៤ទៅ៥នាក់ ។ ចំណែកការសិក្សាស្រាវជ្រាវ លោកស្រីក៏បានអានឯកសារថ្មីៗជាបន្តបន្ទាប់ ដោយសារតែលោកស្រីទទួលបន្ទុកផ្នែកបណ្តុះបណ្តាលនិស្សិតឯកទេសវិកលវិទ្យា ដូច្នេះការសិក្សាលើសៀវភៅ និងការអានឯកសារផ្សេងៗដែលពាក់ព័ន្ធ គឺលោកស្រីបានស្រាវជ្រាវជារៀងរាល់ថ្ងៃ ។ ចំពោះគោលការណ៍ណែនាំអំពីរោគវិនិច្ឆ័យជំងឺហៅថា អាយ.ស៊ី.ឌី.១០ (ICD10) ដែលជាស្តង់ដាររបស់អង្គការសុខភាពពិភពលោកសម្រាប់ធ្វើការណែនាំអំពីការធ្វើរោគវិនិច្ឆ័យ លោកស្រីបានបណ្តុះបណ្តាលនិស្សិតដោយផ្អែកលើឯកសារទាំងនោះ ។ បន្ទាប់ពីបញ្ចប់ការសាកសួរដេញដោល អង្គជំនុំជម្រះបានប្រគល់វេទិកាសួរដេញដោលជូនក្រុមមេធាវីការពារក្តី អៀង ធីរិទ្ធ ដើម្បីសាកសួរបន្តអំពីការវាយតម្លៃ ស្ថានភាពសុខភាព និងសមត្ថភាពបញ្ញា ស្មារតីកូនក្តីរបស់ខ្លួន ។

### ២.ខ) ការសួរដេញដោលដោយមេធាវីការពារក្តី អៀង ធីរិទ្ធ

### ២.ខ.១) មេធាវីជាតិ

មេធាវីជាតិការពារក្តីជនជាប់ចោទ អៀង ធីរិទ្ធ គឺលោក ផាត់ ពៅសៀង បានចោទសួរវេជ្ជបណ្ឌិត ចក់ ធីតា ពាក់ព័ន្ធនឹងរបាយការណ៍របស់លោកស្រីអំពីស្ថានភាពសុខភាព និងកាយសម្បទា បញ្ញា ស្មារតីកូនក្តីរបស់ខ្លួន ។ លោកមេធាវីបានចាប់ផ្តើមសំណួរដំបូងដោយផ្តោតសំខាន់លើចំណុចបី ដែលលោកស្រីវេជ្ជបណ្ឌិតបានយោងក្នុងការវាយតម្លៃលើស្ថានភាពសុខភាពរបស់កូនក្តីរបស់លោក ។ ទី១) គឺកត្តាទំនាក់ទំនងល្អ ទី២) ភាពជាស្ត្រីដូចគ្នា និងទី៣) ការនិយាយភាសាដូចគ្នាជាហេតុនាំឲ្យទទួលបាននូវលទ្ធផលល្អ ។ មេធាវី ផាត់ ពៅសៀង បានអះអាងថា លោកមានភាពមន្ទិលសង្ស័យលើរបាយការណ៍របស់លោកស្រីវេជ្ជបណ្ឌិតពាក់ព័ន្ធនឹងវិធីសាស្ត្រក្នុងការវាយតម្លៃចំពោះស្ថានភាពសម្បទា

បញ្ញា ស្មារតីកូនក្តីរបស់ខ្លួន និងបានចោទសួរថា តើការទទួលបានព័ត៌មានដើម្បីធ្វើការវាយតម្លៃនោះមានភាពគ្រប់គ្រាន់ដែរឬយ៉ាងណា ទើបធ្វើឲ្យរបាយការណ៍របស់លោកស្រីវេជ្ជបណ្ឌិតមានភាពផ្ទុយគ្នាពីអ្នកជំនាញទាំងបីរូប ។ ឆ្លើយតបនឹងសំណួរនេះ វេជ្ជបណ្ឌិត ធីតា បានបកស្រាយជូនអង្គជំនុំជម្រះទាក់ទងនឹងទំនាក់ទំនងល្អ ដែលខ្លួនមានជាមួយជនជាប់ចោទ អៀង ធីរិទ្ធ ថានៅពេលដែលលោកស្រីចូលពិនិត្យជនជាប់ចោទ លោកស្រីតែងតែជម្រាបអំពីគោលបំណងរបស់ខ្លួន និងបានសួរសុខទុក្ខជនជាប់ចោទ ។ ពេលនោះជនជាប់ចោទ អៀង ធីរិទ្ធ បានអញ្ជើញលោកស្រីអង្គុយ


មេធាវីជាតិការពារក្តី ផាត់ ពៅសៀង
(ប្រភព ៖ មជ្ឈមណ្ឌលឯកសារកម្ពុជា)

លេង និងសំណេះសំណាលគ្នាពីសុខភាពរបស់ខ្លួន ជួនកាលត្អូញត្អែរថាឈឺជើង ពេលខ្លះថាជើងហើម ។ វេជ្ជបណ្ឌិត ធីតា បន្តទៀតថា លោកស្រីតែងតែសួរអំពីសុខភាពការហូបចុក ឬសុខទុក្ខគ្រួសាររបស់ជនជាប់ចោទ អៀង ធីរិទ្ធ ជានិច្ច មុនពេលផ្តើមការងាររបស់ខ្លួន ។ លោកស្រីបានអះអាងថាខ្លួនធ្វើការពិនិត្យ អៀង ធីរិទ្ធ រៀងរាល់១ទៅ២សប្តាហ៍ម្តង ចាប់តាំងពីខែកុម្ភៈ ឆ្នាំ ២០១២ ហើយលោកស្រីក៏ពុំធ្លាប់បានជួបប្រទះការបដិសេធរបស់ អៀង ធីរិទ្ធ មិនព្រមឲ្យចូលពិនិត្យនោះទេ ។ លោកស្រីសង្កេតឃើញថា ស្ថានភាពសុខភាពរបស់ អៀង ធីរិទ្ធ ចាប់ពីដើមដល់ចុងឆ្នាំ២០១១ ការឡូឡាចំពោះអ្នកធ្វើការនៅទីនោះ គឺមានការផ្លាស់ប្តូរនៅក្នុងរយៈពេល២ខែនេះ គឺមានសភាពធូរស្រាល ដោយសារជនជាប់ចោទមិនសូវមានការខឹងសម្បា ឬជះកំហឹងលើបុគ្គលិកនៅមន្ទីរឃុំឃាំង ។ លោកស្រី បានគូសបញ្ជាក់ទៀតថា លោកស្រីមិនធ្លាប់ឃើញរបាយការណ៍ណាមួយ ឬក៏ដឹងថា អៀង ធីរិទ្ធ បត់ជើងតូច ឬបត់ជើងធំនៅលើពូក ឬនៅក្នុងបន្ទប់គេងទេ ។ ជនជាប់ចោទ អៀង ធីរិទ្ធ នៅចាំឈ្មោះរបស់លោកស្រី បន្ទាប់ពីលោកស្រីបានណែនាំខ្លួននៅពេលជំនួបដំបូង ។

### (២.១.២) មេធាវីអន្តរជាតិ

បន្ទាប់ពីមេធាវីជាតិ ផាត់ ពៅសៀង បានបញ្ចប់ការសួរសំណួររបស់ខ្លួនមេធាវីអន្តរជាតិ គឺលោកស្រី ដាយអាណា


មេធាវីអន្តរជាតិការពារក្តី ដាយអាណា អេលីស
(ប្រភព ៖ មជ្ឈមណ្ឌលឯកសារកម្ពុជា)

អេលីស បានបន្តចោទសំណួរចំពោះវេជ្ជបណ្ឌិត ចក់ ធីតា ។ ដូចគ្នានឹងចៅក្រម អង្គជំនុំជម្រះ និងសហព្រះរាជអាជ្ញា មេធាវី អេលីស បានចាប់ផ្តើមជាមួយនឹងសំណួរទាក់ទងនឹងគុណវុឌ្ឍិរបស់លោកស្រីវេជ្ជបណ្ឌិត ។ បន្ទាប់មកមេធាវីបានបន្តជជីកសួរអំពីការចូលរួមពិនិត្យអំពីបញ្ហាសុខភាពរបស់ជនជាប់ចោទ អៀង ធីរិទ្ធ នៅមន្ទីរពេទ្យកាល់ម៉ែត្រ ។ ឆ្លើយតបនឹងសំណួរនេះ លោកស្រីវេជ្ជបណ្ឌិតបានអះអាងថា លោកស្រីមិនបានទទួលរបាយការណ៍ដែលចេញដោយសាស្ត្រាចារ្យ កា ស៊ុនបូណាត និងវេជ្ជបណ្ឌិត ប្រ៊ីនឌីដ ទេ ។ នៅក្នុងរបាយការណ៍នោះ វេជ្ជបណ្ឌិតទាំងពីររូបធ្លាប់បានរកឃើញថា អៀង ធីរិទ្ធ មានការចុះខ្សោយផ្នែកសតិបញ្ញាមានកម្រិតស្រាលនៅក្នុងឆ្នាំ២០០៩ ។ លោកស្រីវេជ្ជបណ្ឌិតបានបន្តថា

នៅពេលលោកស្រីជួបជនជាប់ចោទ អៀង ធីរិទ្ធ លើកដំបូងលោកស្រីមិនបានដឹងថា អៀង ធីរិទ្ធ មានជំងឺចុះខ្សោយសតិបញ្ញាទេ ។ លោកស្រីបានដឹងថា កាលពីឆ្នាំមុន អៀង ធីរិទ្ធ មានរោគសញ្ញានៃការរួមតូចនៃខួរក្បាល ដែលការវាយតម្លៃនោះគឺនៅក្នុងកម្រិតស្រាល ។ មេធាវី អេលីស បានសួរបញ្ជាក់ទៀតថា “វេជ្ជ


អ្នកចូលរួមកំពុងតាមដាននីតិវិធីនៅក្នុងសាលសវនាការ (ប្រភពរូបថត ៖ អ.វ.ត.ក)

បណ្ឌិតមួយចំនួននៅមន្ទីរពេទ្យកាល់ម៉ែត្របានចេញរបាយការណ៍រកឃើញថា អៀង ធីរិទ្ធ មានការចុះខ្សោយខាងបញ្ញា ហើយមានតែលោកស្រីវេជ្ជបណ្ឌិត ចក់ ធីតា តែមួយគត់ ដែលរកឃើញថា អៀង ធីរិទ្ធ មិនមានជំងឺខាងផ្លូវចិត្ត ឬជំងឺវិកលចរិត តើលោកស្រីអាចពន្យល់អ្វីបន្ថែមទេ? លោកស្រីបានពិភាក្សាជាមួយដុកទ័រផ្សេងទៀតទាក់ទងនឹងការសន្និដ្ឋានរបស់គេដែលថា វាខុសពីលោកស្រីត្រង់ណា? ដោយមូលហេតុអ្វីដែរឬទេ?» ។ វេជ្ជបណ្ឌិត ធីតា បានឆ្លើយតបនឹងសំណួរនេះថា ការធ្វើសេចក្ដីសន្និដ្ឋានចំពោះស្ថានភាពសតិបញ្ញាស្មារតីរបស់ អៀង ធីរិទ្ធ គឺមិនមែនផ្អែកតែលើលោកស្រីតែម្នាក់ឯងនោះទេ គឺលោកស្រីពឹងផ្អែកលើព័ត៌មានជាប្រចាំពីគិលានុបដ្ឋាក ដែលយាមប្រចាំការ, ព័ត៌មានពីគ្រូពេទ្យនៅប្រចាំការ និងអ្នកថែទាំ និងមានការប្រជុំជារួម ៗ ពាក់ព័ន្ធនឹងការអះអាងរបស់វេជ្ជបណ្ឌិត ចក់ ធីតា ដែលធ្វើការពិនិត្យតាមរយៈបង្កើតទំនាក់ទំនងជាមួយនឹងជនជាប់ចោទដោយផ្អែកលើភាពជាស្ត្រីដូចគ្នា លោកស្រីមេធាវីបានចោទសួរថា “តើលោកស្រីវេជ្ជបណ្ឌិតមិនធ្លាប់ដឹងទេថា អ្នកយាមជាស្ត្រីបានជួបនូវបញ្ហាជាច្រើនទាក់ទងនឹងអាកប្បកិរិយារបស់គាត់ក្នុងការធ្វើទំនាក់ទំនងទេ»? លោកស្រីបានបំភ្លឺថាការជួបគ្រូពេទ្យស្ត្រី គឺមិនមែនជួបតែ លោកស្រីម្នាក់នោះទេ គឺគ្រូពេទ្យទាំងអស់មានទាំងប្រុសទាំងស្រី ប៉ុន្តែមានពេលមួយនៅពេលដែលគ្រូពេទ្យទាំងអស់ទៅពិនិត្យខណៈពេលដែលជនជាប់ចោទ អៀង ធីរិទ្ធ ទើបចេញពីបន្ទប់ទឹកដោយមានចងពុងសារ៉ុង ពេលនោះជនជាប់ចោទបានប្រាប់អ្នកយាមថា មិនឲ្យគ្រូពេទ្យប្រុសចូលនោះទេ ព្រោះខ្លួនមិនទាន់ពាក់អាវត្រឹមត្រូវ ប៉ុន្តែគ្រូពេទ្យស្រីអាចចូលបាន ។

### ២.ត) ការសួរដេញដោលដោយតំណាងសហព្រះរាជអាជ្ញា

តំណាងសហព្រះរាជអាជ្ញាជាតិ សុង ឆវ័ន្ត បានសាកសួរចំពោះសាក្សីជំនាញ ចក់ ធីតា ដោយផ្តោតសំខាន់លើភាពពូកែឈ្លាសវៃរបស់លោកស្រី នៅពេលដែលលោកស្រីសិក្សានៅវិទ្យាល័យ ។ ការសួរសំណួរបញ្ជាក់អំពីភាពវៃឆ្លាតរបស់វេជ្ជ

បណ្ឌិត ចក់ ធីតា ដោយតំណាងសហព្រះរាជអាជ្ញា គឺដើម្បី បង្ហាញថា លោកស្រីវេជ្ជបណ្ឌិតមានសមត្ថភាព និងគុណវុឌ្ឍិ គ្រប់គ្រាន់ក្នុងការពិនិត្យ និងវាយតម្លៃអំពីបញ្ហាសុខភាពរបស់ ជនជាប់ចោទ អៀង ធីរិទ្ធ ។ បន្ទាប់មកតំណាងសហព្រះរាជអាជ្ញា ឆវីន្ត បានបន្តសំណួរទាក់ទងនឹងការបង្កើតទំនាក់ទំនងរវាងវេជ្ជ បណ្ឌិត និងអ្នកជំងឺ ។ វេជ្ជបណ្ឌិត ធីតា បានឆ្លើយថា ការបង្កើត ទំនាក់ទំនង គឺជាប្រធានបទមួយនៃការសិក្សាឯកទេសវិកល វិទ្យាហើយឆ្លងកាត់តាមទ្រឹស្តីនេះ នៅក្នុងការអនុវត្តគឺទទួលបាន



តំណាងសហព្រះរាជអាជ្ញាជាតិ សុង ឆវីន្ត
(ប្រភព : មជ្ឈមណ្ឌលឯកសារកម្ពុជា)

លទ្ធផលល្អនៅពេលដែលមានទំនាក់ទំនងល្អជាមួយអ្នកជំងឺធ្វើឲ្យ អ្នកជំងឺមានការជឿទុកចិត្ត និងអាចចែករំលែកសាច់រឿងរបស់ខ្លួន យ៉ាងលម្អិតមកដល់គ្រូពេទ្យ ។ លោកស្រីបានបន្ថែមថា បច្ចុប្បន្ន នេះខ្លួនកំពុងបង្រៀនឯកទេសវិកលវិទ្យាផ្នែកបង្កើតទំនាក់ទំនង និងអះអាងថា ការចាប់ផ្តើមដំបូង គឺត្រូវធ្វើការស្វាគមន៍ចំពោះ អ្នកជំងឺដោយការប្រាប់អំពីសមាសភាពរបស់ខ្លួនជាអ្នកណាមក ពីណាក្នុងគោលបំណងអ្វី ដើម្បីឲ្យមានការជឿទុកចិត្ត ។ ក្រោយពី ការស្វាគមន៍ គឺមានការសំណេះសំណាលអំពីបញ្ហារបស់អ្នកជំងឺ និងមានការកំណត់ច្បាស់លាស់ថា គួរនិយាយត្រឹមណា នៅពេល ជួបលើកទីមួយ និងពេលបន្ទាប់ ។

ឆ្លើយតបនឹងសំណួររបស់តំណាងសហព្រះរាជអាជ្ញាពាក់ព័ន្ធ នឹងឥរិយាបថវាយទ្វារខ្លាំងៗរបស់ជនជាប់ចោទ អៀង ធីរិទ្ធ វេជ្ជបណ្ឌិត ធីតា បានបញ្ជាក់ថា ឥរិយាបថបែបនេះ គឺអាច បណ្តាលមកពីជនជាប់ចោទចង់ចេញក្រៅ ទើបមានការនិយាយ ខ្លាំងៗទៅកាន់អ្នកយាម និងយកឈើច្រត់វាយទ្វារខ្លាំងៗ ប៉ុន្តែ ការវាយទ្វារនេះ គឺមិនមានការប៉ះពាល់ដល់ទូរទស្សន៍ និងកែវទឹក ដែលនៅជិតនោះឡើយ គឺវាយតែទ្វារប៉ុណ្ណោះ ។

### ២.ឃ) ការសួរដេញដោលដោយមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី

មេធាវីជាតិនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី គឺលោក ពេជ អង្គ បានសួរសំណួរមួយចំនួន ដោយផ្តោតសំខាន់លើវិធី សាស្ត្រក្នុងការធ្វើតេស្តដែលវេជ្ជបណ្ឌិត ចក់ ធីតា បានប្រើប្រាស់ ដើម្បីនិពិត្យ និងវាយតម្លៃស្ថានភាពសតិបញ្ញាស្មារតីរបស់ជន ជាប់ចោទ អៀង ធីរិទ្ធ ។ ឆ្លើយតបនឹងសំណួររបស់លោកមេធាវី ពេជ អង្គ វេជ្ជបណ្ឌិត ធីតា បានអះអាងថារបៀបនៃការធ្វើតេស្ត អឹម.អឹម.អេស.អ៊ី (M.M.S.E) របស់លោកស្រីមិនបានកែប្រែឲ្យ ខុសពីទម្រង់ដើមទាំងស្រុងនោះទេ គឺគ្រាន់តែមានលក្ខណៈបត់បែន ខ្លះៗតែប៉ុណ្ណោះ ។ ការបត់បែននេះលោកស្រីក៏បានពិភាក្សា ជាមួយគ្រូពេទ្យបរទេសចំពោះការយល់ដឹងរបស់ប្រជាជនកម្ពុជា ទាក់ទងនឹងការអនុវត្តនេះ ហើយគ្រូពេទ្យបរទេសបានឯកភាព



មេធាវីជាតិនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី ពេជ អង្គ
(ប្រភព : មជ្ឈមណ្ឌលឯកសារកម្ពុជា)

ចំពោះចំណុចទាំងនេះថា អាចទទួលបានលទ្ធផលដូចគ្នា ។ ប្រសិនបើ ប្រើប្រាស់ភាសាបច្ចេកទេសទាំងស្រុងមកអនុវត្តជាមួយអ្នកជំងឺ ពេលខ្លះនឹងមិនអាចទទួលបានលទ្ធផលនោះទេ ដោយសារតែអ្នក ជំងឺមិនអាចស្តាប់យល់ ។ ប៉ុន្តែពេលខ្លះលោកស្រីក៏បានប្រើប្រាស់

ការពិសោធតាមសំណៅដើមទាំងស្រុងជាមួយអ្នកជំងឺ ដែលមានកម្រិតយល់ដឹងខ្ពស់ដែរ ។ ឧទាហរណ៍ការអនុវត្តជាក់ស្តែងនៃសៀវភៅមួយហៅថា "Clinical Psychiatrist Second Edition" ។

### ៣) ការសួរដេញដោលក្រុមអ្នកជំនាញផ្នែកវិកលវិទ្យាទាំងបីរូប

បន្ទាប់ពីបញ្ចប់ការសាកសួរចំពោះវេជ្ជបណ្ឌិត ចក់ ធីតា ដែលជាសាក្សីជំនាញ អង្គជំនុំជម្រះបានបន្តកិច្ចដំណើរការនីតិវិធីសួរដេញដោលអ្នកជំនាញផ្នែកមនុស្សចាស់ និងជំនាញផ្នែកវិកលវិទ្យាទាំងបីរូប គឺលោកវេជ្ជបណ្ឌិត ចន ខាំប៊ែល, លោកវេជ្ជបណ្ឌិត ហួត លីណា និងលោកវេជ្ជបណ្ឌិត ស៊ីណា ហ្វាសែល ដែលអង្គជំនុំជម្រះបានចាត់តាំងឲ្យពិនិត្យព្យាបាលជនជាប់ចោទ អៀង ធីរិទ្ធ ។ សវនាការនេះ ធ្វើឡើងក្នុងគោលបំណងដើម្បីផ្តល់ឱកាសជូនភាគីសាកសួរអំពីរបាយការណ៍វាយតម្លៃចំពោះស្ថានសតិបញ្ញាស្មារតីរបស់ជនជាប់ចោទ អៀង ធីរិទ្ធ ដែលអ្នកជំនាញទាំងបីរូបបានរកឃើញ ។

#### ៣.ក) ការសួរដេញដោលដោយអង្គជំនុំជម្រះ

#### ៣.ក.១) កំណត់សម្គាល់របស់អ្នកជំនាញចំពោះរបាយការណ៍របស់វេជ្ជបណ្ឌិត ចក់ ធីតា

មុនពេលចាប់ផ្តើមការសាកសួរចំពោះអ្នកជំនាញទាំងបីរូប ប្រធានអង្គជំនុំជម្រះ គឺលោកចៅក្រម និល ណុន បានប្រគល់វេទិកាជូនលោកស្រីចៅក្រម ស៊ីលវៀ ខាតវ៉្រាយត៍ ដើម្បីសាកសួរសំណួរមួយចំនួនទាក់ទងនឹងរបាយការណ៍វាយតម្លៃអំពីស្ថានភាពសតិបញ្ញាស្មារតីរបស់ អៀង ធីរិទ្ធ និងការរកឃើញរបស់វេជ្ជបណ្ឌិត ចក់ ធីតា ។ លោកស្រីចៅក្រមក៏បានបញ្ជាក់ដែរថា អ្នកជំនាញណាម្នាក់ក៏បានក្នុងចំណោមអ្នកជំនាញទាំងបីរូបអាចឆ្លើយតបនឹងសំណួររបស់អង្គជំនុំជម្រះក្នុងនាមតំណាងឲ្យមតិយោបល់របស់អ្នកជំនាញទាំងបីរូបតែម្តង ឬមួយ ប្រសិនបើអ្នកជំនាញណាម្នាក់មានមតិយោបល់បន្ថែមអាចចូលឆ្លើយបញ្ជាក់បាន ។ ឆ្លើយតបនឹងការបញ្ជាក់របស់ចៅក្រម ខាតវ៉្រាយត៍ អ្នកជំនាញទាំងបីរូបបានសម្រេចប្រគល់ភារកិច្ចជូនលោកវេជ្ជបណ្ឌិត ស៊ីណា ហ្វាសែល ដើម្បីឆ្លើយតបនឹងសំណួររបស់ចៅក្រម និងភាគីតំណាងឲ្យអ្នកជំនាញទាំងបីរូប ។

ឆ្លើយតបនឹងសំណួររបស់ចៅក្រម ស៊ីលវៀ ខាតវ៉្រាយត៍ ទាក់ទងនឹងការវាយតម្លៃរបស់វេជ្ជបណ្ឌិត ចក់ ធីតា ចំពោះជនជាប់ចោទ អៀង ធីរិទ្ធ វេជ្ជបណ្ឌិត ស៊ីណា ហ្វាសែល បានធ្វើការកត់សម្គាល់នូវចំណុចមួយចំនួន ។ ទីមួយ លោកវេជ្ជបណ្ឌិត ហ្វាសែល បានលើកឡើងថា តាមការយល់ឃើញក្នុងក្រុមរបស់លោកចំពោះករណីដែល អៀង ធីរិទ្ធ រកនឹកមិនឃើញអំពីការសម្ភាស ឬការធ្វើតេស្តបន្ទាប់ពីខ្លួនបានធ្វើក្នុងរយៈពេលពីរ-បី


វេជ្ជបណ្ឌិត ស៊ីណា ហ្វាសែល
(ប្រភព៖ មជ្ឈមណ្ឌលឯកសារកម្ពុជា)

នាទីមុន គឺមិនមែនរឿងធម្មតាដូចជាអ្វីដែលវេជ្ជបណ្ឌិត ចក់ ធីតា បានលើកឡើងនោះទេ ។ លោកសន្និដ្ឋានថា យ៉ាងហោចណាស់ការភ្លេចភ្លាំងរបស់ អៀង ធីរិទ្ធ គឺជាការចុះខ្សោយសតិបញ្ញាកម្រិតមធ្យម ។ ចំណុចទីពីរ នៅក្នុងតេស្ត អឹម.អឹម.អេស.អ៊ី (M.M.S.E) ដែលវេជ្ជបណ្ឌិត ចក់ ធីតា បានបង្ហាញនោះ គឺមិនស្ថិតនៅក្នុងប្រភេទតេស្តនេះទេ ។ លោកបានផ្តល់ឧទាហរណ៍ថា អៀង ធីរិទ្ធ អាចនិយាយពាក្យ ប៊ិច និងនាឡិកាដៃនោះ គឺមិនស្ថិតនៅក្នុងប្រភេទតេស្ត អឹម.អឹម.អេស.អ៊ី ទេ ដោយសារតេស្តនេះមិនតម្រូវឲ្យធ្វើដូច្នេះ ។ លោកបានបន្តទៀតថា ចំណុចសំខាន់មួយទៀត គឺវេជ្ជបណ្ឌិត ចក់ ធីតា បានកាត់បន្ថយសំណួរមួយចំនួននៅក្នុងតេស្តនោះចេញ ហើយជំនួសដោយសំណួរផ្សេងដែលមានលក្ខណៈងាយស្រួលជាង និងសាមញ្ញជាង ។ ឧទាហរណ៍ នៅក្នុងតេស្តតម្រូវឲ្យអ្នកជំងឺសរសេរឃ្លា តែវេជ្ជបណ្ឌិត ធីតា បាន

ស្នើឲ្យជនជាប់ចោទ អៀង ធីរិទ្ធ សរសេរឈ្មោះគ្រូពេទ្យ ។ ការសរសេរឈ្មោះ គឺមិនដូចគ្នានឹងការសរសេរប្រយោគនោះទេ ។ ឧទាហរណ៍មួយទៀតនោះ គឺថាសំណួរទាក់ទងនឹងការចងចាំទីកន្លែងខេត្តណាដែលអ្នកជំងឺកំពុងរស់នៅ គឺអាចប្តូរទៅជាខេត្ត ឬរដ្ឋ ។ ប៉ុន្តែវេជ្ជបណ្ឌិត ចក់ ធីតា បានប្រើសំណួរទាក់ទងនឹងកូនចៅរបស់ អៀង ធីរិទ្ធ ទៅវិញ ។ ការណ៍នេះបានបង្ហាញឲ្យឃើញថា



សាស្ត្រាចារ្យ ចន ឌាំប៊ែល
(ប្រភព : មជ្ឈមណ្ឌលឯកសារកម្ពុជា)

ការចងចាំពីទីកន្លែង និងកូនចៅ គឺមិនមានភាពជាប់ទាក់ទងគ្នាទេ បើតាមការយល់ឃើញរបស់ក្រុមលោក ។ ចំណុចចុងក្រោយ វេជ្ជបណ្ឌិត ស៊ីណា ហ្វាសែល បានបញ្ជាក់ថា តាមការពិនិត្យដោយក្រុមលោកផ្ទាល់ មិនមានភស្តុតាងណាមួយនៅក្នុងរបាយការណ៍របស់វេជ្ជបណ្ឌិត ចក់ ធីតា ដែលបន្ថែមនូវលក្ខណៈវិនិច្ឆ័យទាក់ទងនឹងសមត្ថភាព ឬសម្បទាក្នុងការធ្វើការឆ្លើយតបនឹងការចោទប្រកាន់ ឬការជំនុំជម្រះនោះទេ ។ នៅត្រង់ចំណុចនេះ សាស្ត្រាចារ្យ ចន ឌាំប៊ែល បានបន្ថែមលើការលើកឡើងរបស់វេជ្ជបណ្ឌិត ហ្វាសែល ថា ការចងចាំ គឺជាចំណុចសំខាន់ដែលអ្នកមានជំងឺវង្វេងវង្វាន់ (Dementia) មើលពីខាងក្រៅគឺមានសភាពធម្មតា ប៉ុន្តែប្រសិនបើមើលឲ្យស៊ីជម្រៅទើបអាចដឹងច្បាស់ថា អ្នកជំងឺជួបប្រទះនឹងបញ្ហាវង្វេងវង្វាន់ ។ សាស្ត្រាចារ្យ ឌាំប៊ែល បានបន្តទៀតថា ក្រុមរបស់លោកបានរកឃើញថា អៀង ធីរិទ្ធ មិនសូវចងចាំសមាជិកគ្រួសារ ឬស្ថានភាពគ្រួសារនាពេលបច្ចុប្បន្នទេ ។ ចំណុចសំខាន់មួយទៀត គឺការទទួលបានប្រវត្តិជំងឺរបស់ អៀង ធីរិទ្ធ ពីសាស្ត្រាចារ្យ កា ស៊ុនបូណាត និងសាស្ត្រាចារ្យ ប្រ៊ីនឌីដ នៅក្នុងឆ្នាំ២០០៩ ដែលបានសន្និដ្ឋាននៅក្នុងរបាយការណ៍របស់ខ្លួនថា អៀង ធីរិទ្ធ មានជំងឺវង្វេងវង្វាន់ដំណាក់កាលដំបូង ដែលមានការចុះខ្សោយផ្នែកមុខងារសតិបញ្ញា និងការចងចាំ ។ សាស្ត្រាចារ្យបញ្ជាក់ថាជំងឺរបស់ អៀង ធីរិទ្ធ គឺបានបញ្ជាក់ច្បាស់នូវការចុះខ្សោយមុខងារសតិបញ្ញា ដែលមានលក្ខណៈស្រាល ប៉ុន្តែស្ថិតនៅក្នុងស្ថានភាពមួយមធ្យម និងឈានទៅរកភាពធ្ងន់ធ្ងរដែលអាចបណ្តាលឲ្យចុះខ្សោយកាន់តែខ្លាំងទៅៗ ។

លោកស្រីចៅក្រមបានសួរបញ្ជាក់អំពីបញ្ហាវប្បធម៌ដែលសាក្សីវេជ្ជបណ្ឌិត ចក់ ធីតា បានប្រើភាពជាស្ត្រីដូចគ្នាក្នុងការបង្កើតទំនាក់ទំនងល្អដើម្បីព្យាបាលធ្វើតេស្តជនជាប់ចោទ អៀង ធីរិទ្ធ ។ ឆ្លើយតប នឹងការលើកឡើងរបស់លោកស្រីចៅក្រមនៅត្រង់ចំណុចនេះ វេជ្ជបណ្ឌិត ហ្វាសែល បានរៀបរាប់ថា បញ្ហាវប្បធម៌ គឺពិតជាមានសារៈសំខាន់ណាស់ ។ លោកបានធ្វើការពិចារណា និងប្រឹងប្រែងយ៉ាងខ្លាំង ដើម្បីទទួលបានព័ត៌មានគ្រប់គ្រាន់ពីបុគ្គលដែលចូលរួមថែទាំ អៀង ធីរិទ្ធ ជាយូរមកហើយ ។ ចំណែកឯសាស្ត្រាចារ្យ ចន ឌាំប៊ែល បានបញ្ចេញយោបល់ចំពោះការវាយតម្លៃរបស់វេជ្ជបណ្ឌិត ចក់ ធីតា ទាក់ទងនឹងជួបប្រទះនូវដំណាក់កាលមុនជំងឺវិកលចរិតថា វេជ្ជបណ្ឌិត ធីតា បានព្យាយាមធ្វើការបែងចែកការប្រែប្រួលរវាងជំងឺមួយដំណាក់កាលមុនវិកលចរិតរបស់ជនជាប់ចោទ ។

### ៣.ក.២) ការវង្វេងវង្វាន់ជាការធ្វើពុតរបស់ អៀង ធីរិទ្ធ ឬ?

បន្ទាប់មក លោកស្រីចៅក្រម ស៊ីលវៀ ខាតវ្រ៉ាយត៍ បានបន្តសំណួរទាក់ទងនឹងការធ្វើពុតរបស់ជនជាប់ចោទ អៀង ធីរិទ្ធ ថា ៖

*“នៅក្នុងករណីដែលបុគ្គលណាម្នាក់ គាត់មានជម្ងឺខាងផ្នែកសតិបញ្ញានោះ គឺពេលខ្លះយើង មិនអាចថាអ្នកជំងឺធ្វើពុតជាឈឺ ឬក៏ធ្វើជាមានជំងឺនេះទេ ។ តើអញ្ចឹងដែរឬទេ? យើងសង្កេតឃើញថា មានករណីមួយចំនួន ដែលគេនិយាយថាលោកស្រី អៀង ធីរិទ្ធ ធ្វើជាឈឺ ដើម្បីជៀសវាងកុំឲ្យមានការចាប់យក*

មកកាត់ទោស ។ នេះជាបញ្ហាមួយធ្ងន់ធ្ងរណាស់ តើលោកអាចពន្យល់បន្ថែមថាតើលោកស្រី អៀង ធីរិទ្ធ ធ្វើពុតជាឈឺដែរឬទេ?»

សាស្ត្រាចារ្យ ចន ខាំប៊ែល បានឆ្លើយតបនឹងសំណួរនេះថា ៖ «យើងប្រយ័ត្នណាស់ចំពោះចំណុចនេះ ។ យើងដឹងចំពោះចំណុចនេះ ។ ក្នុងពេលដែលយើងធ្វើតេស្ត យើងមិនដែលឃើញសញ្ញាបញ្ជាក់ណាមួយដែលថា អៀង ធីរិទ្ធ ធ្វើការបន្លំទៅលើសំណួរដែលគាត់មិនអាចឆ្លើយនោះទេ ។ ចំណុចចុងក្រោយនៅពេលដែលយើងធ្វើតេស្តមួយ ដែលដកលេខ៧/នោះ គឺគាត់មិនអាចដកពី៧/២ ទៅដល់លេខ៧/៥ នោះទេ ។ ដូច្នេះហើយ គាត់អាចដកត្រឹមតែ៧/៩ តែប៉ុណ្ណោះ ។ ដូច្នេះវាមិនមែនជាការដែលគាត់ធ្វើពុតនោះឡើយ ។ អាកប្បកិរិយារបស់គាត់ និងមុខនាទីដំណើរការរបស់គាត់វាមានការចុះខ្សោយ ហើយវាស្របទៅនឹងអ្វីដែលយើងបានពិនិត្យឃើញ ពេលដែលយើងធ្វើវិនិច្ឆ័យកាលពីលើកមុន ។ ដូច្នេះហើយ គឺមិនអាចថា គាត់ធ្វើពុតអីចឹងក្នុងរយៈពេលយូរដូច្នេះនោះឡើយ» ។

ក្រោយមកលោកស៊ីណា ហ្វាសែល បានបន្ថែមទៅលើការលើកឡើងរបស់សាស្ត្រាចារ្យ ខាំប៊ែល ថា ៖

«ទាក់ទងនឹងយោបល់មួយដែលលោកឆ្លើយតបនឹងការធ្វើពុត ឬក្លែងបន្លំដូចលោកវេជ្ជបណ្ឌិត កា ស៊ុនបូណាត គឺថាដូចលោកវេជ្ជបណ្ឌិត ចន ខាំប៊ែល បាបបញ្ជាក់ដែរ ក្នុងការធ្វើពុតអំពីការកែប្រែអំពីអនាម័យផ្ទាល់ខ្លួនរបស់គាត់ ដូចជា អៀង ធីរិទ្ធ រាគនោមដាក់សំពត់ជាដើម ។ យើងមានការពិបាកក្នុងការធ្វើពុតបែបនេះ អ្វីដែលយើងកត់សម្គាល់នោះគឺថា ការឡើងចុះនៃមុខងារសតិបញ្ញា ជាពិសេសអំពីការផ្ទុះកំហឹង អាការកោងកាចរបស់ អៀង ធីរិទ្ធ ចំពោះអ្នកយាមជាដើម គឺថាប្រសិនបើមនុស្សធ្វើពុត គេអាចនឹងធ្វើពុតដដែល ។ ប៉ុន្តែនេះវាមានការខុសគ្នាពីម្តងទៅម្តង ជាពិសេសពេលឆ្លើយតបសំណួរទាក់ទងទៅនឹងការចងចាំដូចនៅដំណាក់កាល ដែលយើងសួរសម្ភាសន៍ អៀង ធីរិទ្ធ មិនចាំឈ្មោះប្តីរបស់ខ្លួនទេ ប៉ុន្តែថ្ងៃទីពីរ គាត់មានការចងចាំឈ្មោះប្តីវិញ ។ នេះជាទស្សនៈរបស់ខ្ញុំគឺថា មនុស្សពិបាកនឹងធ្វើពុតអំពីការចងចាំរបស់ខ្លួនណាស់ ហើយវាមានបញ្ហាច្រើនទៀតគឺថា យើងពិនិត្យមើលពីមួយថ្ងៃទៅមួយថ្ងៃ គឺការធ្លាក់ចុះ ហើយការចងចាំ និងការនឹកឃើញគឺថាផ្លាស់ប្តូរ ។ ពេលខ្លះ អៀង ធីរិទ្ធ នឹកឃើញកិច្ចការ ដែលបានទៅរៀននៅបរទេស ប៉ុន្តែការសន្ទនាបន្ទាប់មកគាត់ឆ្លើយថា ទេ រៀននៅភ្នំពេញទេ ។ ដូច្នេះបើមាននរណាម្នាក់ធ្វើពុត គេនឹងរក្សាការធ្វើពុតហ្នឹងដូចគ្នា គឺថាគេនឹងប្រកាន់ការធ្វើពុតហ្នឹងដដែលៗ ប៉ុន្តែនេះគឺខុសគ្នាពីកាលមួយទៅកាលមួយ» ។

ឆ្លើយតបនឹងសំណួរបន្ទាប់ សាស្ត្រាចារ្យ ចន ខាំប៊ែល បានអះអាងថា តាមរយៈប្រវត្តិនៃការវិវត្តរបស់ជំងឺដែលតាមដានដោយលោកវេជ្ជបណ្ឌិត កា ស៊ុនបូណាត និង ប្រ៊ិនឌីដ លោកយល់ឃើញថា គ្រប់ពេលដែលលោកបានជួប អៀង ធីរិទ្ធ គឺលទ្ធភាពនៃសតិបញ្ញាមានសភាពចុះខ្សោយជាលំដាប់ ។ លោកមិនបានរកឃើញថា មានការប្រសើរឡើងដោយសារការប្រើថ្នាំព្យាបាលនោះទេ ដោយសារ អៀង ធីរិទ្ធ មានជំងឺវង្វេងវង្វាន់ស្មារតីធ្ងន់ធ្ងរ ដែលមិនមានការព្យាបាលណាមួយអាចមានប្រសិទ្ធភាព ។ ដូច្នេះ ក្រុមរបស់លោកមិនមានអនុសាសន៍ក្នុងការប្រើប្រាស់ថ្នាំអ៊ីតទៀតឡើយ ។

### ៣.១) ការសួរដេញដោលដោយតំណាងសហព្រះរាជអាជ្ញា

តំណាងសហព្រះរាជអាជ្ញាអន្តរជាតិ ថារីក អាប់ឌុលហាក់ បានចាប់ផ្តើមសួរដោយស្នើឲ្យអ្នកជំនាញទាំងបីរូបធ្វើការពន្យល់បន្ថែមអំពីការកត់សម្គាល់របស់អ្នកជំនាញវិជ្ជាជីវៈនៅប្រទេសសិង្ហបុរី ថា «ចំពោះសមត្ថភាពរបស់លោកស្រី អៀង ធីរិទ្ធ ខាងសតិបញ្ញានេះតាំងពីអនុវត្តកម្មវិធីដាស់សតិបញ្ញា បញ្ជាក់ថាមិនមានការកែប្រែនៅក្នុងសតិបញ្ញា ថាតើលោកយល់យ៉ាងដូចម្តេចដែលថា តាមពិន្ទុនោះ គឺថាមានការចុះខ្សោយទៅមុខជាលំដាប់នោះ?»

ឆ្លើយតបនឹងសំណើនេះអ្នកជំនាញ ចន ខាំប៊ែល បានពន្យល់ថា ជំងឺភ្លេចភ្លាំងគឺជាការចុះខ្សោយយឺតៗជាលំដាប់ ប៉ុន្តែរោគសញ្ញានៃជំងឺនេះពុំមែនបង្ហាញឲ្យឃើញត្រឹមតែរយៈពេល៣ខែទេ គឺលេចឡើងក្នុងរយៈពេលវែង ។ ចំណែកឯអ្នកជំនាញ ស៊ីណា ហ្វាសែល បានបញ្ជាក់ទាក់ទងនឹងសកម្មភាពរបស់ អៀង ធីរិទ្ធ ថាការប្រើពាក្យសម្តីមិនពិរោះចំពោះអ្នកមើលថែទាំ ដោយពេលខ្លះ

ដេរអ្នកទាំងនោះ ពេលខ្លះប្រើពាក្យសម្តីសុភាពរាបសារ និងពេលខ្លះបានចោទថាបុគ្គលិកមើលថែបានលួចរបស់របរខ្លួន គឺជាសញ្ញាបញ្ជាក់អំពីការចុះខ្សោយនៃការវិនិច្ឆ័យ និងការគ្រប់គ្រងនៅក្នុងស្ថានភាពសង្គមរបស់ អៀង ធីរិទ្ធ ដែលជាចំណុចសំខាន់ឈានទៅរកលទ្ធភាពខ្សោយនៃសតិបញ្ញា ។ អ្នកជំនាញទាំងបីរូបបានផ្តល់យោបល់ថា ការប្រើប្រាស់ថ្នាំមិនអាចជួយលើកកម្ពស់សតិបញ្ញារបស់ អៀង ធីរិទ្ធ បាននោះទេ ។ អៀង ធីរិទ្ធ ត្រូវតែមានការ


តំណាងសហព្រះរាជអាជ្ញាអន្តរជាតិ ថារីក អាប់ឌុលហាក់
(ប្រភព ៖ មជ្ឈមណ្ឌលឯកសារកម្ពុជា)

ជួយជ្រោមជ្រែង និងគាំទ្រពីគិលានុបដ្ឋាកនៅផ្ទះដោយផ្ទាល់ ។

### ៣.គ) ការសួរដេញដោលដោយមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី

#### ៣.គ.១) មេធាវីជាតិ

មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី គឺលោក ពេជ អង្គ បានចាប់ផ្តើមចោទសំណួរអំពីពេលវេលា ដែលវេជ្ជបណ្ឌិតទាំងបីប្រើប្រាស់ដើម្បីពិនិត្យ និងតាមដានស្ថានភាពបញ្ញាស្មារតីរបស់ជនជាប់ចោទ អៀង ធីរិទ្ធ ។ វេជ្ជបណ្ឌិត ហ្វាសែល បានបញ្ជាក់ថា នៅក្នុងជំនួបរវាងក្រុមរបស់លោកជាមួយនឹង អៀង ធីរិទ្ធ គឺធ្វើឡើងដោយមានជំនួយពីសហការីជនជាតិខ្មែរ និងថានៅក្នុងតេស្ត អឹម.អឹម.អេស.អ៊ី គឺត្រូវបានប្រើប្រាស់សំណួរដដែលៗនៅក្នុងពេលវេលាផ្សេងៗគ្នា ដើម្បីពិនិត្យមើលមុខងារសតិបញ្ញាផ្នែកខួរក្បាល ។ លោកមេធាវីបានបន្តសួរទាក់ទងនឹងចំនួនលោកគ្រូពេទ្យដែលជាបុរសនៅក្នុងបន្ទប់ជនជាប់ចោទ អៀង ធីរិទ្ធ ក្នុងអំឡុងពេលធ្វើតេស្ត ថាតើអាចមានផលប៉ះពាល់ដល់ការឆ្លើយសំណួរដែរឬទេ? សាស្ត្រាចារ្យ ចន ខាំប៊ែល បានបញ្ជាក់ថា អ្នកជំនាញ និងគ្រូពេទ្យទាំងអស់គ្នា ពេលខ្លះបានសង្កេតឃើញថា អៀង ធីរិទ្ធ មានការខឹងសម្បារ ពេលខ្លះមានការយល់ស្រប ដែលការឡើងចុះនៃអារម្មណ៍នេះមិនឆ្លុះបញ្ចាំងអំពីចំនួនមនុស្សដែលចូលរួមធ្វើតេស្ត និងការប្រើប្រាស់ភាសា ដែលផ្តល់ជំនួយពី


វេជ្ជបណ្ឌិត ហួត លីណា
(ប្រភព ៖ មជ្ឈមណ្ឌលឯកសារកម្ពុជា)

អ្នកបកប្រែនោះទេ ។ វេជ្ជបណ្ឌិត ហួត លីណា បានបញ្ជាក់បន្ថែមព័ត៌មានពីលើសហការីរបស់ខ្លួនថា មុននឹងចូលធ្វើតេស្ត ក្រុមរបស់លោក បានធ្វើការណែនាំខ្លួនម្នាក់ម្តងៗ ហើយពេលនោះជនជាប់ចោទ អៀង ធីរិទ្ធ បានអនុញ្ញាតដោយញញឹម រីករាយ និងទទួលរាក់ទាក់ ។ លោកបន្តថា ទង្វើនេះមានន័យថា អៀង ធីរិទ្ធ មិនមានការទើសទាល់ចំពោះវត្តមានគ្រូពេទ្យច្រើននាក់នោះទេ ។ លោកបានលើកឡើងពីបច្ចេកទេសនៃការសម្ភាស ។ ដំបូង គឺតម្រូវឲ្យមានរបាយការណ៍ជាផ្នែកមួយដែលគ្រូពេទ្យឯកទេសវិកលវិទ្យា មានលក្ខណៈខុសពីគ្រូពេទ្យព្យាបាលជំងឺផ្លូវកាយ ។ ចំណុចនេះបញ្ជាក់ថា ការពិនិត្យព្យាបាលជំងឺផ្លូវចិត្តត្រូវទាមទារឲ្យមានទំនាក់ទំនងល្អជាមួយអ្នកជំងឺ ធ្វើឲ្យអ្នកជំងឺមានអារម្មណ៍ធូរស្រាល ទើបគ្រូពេទ្យអាចចាប់ផ្តើមដំណើរការសម្ភាសន៍ ។ លោកវេជ្ជបណ្ឌិត លីណា បានយល់ស្របជាមួយនឹងការលើកឡើងរបស់

វេជ្ជបណ្ឌិត ចក់ ធីតា ដែលអះអាងថា គ្រូពេទ្យត្រូវទទួលការបណ្តុះបណ្តាលតាំងពីការប្រើប្រាស់ពាក្យសម្តី ការរៀបចំឥរិយាបថ និងជៀសវាងការសម្តែងនូវអាកប្បកិរិយាណាមួយរំខានដល់អ្នកជំងឺ ដូចជា មិនអាចងើបឈរ, បុកពារឡេះឡោះ, អង្គុយមិននឹង, ការលើកទូរស័ព្ទ ឬកាយវិការណាមួយរំខានដល់អ្នកជំងឺ ។ គ្រូពេទ្យហាមមិនឲ្យសើចដាក់អ្នកជំងឺឡើយ ត្រូវធ្វើយ៉ាងណាឲ្យអ្នកជំងឺយល់ថា គ្រូពេទ្យយកចិត្តទុកដាក់ជាមួយខ្លួន ។ វេជ្ជបណ្ឌិត លីនណា បានធ្វើសេចក្តីសន្និដ្ឋានថា ខ្លួនបានឃើញ អៀង ធីរិទ្ធ មានការសហការល្អជាមួយក្រុមរបស់លោក ទោះបីឆ្លើយរួច ឬមិនរួចយ៉ាងណាក៏ដោយ អៀង ធីរិទ្ធ បានព្យាយាមឆ្លើយ ហាក់ដូចជាមិនមានអារម្មណ៍ថា អៀង ធីរិទ្ធ ខំគេចវេះពីសំណួរ ឬធ្វើពុតនោះទេ ។

### ៣.គ.២) មេធាវីអន្តរជាតិ

មេធាវីអន្តរជាតិតំណាងដើមបណ្តឹងរដ្ឋប្បវេណី គឺលោកស្រី អេលីហ្សាប៉ែត ស៊ីម៉ុនណូហ្វត បានបន្តសំណួរមួយចំនួនពីសហភាគារបស់ខ្លួន ។ លោកស្រីបានលើកយកសំណួរមួយទាក់ទងនឹងសីលធម៌ ថាតើមានការកំណត់ដែរឬទេ ចំពោះអ្នកជំងឺជាស្ត្រីត្រូវ



មេធាវីអន្តរជាតិនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី អេលីហ្សាប៉ែត ស៊ីម៉ុនណូហ្វត (ប្រភព : មជ្ឈមណ្ឌលឯកសារកម្ពុជា)

ឲ្យគ្រូពេទ្យជាស្ត្រីពិនិត្យនោះ? វេជ្ជបណ្ឌិត ហ្វូត លីណា បានឆ្លើយតបនឹងសំណួរនេះថា តាមការយល់ដឹងរបស់លោក គឺមិនមានលក្ខខណ្ឌណាមួយ ដែលថាអ្នកជំងឺផ្លូវចិត្តស្រីត្រូវតែព្យាបាលដោយពេទ្យជាស្ត្រីនោះទេ ។ នៅប្រទេសកម្ពុជា ថ្វីត្បិតតែវប្បធម៌ខ្មែរដូចជាតឹងរ៉ឹងបន្តិចសម្រាប់ស្ត្រី ប៉ុន្តែជាក់ស្តែងគឺមានគ្រូពេទ្យជាបុរសបានពិនិត្យ និងព្យាបាលរោគស្ត្រី ។ លោកវេជ្ជបណ្ឌិតបានបញ្ជាក់ទៀតថា ដូច្នេះគឺសបញ្ជាក់ឲ្យឃើញថា គ្មានច្បាប់ទម្លាប់ណាដែលថាហាមឃាត់មិនឲ្យបុរសធ្វើជាគ្រូពេទ្យឯកទេសព្យាបាលជំងឺស្ត្រីទេ ។ លោកស្រីមេធាវីបានបន្តសួរទាក់ទងនឹងបច្ចេកវិទ្យាថ្មីដែលអាចព្យាបាលជំងឺរបស់ជនជាប់ចោទ អៀង ធីរិទ្ធ ។ ឆ្លើយតបនឹងសំណួរនេះ អ្នកជំនាញ ចន ខាំប៊ែល បានរៀបរាប់ថា លោកមិនទាន់មានបច្ចេកវិទ្យាថ្មីណាមួយដែលមានលទ្ធភាពក្នុងការព្យាបាលនៅក្នុងករណីនេះទេ ហើយក៏មិនទាន់មានជម្រើសថ្មីណាមួយដែរ ។ លោកបន្តថា ជំងឺភ្លេចភ្លាំងនឹងមានសភាពកាន់តែធ្ងន់ធ្ងរ និងវិវត្តទៅមុខជានិច្ច ។

### ៣.ឃ) ការសួរដេញដោលដោយក្រុមមេធាវីការពារក្តីជនជាប់ចោទ អៀង ធីរិទ្ធ

#### ៣.ឃ.១) មេធាវីជាតិ

មេធាវីជាតិការពារក្តីជនជាប់ចោទ អៀង ធីរិទ្ធ លោក ផាត់ ពៅស៊ាង ត្រូវបានផ្តល់វេទិកាដើម្បីសាកសួរវេជ្ជបណ្ឌិតទាំងបីរូប ដែលជាអ្នកជំនាញព្យាបាល និងពិនិត្យស្ថានភាពសតិបញ្ញាស្មារតីកូនក្តីរបស់ខ្លួន ។ មេធាវី ពៅស៊ាង បានចាប់ផ្តើមសំណួររបស់ខ្លួនដោយផ្តោតសំខាន់លើការដាក់ពិន្ទុក្នុងការធ្វើតេស្តលើកូនក្តីរបស់ខ្លួនរវាងក្រុមអ្នកជំនាញទាំងបីរូប និងវេជ្ជបណ្ឌិត ចក់ ធីតា ថាតើការដាក់ពិន្ទុណាមួយដែលមានភាពត្រឹមត្រូវ? លោកវេជ្ជបណ្ឌិត ស៊ីណា ហ៊ុស៊ែល បានឆ្លើយតបនឹងសំណួរនេះថា ការកំណត់ពិន្ទុនិងសំណួរដែលវេជ្ជបណ្ឌិត ចក់ ធីតា បានធ្វើ គឺមិនមានភាពត្រឹមត្រូវ និងមិនអាចយកជាការបានទេ ។ លោកបន្តទៀតថា សតិបញ្ញាស្មារតីរបស់ អៀង ធីរិទ្ធ ពុំទាន់មានការកែប្រែប្រសើរជាងមុនឡើយ ។ តាមមតិរបស់លោក មុខងារសតិបញ្ញាស្មារតីរបស់ អៀង ធីរិទ្ធ មានសភាពកាន់តែចុះខ្សោយជាលំដាប់ក្នុងរយៈពេលពីរទៅបីខែចុងក្រោយនេះ ។

បន្ទាប់មកលោកមេធាវីបានបន្តសួរអំពីការលើកឡើងរបស់វេជ្ជបណ្ឌិត ចក់ ធីតា ទាក់ទងនឹងលទ្ធភាពក្នុងការអានភាសាបរទេសរបស់ អៀង ធីរិទ្ធ ។ ឆ្លើយតបនឹងសំណួរនេះ សាស្ត្រាចារ្យ

ចន ខាំប៊ែល បានពន្យល់ថា ចំពោះលោក គឺពុំមានមតិយោបល់លើការរកឃើញរបស់វេជ្ជបណ្ឌិត ចក់ ធីតា ទេ ដោយសារលោកមិនយល់ពីស្ថានភាព និងរបៀបធ្វើតេស្តដែលវេជ្ជបណ្ឌិត ធីតា បានអនុវត្ត ។ លោកមេធាវី ពៅស៊ាង បានបន្តសួរទៀតថា តើមនុស្សម្នាក់ដែលអាចអានបាន អាចសន្និដ្ឋានថា មិនមានជំងឺវង្វេងវង្វាន់ដែរឬទេ? អ្នកជំនាញ ខាំប៊ែល មិនបានយល់ស្របចំពោះការសន្និដ្ឋានបែបនេះឡើយ ដោយលោកអះអាងថា អ្នកជំងឺអាចអានបានមិនប្រាកដថាអ្នកជំងឺអាចយល់ដឹងអំពីអត្ថន័យនោះទេ ។ លោកបានបញ្ជាក់បន្ថែមទៀតថា លោកមិនបានដឹងថា នៅពេល អៀង ធីរិទ្ធ អាននោះ មានការយល់ដឹងត្រឹមណានោះទេ ហើយលោកក៏មិនបានដឹងថាវេជ្ជបណ្ឌិត ចក់ ធីតា ប្រើប្រាស់សំណួរនៅក្នុងកម្រិតណានោះដែរ ។

នៅក្នុងសំណួរចុងក្រោយរបស់ខ្លួន មេធាវី ផាត់ ពៅស៊ាង បានសួរបញ្ជាក់ពីស្ថានភាពស្មារតីរបស់ អៀង ធីរិទ្ធ ដែលអ្នកជំនាញបានសន្និដ្ឋានថា *"ជាដំណាក់កាលចុងក្រោយ"* ។ វេជ្ជបណ្ឌិត ស៊ីណា ហ្វាស៊ែល បានពន្យល់ចំពោះការប្រើប្រាស់ពាក្យខាងលើថា ក្រុមរបស់លោកមានទស្សនៈស្របគ្នាថា អៀង ធីរិទ្ធ មានជំងឺវង្វេងវង្វាន់ពីកម្រិតមធ្យមទៅដល់កម្រិតធ្ងន់ធ្ងរ ។ តាមការយល់ដឹងរបស់ក្រុមលោក គឺមិនមានការព្យាបាលណាមួយ ឬការប្រើថ្នាំណាមួយដែលអាចជួយកែលម្អមុខងារសតិបញ្ញារបស់ អៀង ធីរិទ្ធ បានទេ ។

### ៣.ឃ.២) មេធាវីអន្តរជាតិ

មេធាវីអន្តរជាតិការពារក្តីជនជាប់ចោទ អៀង ធីរិទ្ធ គឺលោកស្រី ដាយអាណា អេលីស បានបន្តសំណួរពីសហមេធាវីជាតិរបស់ខ្លួន ដោយបន្តចោទសួរអំពីរបៀបនៃការសន្និដ្ឋានរបស់អ្នកជំនាញទាំងបីរូប ដែលរកឃើញថា អៀង ធីរិទ្ធ មានជំងឺវង្វេងវង្វាន់តាមគោលការណ៍ស្តង់ដារ ដែលធ្វើឡើងដោយអង្គការសុខភាពពិភពលោក ។ វេជ្ជបណ្ឌិត ស៊ីណា ហ្វាស៊ែល បានឆ្លើយតបនឹងសំណួរនេះថា ក្រុមរបស់លោកបានប្រើប្រាស់មធ្យោបាយដែលមានលក្ខណៈស្តង់ដារអន្តរជាតិក្នុងការធ្វើរោគវិនិច្ឆ័យជំងឺរបៀបនេះ ។ ឆ្លើយតបនឹងសំណួររបស់មេធាវីទាក់ទងនឹងភាពវង្វេងវង្វាន់របស់ជនជាប់ចោទ អៀង ធីរិទ្ធ អ្នកជំនាញបានលើកឡើងថា ការណ៍ដែល អៀង ធីរិទ្ធ មើលឃើញមុងដែលចងថាជាមនុស្ស ឬជាក្បាលខ្មោច ឬជាកូនក្មេង ហើយការពិតមិនមានអ្វីសោះនោះ គឺជារឿងមិនធម្មតាឡើយ ហើយចាំបាច់ត្រូវមានការពិនិត្យមើលឲ្យបានពិស្តារ ព្រោះលទ្ធភាពដែលនាំឲ្យនិយាយបែបនេះ គឺជាអារម្មណ៍មិនធម្មតា ។ លោកស្រីមេធាវីអន្តរជាតិបានលើកឡើងពីយោបល់របស់អ្នកជំនាញដែលបានផ្តល់ប្រឹក្សាអំពីករណីផ្លាស់ប្តូរឲ្យ អៀង ធីរិទ្ធ រស់នៅឲ្យបានសមស្របជាមួយក្រុមគ្រួសារវិញ ។ សាស្ត្រាចារ្យ ចន ខាំប៊ែល បានបំភ្លឺថា អៀង ធីរិទ្ធ ចាំបាច់ត្រូវមានការថែទាំដើម្បីបំពេញទៅតាមតម្រូវការផ្នែករាងកាយ ហើយការផ្តល់ជូននេះ គឺអាចធ្វើឡើងដោយសមាជិកគ្រួសារ ឬអ្នកផ្តល់សេវាគាំទ្រពីខាងក្រៅ ។

## ៤) សេចក្តីសន្និដ្ឋានរបស់ភាគី

បន្ទាប់ពីបញ្ចប់ការសាកសួររបស់ភាគីទាក់ទងនឹងរបាយការណ៍របស់អ្នកជំនាញទាំងបីរូប លោកប្រធានអង្គជំនុំជម្រះ និល ណុន បានផ្តល់វេទិកាជូនភាគីទាំងអស់ ដើម្បីបង្ហាញពីសេចក្តីសន្និដ្ឋានរបស់ខ្លួន ចំពោះរបាយការណ៍របស់អ្នកជំនាញទាំងបីរូប និងរបាយការណ៍របស់វេជ្ជបណ្ឌិត ចក់ ធីតា ។

### ៤.ក) សេចក្តីសន្និដ្ឋានរបស់សហព្រះរាជអាជ្ញា

តំណាងសហព្រះរាជអាជ្ញាអន្តរជាតិ អាប់ឌុលហាក់ ថាវីក បានលើកឡើងធ្វើសេចក្តីសន្និដ្ឋាន ដោយយោងលើវិធានច្បាប់អន្តរជាតិ និងច្បាប់របស់អង្គជំនុំជម្រះថា ការណ៍ដែលជនជាប់ចោទមិនមានសម្បទាគ្រប់គ្រាន់ក្នុងការចូលរួមសវនាការ មិនមែនមានន័យថា ដំណើរការក្តីនៃសំណុំរឿងនោះត្រូវបានបញ្ចប់នោះទេ ប៉ុន្តែករណីនេះគ្រាន់តែជាការពន្យាពេលកិច្ចដំណើរការនីតិវិធីតែប៉ុណ្ណោះ ។ ចំពោះស្ថានភាពនៃការវង្វេងវង្វាន់របស់ជនជាប់ចោទ អៀង ធីរិទ្ធ សហព្រះរាជអាជ្ញាទទួលស្គាល់ថា លទ្ធភាពក្នុងការព្យាបាលជនជាប់ចោទបន្តទៀតនោះ ហាក់ដូចជាមិនអាចបន្តធ្វើតទៀតបានឡើយ ដូច្នេះជំហររបស់សហព្រះរាជអាជ្ញាគឺស្នើសុំឲ្យអង្គជំនុំជម្រះដោះលែងជនជាប់ចោទ អៀង ធីរិទ្ធ ប៉ុន្តែត្រូវមានភ្ជាប់ជាមួយនឹងលក្ខខណ្ឌ ។ លក្ខខណ្ឌដែលសហព្រះរាជអាជ្ញាបានស្នើសុំ គឺការដាក់ជនជាប់ចោទឲ្យស្ថិតនៅក្រោមការត្រួតពិនិត្យរបស់តុលាការ ដោយយោងលើវិធាន៨២នៃវិធានផ្ទៃ

ក្នុងរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ។ លក្ខខណ្ឌទាំងនោះរួមមាន ៖

១) ស្ថិតនៅទីកន្លែងដែលមានអស័យដ្ឋានជាក់លាក់ ដែលត្រូវមានការជូនដំណឹងមកអង្គជំនុំជម្រះ ២) មានការពិនិត្យពីសុវត្ថភាពដោយអាជ្ញាធរ ឬមន្ត្រីណាមួយដែលតុលាការចាត់តាំង ៣) ប្រគល់លិខិតឆ្លងដែន និងអត្តសញ្ញាណប័ណ្ណមកតុលាការ ៤) មិនឲ្យមានការទាក់ទងដោយផ្ទាល់ ឬប្រយោលជាមួយជនជាប់ចោទផ្សេងទៀត លើកលែងតែជន ជាប់ចោទ អៀង សារី ប៉ុណ្ណោះ ៥) មិនឲ្យទាក់ទងផ្ទាល់ ឬប្រយោលជាមួយសាក្សី ឬជនរងគ្រោះដែលត្រូវមកធ្វើសក្ខីកម្ម មិនឲ្យរំខានដល់ដំណើរការរបស់តុលាការ ៦) ឲ្យមានការពិនិត្យព្យាបាលជនជាប់ចោទរាល់៦ខែម្តង ដើម្បីឲ្យតុលាការអាចតាមដានពីស្ថានភាពចុះខ្សោយនៃសុខភាពរបស់ជនជាប់ចោទ ។

**៤.ខ) សេចក្តីសន្និដ្ឋានរបស់មេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី**

មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីជាតិគឺលោក ពេជ អង្គ បានស្នើសុំឲ្យអង្គជំនុំជម្រះបន្តឃុំខ្លួនជនជាប់ចោទ ដោយមានការតែងតាំងអ្នកជំនាញថ្មីដើម្បីធ្វើការតាមដានស្ថានភាពបញ្ញាស្មារតីរបស់ជនជាប់ចោទ អៀង ធីរិទ្ធ បន្តទៀត ។ បន្ថែមពីលើនេះលោកស្រីសហមេធាវីនាំមុខអន្តរជាតិតំណាង ដើមបណ្តឹងរដ្ឋប្បវេណី អេលីហ្សាប៊ែត ស៊ីម៉ុនណូហ្វគ បានស្នើសុំឲ្យតុលាការផ្តល់ហេតុផលឲ្យបានលម្អិត និងយោងលើមូលដ្ឋានច្បាប់ត្រឹមត្រូវប្រសិនបើតុលាការធ្វើការដោះលែងជនជាប់ចោទ ។

**៤.គ) សេចក្តីសន្និដ្ឋានរបស់ក្រុមមេធាវីការពារក្តី អៀង ធីរិទ្ធ**

ក្រុមមេធាវីការពារក្តីជនជាប់ចោទ អៀង ធីរិទ្ធ បានស្នើសុំឲ្យអង្គជំនុំជម្រះសម្រេចដោះលែងជនជាប់ចោទ អៀង ធីរិទ្ធ ដោយឥតលក្ខខណ្ឌ ។ លោកមេធាវីជាតិ ផាត់ ពៅស៊ាង បានបដិសេធចំពោះការលើកឡើងរបស់វេជ្ជបណ្ឌិត ចក់ ធីតា ដែលអះអាងថា អៀង ធីរិទ្ធ មិនមានបញ្ហាសតិបញ្ញាស្មារតីធ្ងន់ធ្ងរ ។ លោកមេធាវីបានបញ្ជាក់ថា ការពិនិត្យរបស់វេជ្ជបណ្ឌិត ចក់ ធីតា មានការខ្វះខាត ដោយសារតែលោកស្រីវេជ្ជបណ្ឌិតបានផ្អែកលើរបាយការណ៍របស់គិលានុបដ្ឋាក ដែលពុំមានទិន្នន័យច្បាស់លាស់ក្នុងការវាយតម្លៃអំពីស្ថានភាពរស់នៅរបស់ អៀង ធីរិទ្ធ ។ លោកមេធាវីបានបន្តធ្វើការច្រានចោល ការតម្រូវឲ្យមានការពិនិត្យពីពេទ្យជាស្ត្រី និងថាការលើកឡើងដូច្នេះ គឺពុំមានលក្ខណៈសមហេតុផលឡើយ ។ លោកមេធាវី ពៅស៊ាង ក៏បានអះអាងដែរថា ការពិនិត្យរបស់អ្នកជំនាញទាំងបីរូប គឺជារបាយការណ៍ដែលមានការទទួលស្គាល់ពីអង្គការសុខភាពពិភពលោក ។ ចំណែកឯ


ទិដ្ឋភាពខាងក្នុងមន្ទីរឃុំឃាំងនៃអង្គជំនុំជម្រះវិសាមញ

លោកស្រី មេធាវីអន្តរជាតិ ដាយអាណា អេលីស បានបន្ថែមដោយលើកយកលទ្ធផលនៃការពិនិត្យរបស់អ្នកជំនាញទាំងបី ដែលបង្ហាញថាជនជាប់ចោទ អៀង ធីរិទ្ធ មានជំងឺភ្លេចភ្លាំង និងថាកោសិកាខួរក្បាលរបស់ជនជាប់ចោទបានស្លាប់បាត់បង់ទៅហើយ ដែលមិនអាចដុះឡើងវិញបានទេ ។ សំខាន់ជាងនេះទៀត គឺមិនមានថ្នាំណាដែលអាចព្យាបាលជនជាប់ចោទបានឡើយ ។

### ៥) សេចក្ដីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងលើសម្បទាជនជាប់ចោទ អៀង ធីរិទ្ធ

រយៈពេល២សប្ដាហ៍បន្ទាប់ពីសវនាការវាយតម្លៃសមត្ថភាពបញ្ញា ស្មារតី របស់ជនជាប់ចោទ អៀង ធីរិទ្ធ នៅថ្ងៃទី១៣ ខែកញ្ញា ឆ្នាំ២០១២ អង្គជំនុំជម្រះសាលាដំបូងនៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាបានចេញសេចក្ដីសម្រេចដោះលែងជនជាប់ចោទ


...ញ្ញក្នុងតុលាការកម្ពុជា (ប្រភពរូបថត ៖ អ.វ.ត.ក)

អៀង ធីរិទ្ធ ឲ្យនៅក្រៅឃុំ និងផ្អាករាល់កិច្ចដំណើរការនីតិវិធីប្រឆាំងនឹងជនជាប់ចោទក្នុងសំណុំរឿង០០២ ដោយមិនកំណត់រយៈពេល ។ ការចេញសេចក្ដីសម្រេចដូច្នេះ ដោយសារតែអង្គជំនុំជម្រះបានរកឃើញថា ជនជាប់ចោទ អៀង ធីរិទ្ធ ពុំមានសម្បទាខាងបញ្ញាស្មារតីគ្រប់គ្រាន់ក្នុងការចូលរួមការជំនុំជម្រះក្ដី ។ ប៉ុន្តែអង្គជំនុំជម្រះនឹងរៀបចំការពិគ្រោះយោបល់ជាមួយអ្នកជំនាញជារៀងរាល់ឆ្នាំ ចាប់ពីខែមិនា ឆ្នាំ២០១៣ ក្នុងរយៈពេលអត្ថិភាពរបស់តុលាការ ដើម្បីធ្វើការតាមដានសុខភាពបញ្ញាស្មារតីរបស់ អៀង ធីរិទ្ធ ក្នុងគោលបំណងបញ្ជាក់ពីជម្រើសនៃការព្យាបាលជនជាប់ចោទបន្តទៀត ។ នៅក្នុងសេចក្ដីសម្រេចនោះទៀតសោតអង្គជំនុំជម្រះបានកំណត់នូវលក្ខខណ្ឌចំនួនពីរ ៖

ទី១) មិនឲ្យជនជាប់ចោទធ្វើការជ្រៀតជ្រែកដល់សាក្សីអ្នកជំនាញ ឬជនរងគ្រោះ នៅចំពោះមុខអង្គជំនុំជម្រះ និងជនជាប់ចោទដទៃទៀត លើកលែងតែជនជាប់ចោទ អៀង សារី ដែលជាស្វាមី ។ ទី២) មិនអនុញ្ញាតឲ្យជនជាប់ចោទជួបជាមួយប្រព័ន្ធសារព័ត៌មានដែលពាក់ព័ន្ធនឹងកិច្ចដំណើរការនីតិវិធីរបស់តុលាការ ។

ប៉ុន្តែនៅថ្ងៃទី១៤ ខែកញ្ញា ឆ្នាំ២០១២ គឺមួយថ្ងៃបន្ទាប់ពីអង្គជំនុំជម្រះសាលាដំបូងចេញសេចក្ដីសម្រេចដោះលែងជនជាប់ចោទ អៀង ធីរិទ្ធ សហព្រះរាជអាជ្ញាបានដាក់សំណើជូនប្រធានអង្គជំនុំជម្រះតុលាការកំពូលសុំផ្អាកដីកាបង្គាប់ឲ្យដោះលែង និងបានដាក់បណ្ដឹងសាទុក្ខប្រឆាំងនឹងសេចក្ដីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូង ។ នៅក្នុងបណ្ដឹងសាទុក្ខដែលបានដាក់នៅថ្ងៃទី២៨ ខែកញ្ញា ឆ្នាំ២០១២ សហព្រះរាជអាជ្ញាបានស្នើសុំអង្គជំនុំជម្រះតុលាការកំពូលមោឃសេចក្ដីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូង និងស្នើឲ្យតុលាការកំពូលបន្ថែមលក្ខខណ្ឌចំពោះការដោះលែងជនជាប់ចោទ អៀង ធីរិទ្ធ ។

លក្ខខណ្ឌបន្ថែមដែលសហព្រះរាជអាជ្ញាបានស្នើសុំរួមមាន៖

១) ស្ថិតនៅទីកន្លែងដែលមានអស័យដ្ឋានជាក់លាក់ ដែលត្រូវមានការជូនដំណឹងមកអង្គជំនុំជម្រះ ២) មានការពិនិត្យពីសុវត្ថភាពដោយអាជ្ញាធរ ឬមន្ត្រីណាមួយដែលតុលាការចាត់តាំង ៣) ប្រគល់លិខិតឆ្លងដែន និងអត្តសញ្ញាណប័ណ្ណមកតុលាការ ៤) មិនឲ្យមានការទាក់ទងដោយផ្ទាល់ ឬប្រយោលជាមួយជនជាប់ចោទផ្សេងទៀត លើកលែងតែជនជាប់ចោទ អៀង សារី ប៉ុណ្ណោះ ៥) មិនឲ្យទាក់ទងផ្ទាល់ ឬប្រយោលជាមួយសាក្សី ឬជនរងគ្រោះដែលត្រូវមកធ្វើសក្ខីកម្មមិនឲ្យរំខានដល់ដំណើរការរបស់តុលាការ ៦) ឲ្យមានការពិនិត្យព្យាបាលជនជាប់ចោទរាល់៦ខែម្ដងដើម្បីឲ្យតុលាការអាចតាមដានពីស្ថានភាពចុះខ្សោយនៃសុខភាពរបស់ជនជាប់ចោទ ។

# សវនាការស្តីអំពីលក្ខខណ្ឌចំពោះការដោះលែងជនជាប់ចោទ អៀង ធីរិទ្ធ

## ថ្ងៃទី១៣ ខែវិច្ឆិកា ឆ្នាំ២០១២

ឆាយ ឈុនលី និង ឌី សុជាតា

### សេចក្តីផ្តើម

នៅថ្ងៃទី១៣ ខែវិច្ឆិកា ឆ្នាំ២០១២ អង្គជំនុំជម្រះតុលាការកំពូលនៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាបានប្រកាសបើកសវនាការស្តីពីការដាក់លក្ខខណ្ឌចំពោះការដោះលែងជនជាប់ចោទ អៀង ធីរិទ្ធ ដែលត្រូវបានអង្គជំនុំជម្រះសាលាដំបូងសម្រេចដោះលែងកាលពីថ្ងៃទី១៦ ខែកញ្ញា ឆ្នាំ២០១២ កន្លងទៅ ។ នៅក្នុងសវនាការនេះ ជនជាប់ចោទ អៀង ធីរិទ្ធ ត្រូវបានអង្គជំនុំជម្រះតុលាការកំពូលកោះហៅឲ្យចូលខ្លួនក្នុងសវនាការ ដែលជាការបង្ហាញខ្លួនជាលើកដំបូង បន្ទាប់ពីអវត្តមានពីសវនាការអស់រយៈពេលជាង១ឆ្នាំ ដោយសារបញ្ហាសម្បទា បញ្ហា ស្មារតី ឬជំងឺវង្វេងវង្វាន់ ។ នៅអំឡុងពេលនៃសវនាការនោះ ក៏មានវត្តមានលោកស្រី អៀង វិជិដា ដែលត្រូវជាកូនស្រីបង្កើតរបស់ជនជាប់ចោទ អៀង ធីរិទ្ធ ដែរ ។ អៀង វិជិដា ត្រូវបានសាលាដំបូងរាជធានីភ្នំពេញចាត់តាំងឲ្យធ្វើជាអាណាព្យាបាលទូទៅរបស់ជនជាប់ចោទ អៀង ធីរិទ្ធ បន្ទាប់ពីជនជាប់ចោទរូបនេះត្រូវបានដោះលែងឲ្យស្ថិតនៅក្រៅឃុំ ។

ជាកិច្ចចាប់ផ្តើមលោកប្រធានអង្គជំនុំជម្រះតុលាការកំពូលចៅក្រម គង់ ស្រ៊ឹម បានប្រកាស អំពីសមាសភាពនៃអង្គជំនុំជម្រះនិងវិសាលភាពនៃសវនាការដែលផ្តោតលើលក្ខខណ្ឌ ដែលត្រូវកំណត់ក្នុងការដោះលែងជនជាប់ចោទដោយសារបញ្ហាសុខភាពផ្នែកបញ្ញាស្មារតី ។

បន្ទាប់មកលោកប្រធានអង្គជំនុំជម្រះបានផ្ទេរវេទិកាជូនសហព្រះរាជអាជ្ញាដើម្បីធ្វើសារណាផ្ទាល់មាត់លើបណ្តឹងសាទុក្ខរបស់ខ្លួន ។ ប៉ុន្តែភ្លាមៗនោះ មេធាវីអន្តរជាតិការពារក្តីជនជាប់ចោទ អៀង ធីរិទ្ធ គឺលោកស្រី ដាយអាណា អេលីស បានស្នើសុំឲ្យអង្គជំនុំជម្រះធ្វើការសាកសួរជនជាប់ចោទ ជាមុនសិន ដោយហេតុថា ជនជាប់ចោទមិនអាចអង្គុយនៅក្នុងបន្ទប់សវនាការក្នុងរយៈពេលយូរបានទេ ។ ឆ្លើយតបនឹងសំណើនេះ ប្រធានអង្គជំនុំជម្រះ គង់ ស្រ៊ឹម បានបង្គាប់ឲ្យសន្តិសុខសម្រួលដល់ជនជាប់ចោទ អៀង ធីរិទ្ធ ឲ្យបានសម្រាកនៅបន្ទប់ជាន់ក្រោម



សាលសវនាការនៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា (ប្រភពរូបថត : អ.វ.ត.ក)

ដែលរៀបចំឲ្យជនជាប់ចោទតាមដានសវនាការពីចម្ងាយ ។

### ១) សេចក្ដីសន្និដ្ឋានរបស់សហព្រះរាជអាជ្ញាទាក់ទងនឹងលក្ខខណ្ឌចំពោះការដោះលែង អៀង ធីរិទ្ធ

តំណាងសហព្រះរាជអាជ្ញាជាតិ សុង ឆវិន្ត បានធ្វើសេចក្ដីសន្និដ្ឋានទាក់ទងនឹងលក្ខខណ្ឌរបស់អង្គជំនុំជម្រះសាលាដំបូងដែលបានសម្រេចដោះលែងជនជាប់ចោទ អៀង ធីរិទ្ធ ដោយផ្ដោតសំខាន់លើអំណះអំណាងចំនួនពីរចំណុចរបស់អង្គជំនុំជម្រះសាលាដំបូង ។

ទី១) ការរកឃើញរបស់អង្គជំនុំជម្រះដែលប៉ះពាល់ដល់បញ្ហាផ្សេងៗ ទី២) លក្ខខណ្ឌទាំង៦ចំណុចរបស់សហព្រះរាជអាជ្ញាដែលអង្គជំនុំជម្រះសាលាដំបូងបានបដិសេធ ទី៣) ការរកឃើញរបស់អង្គជំនុំជម្រះដែលអះអាងថា លក្ខខណ្ឌទាំងនោះមិនអាចអនុវត្តបាន ។

#### ក) ការរកឃើញរបស់អង្គជំនុំជម្រះសាលាដំបូង

តំណាងសហព្រះរាជអាជ្ញាជាតិ ឆវិន្ត ត្រូវបានអង្គជំនុំជម្រះតុលាការកំពូលផ្ដល់វេទិកាដើម្បីលើកឡើងអំពីការជំទាស់របស់ខ្លួនចំពោះសេចក្ដីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូង ។ តំណាងសហព្រះរាជអាជ្ញាជាតិ បានលើកឡើងអំពីការរកឃើញរបស់អង្គជំនុំជម្រះសាលាដំបូងនៅត្រង់កថាខណ្ឌ២៨ នៃសេចក្ដីសម្រេចរបស់ខ្លួនស្ដីពីការដោះលែងជនជាប់ចោទ អៀង ធីរិទ្ធ ។ នៅត្រង់កថាខណ្ឌ២៨នោះបានបញ្ជាក់ថា អៀង ធីរិទ្ធ មានបញ្ហាស្មារតីដែលនាំឲ្យមានការបាត់បង់ការចងចាំក្នុងរយៈពេលខ្លី និងរយៈពេលវែង ហើយមិនអាចមានលទ្ធភាពចូលរួមការជំនុំជម្រះបានទោះបីជាមានការស្វែងរកគ្រប់វិធានការយ៉ាងណាក៏ដោយ ។ តំណាងសហព្រះរាជអាជ្ញាបានបន្តទៀតថា ទោះបីជាយ៉ាងណាក៏ដោយអង្គជំនុំជម្រះសាលាដំបូង មិនបានរកឃើញថាជនជាប់ចោទមិនមានលទ្ធភាពទាក់ទងជាមួយអ្នកនៅជុំវិញខ្លួននោះឡើយ ។ ចំពោះការវិវត្តនៃជំងឺរបស់ អៀង ធីរិទ្ធ គឺមិនមានសញ្ញាណាមួយដែលអាចបញ្ជាក់ថា ជំងឺនេះនឹងអាចប្រសើរឡើងបានឡើយ ។ ហេតុដូច្នេះហើយទើបអង្គជំនុំជម្រះសាលាដំបូង សម្រេចផ្អាកកិច្ចដំណើរការនីតិវិធីប្រឆាំងជនជាប់ចោទដោយគ្មានពេលវេលាកំណត់ ប៉ុន្តែលទ្ធភាពនៃការជំនុំជម្រះប្រឆាំងជនជាប់ចោទ អៀង ធីរិទ្ធ នៅតែអាចកើតមាន ។ អង្គជំនុំជម្រះសាលាដំបូងក៏បានសម្រេចឲ្យមានការតាមដានពិនិត្យសុខភាពជនជាប់ចោទជារៀងរាល់ឆ្នាំ ដើម្បីស្វែងរកការព្យាបាលតាមវិធីថ្មីៗដែលអាចឲ្យជនជាប់ចោទមានសុខភាពបញ្ញាស្មារតីប្រសើរឡើងវិញ និងអាចចូលរួមសវនាការបាន ដូចមាននៅក្នុងកថាខណ្ឌ៣៩ នៃសេចក្ដីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូង ។

ដោយសារហេតុផលទាំងនេះ តំណាងសហព្រះរាជអាជ្ញាជាតិ សុង ឆវិន្ត បានអះអាងថា អង្គជំនុំជម្រះបានទទួលយកការសន្និដ្ឋានរបស់ខ្លួនដែលថា ទោះបីជាស្ថានភាពជំងឺរបស់ អៀង ធីរិទ្ធ ទំនងជាមិនមានភាពប្រសើរឡើងច្រើនក៏ដោយ ប៉ុន្តែការតាមដានសុខភាពនេះនៅតែត្រូវបានបន្ត ។ ដូច្នេះលទ្ធភាពនៃភាពប្រសើរឡើងនៃបញ្ញាស្មារតីរបស់ អៀង ធីរិទ្ធ នៅតែកើតមានដែលអាចឲ្យដំណើរការជំនុំជម្រះក្ដីប្រឆាំងនឹងជនជាប់ចោទមិនអាចត្រូវបានបញ្ចប់ ។

#### ខ) លក្ខខណ្ឌទាំង៦ដែលអង្គជំនុំជម្រះសាលាដំបូងបដិសេធ

ទាក់ទងនឹងការស្នើឲ្យមានការដាក់លក្ខខណ្ឌលើសេចក្ដីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូង តំណាងសហព្រះរាជអាជ្ញាជាតិរូបនេះបានលើកឡើងថា អង្គជំនុំជម្រះមានកាតព្វកិច្ចថ្លឹងថ្លែងពីសិទ្ធិ និងផលប្រយោជន៍ដែលពាក់ព័ន្ធមុននឹងធ្វើការសម្រេចពីការដាក់លក្ខខណ្ឌ ។ ប៉ុន្តែអង្គជំនុំជម្រះបែរជាអះអាងថាខ្លួនមិនមានលទ្ធភាពផ្លូវច្បាប់ក្នុងការដាក់លក្ខខណ្ឌដែលមានកម្រិតក្នុងការអនុវត្តទៅវិញ ។ ជាងនេះទៀត តំណាងសហព្រះរាជអាជ្ញាជាតិបានបញ្ជាក់ថា អង្គជំនុំជម្រះសាលាដំបូងមានកំហុសក្នុងការបកស្រាយនូវយុត្តិសាស្ត្រអន្តរជាតិ ដែលប្រើប្រាស់នៅអង្គជំនុំជម្រះសាលាដំបូងនៃតុលាការព្រហ្មទណ្ឌអន្តរជាតិ សម្រាប់អតីតប្រទេសយូហ្គោស្លាវី (I.C.T.Y) នៅក្នុងរឿងក្ដី *ថាលិក (Talic)*, *ដូគិក (Djukic)* និង សេចក្ដីសម្រេចរបស់គណៈកម្មការពិសេសនៅប្រទេសទីម័រ សម្រាប់បទល្មើសធ្ងន់ធ្ងរក្នុងរឿងក្ដី *ណាហាក់* លើភាពខុសគ្នាជាមួយករណី អៀង ធីរិទ្ធ ។ តំណាងសហព្រះរាជអាជ្ញា ឆវិន្ត បានបន្តថា នៅក្នុងរឿងក្ដី *ថាលិក* និង *ដូគិក* គឺជនជាប់ចោទទាំងពីរមានជំងឺដែលមិនអាចព្យាបាលបាន ហើយត្រូវបានដោះលែងខណៈពេលដែលកិច្ចដំណើរការនីតិវិធីរបស់អ្នកទាំងពីរត្រូវ

បានផ្អាក ដោយសារតែស្ថានភាពជំងឺរបស់អ្នកទាំងពីរមិនអាចព្យាបាលបានស្ទើរតែទាំងស្រុង ។ ប៉ុន្តែទោះបីជាយ៉ាងណាក៏ដោយ ការដោះលែងនេះនៅតែត្រូវបានកំណត់នូវលក្ខខណ្ឌមួយចំនួនដោយតុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវី ។

តំណាងសហព្រះរាជអាជ្ញាជាតិបានបន្តលើកឡើងពីភាពខុសគ្នារវាងរឿងក្តី ថាលិក និងជនជាប់ចោទ អៀង ធីរិទ្ធ លើចំណុចចំនួន៣ ៖

ទី១) ទាក់ទងនឹងសម្បទារបស់ជនជាប់ចោទក្នុងការចូលរួមសវនាការក្នុងរយៈពេលខ្លី ។

ទី២) ភាពខុសគ្នារវាងគំនិតយោបល់ដែលមិនទាក់ទងគ្នា ដោយសារសម្បទាចូលរួមសវនាការត្រូវបានកំណត់ដោយតុលាការ មិនមែនកំណត់ដោយអ្នកជំនាញទេ ។

ទី៣) គ្រប់អ្នកជំនាញទាំងអស់បានទទួលស្គាល់ថា ថាលិក មានជំងឺមហារីកដែលមិនអាចព្យាបាលជាបាន ហើយនឹងអាចស្លាប់មុនពេលសវនាការ ។

មូលដ្ឋានមួយទៀតដែលបញ្ជាក់ពីភាពខុសគ្នានេះ គឺនៅត្រង់ថា តុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវី (I.C.T.Y) បានបដិសេធមិនធ្វើការកំណត់ចុងក្រោយស្តីអំពីសម្បទា ដោយសារតែមិនមានពាក្យសុំឲ្យសម្រេចអំពីសម្បទានៅចំពោះមុខតុលាការ ដើម្បីសម្រេចលើបញ្ហាសម្បទានោះ ។ បន្ថែមពីលើនេះទៀត តំណាងសហព្រះរាជអាជ្ញាជាតិបានបដិសេធការយល់ឃើញរបស់អង្គជំនុំជម្រះសាលាដំបូង និងក្រុមមេធាវីការពារក្តីថារឿងក្តី ថាលិក មានការយោងនៅក្នុងសេចក្តីសម្រេចរបស់តុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវី (I.C.T.Y) ជាមួយនឹងសវនាការដែលកំពុងបន្តដំណើរការនៅឡើយ ។ តំណាងសហព្រះរាជអាជ្ញា ឆវីន្ត បានបង្ហាញនូវអង្គហេតុថា ថាលិក ត្រូវបានចោទប្រកាន់ជាមួយជនជាប់ចោទផ្សេងទៀតឈ្មោះ ប៉ែនដឺមីន ប៉ុន្តែ ដោយសារបញ្ហាសុខភាពតុលាការបានបំបែកសំណុំរឿង ។ ក្រោយមករឿងក្តី ថាលិក មិនដែលត្រូវបានកាត់ទោសទៀតទេ ។ ក្នុងចំណុចនេះ តំណាងសហព្រះរាជអាជ្ញានៅតែរក្សាជំហររបស់ខ្លួនថា នៅក្នុងរឿងក្តី ថាលិក ពិតជាមានកំណត់រយៈពេលដែលជនជាប់ចោទអាចមានជីវិត តែក្នុងរយៈពេលមួយឆ្នាំ ប៉ុណ្ណោះក្រោយពេលមានសវនាការ ។ ធាតុពិតជនជាប់ចោទបានស្លាប់ក្នុងរយៈពេល៩ខែ បន្ទាប់ពីដោះលែងដែលផ្ទុយស្រឡះនឹងរឿងក្តីរបស់ជនជាប់ចោទ អៀង ធីរិទ្ធ ដែលមិនមានការកំណត់រយៈពេលណាមួយ ហើយសុខភាពផ្លូវកាយរបស់ជនជាប់ចោទ អៀង ធីរិទ្ធ គឺមានលក្ខណៈល្អប្រសើរ ។ ដូច្នេះឱកាសក្នុងការចូលរួមសវនាការរបស់ជនជាប់ចោទគឺនៅតែមាន ។ម្យ៉ាងវិញទៀត ទម្ងន់ទោសរបស់ជនជាប់ចោទ គឺធ្ងន់ធ្ងរជាង រឿងក្តីរបស់ ថាលិក ។ ចំពោះរឿងក្តី ដូគិកវិញ តំណាងសហព្រះរាជអាជ្ញាជាតិ ឆវីន្ត បានលើកឡើងថា ជនជាប់ចោទត្រូវបានធ្វើរោគវិនិច្ឆ័យមុនពេលសវនាការហើយ ជាលទ្ធផល ជនជាប់ចោទមានជំងឺដែលស្ថិតក្នុងដំណាក់កាលចុងក្រោយ ហើយមិនអាចព្យាបាលបាន ។ ជនជាប់ចោទបានស្លាប់ក្នុងរយៈពេលមួយខែក្រោយពីការដោះលែង មានន័យថា តុលា-ការបានដាក់លក្ខខណ្ឌយ៉ាងតឹងរឹងនៅក្នុងរឿងក្តីនេះ ។

ចំពោះរឿងក្តី ណាហាក ជនជាប់ចោទមានជំងឺវិកលចរិកអស់រយៈពេលជាយូរ ហើយសវនាការត្រូវបានផ្អាកក្នុងស្ថានភាពរឹតត្បិត ។ ម្យ៉ាងវិញទៀត លទ្ធភាពនៃការបន្តសវនាការមានតិចតួចបំផុត ប៉ុន្តែ មានភាពប្រែប្រួលអាស្រ័យលើកាលៈទេសៈនៃស្ថានភាពរបស់ជនជាប់ចោទ ។ ដោយផ្អែកទៅលើរឿងក្តីទាំងបីនេះ តំណាងសហព្រះរាជអាជ្ញាជាតិនៅតែរក្សាជំហររបស់ខ្លួនក្នុងការស្នើសុំឲ្យមានការដាក់វិធានការចំពោះជនជាប់ចោទ អៀង ធីរិទ្ធ ដែលត្រូវបានដោះលែង ខណៈពេលដែលលទ្ធភាពនៃការបន្តសវនាការនៅតែអាចមាននៅឡើយ ។

បន្ទាប់មក តំណាងសហព្រះរាជអាជ្ញាបានលើកឡើងនូវសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងដែលមានបង្កប់ន័យថា *«អង្គជំនុំជម្រះបានកំណត់ត្រឹមតែជនជាប់ចោទនឹងត្រូវបានកោះហៅមកចូលរួមសវនាការ ក្នុងករណីដែលមិនមានគម្រោងច្បាស់លាស់ថា ជនជាប់ចោទនឹងត្រូវបាននាំយកមកជំនុំជម្រះនៅពេលក្រោយ»* ។ ចំណែកឯកថាខណ្ឌ៣៣នៃសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូង ដែលយោងលើវិធាន ៦៣(៣)(ខ) ទាក់ទងនឹងការឃុំខ្លួនតំណាងសហព្រះរាជអាជ្ញាយល់ឃើញថាគឺជាការបកស្រាយដ៏ចង្អៀតរបស់អង្គជំនុំជម្រះសាលា

ដំបូង ដែលហាក់បីដូចជាកំពុងតែការពារនូវផលប្រយោជន៍របស់ជនជាប់ចោទ ។ ម្យ៉ាងវិញទៀត ការបន្ថែមលើលក្ខខណ្ឌមួយចំនួនទាក់ទងនឹងការអនុញ្ញាតឲ្យជនជាប់ចោទស្នាក់នៅក្នុងប្រទេសកម្ពុជា និងមានការជូនដំណឹងដល់តុលាការក្នុងករណីផ្លាស់ប្ដូរទីកន្លែង, មិនត្រូវជ្រៀតជ្រែកក្នុងកិច្ចការតុលាការនិងមិនឲ្យទាក់ទងជាមួយបណ្ដាញសារព័ត៌មានដែរទាក់ទងនឹងដំណើរការនីតិវិធី ។ លក្ខខណ្ឌទាំងនេះបានបំពេញនូវសំណើរបស់សហព្រះរាជអាជ្ញាដើម្បីរក្សាសន្តិសុខសាធារណៈ និងសុវត្ថិភាពជនជាប់ចោទ ។ ម្យ៉ាងវិញទៀត សេចក្ដីសន្និដ្ឋានតបរបស់មេធាវីការពារក្ដីក៏បានទទួលស្គាល់នូវវិធានការដើម្បីរក្សាសន្តិសុខរបស់ជនជាប់ចោទដែលនាំឲ្យមានការដាក់វិធានការស្ថិត ក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការ ។ តំណាងសហព្រះរាជអាជ្ញា ឆវិន្ទ បានបន្តលើកឡើងថា សំណើសុំទាំង៦ចំណុចដែលខ្លួនបានលើកឡើង គឺមិននាំឲ្យមានការរឹតត្បិតពេកលើសិទ្ធិរបស់ជនជាប់ចោទឡើយ ហើយក៏មិនមានវិធានការណ៍ណាមួយ ដែលត្រូវដាក់ឲ្យជនជាប់ចោទឲ្យស្ថិតនៅក្រោមការឃុំខ្លួនក្នុងលំនៅស្ថាន និងមិនមានការកំណត់លំនៅស្ថានដោយឡែកឡើយ គឺជនជាប់ចោទមានសិទ្ធិធ្វើដំណើរឲ្យតែស្ថិតនៅក្នុងប្រទេសកម្ពុជា ។

ចំពោះការពិនិត្យសុខភាព អៀង ធីរិទ្ធ ជាប្រចាំ ក៏មិនមានភាពខុសគ្នានឹងខចែងរបស់អង្គជំនុំជម្រះសាលាដំបូង លើការពិគ្រោះប្រចាំឆ្នាំជាមួយអ្នកជំនាញដែរ ។

ចំណែក៦សំណើសុំមិនឲ្យមានការទាក់ទងជាមួយជនជាប់ចោទផ្សេងទៀត (លើកលែងតែជនជាប់ ចោទ អៀង សារី) និងការទាក់ទងជាមួយសាក្សីផ្សេងទៀតនោះ គឺជាការធានាដល់សន្តិសុខដែលសមហេតុផលបំផុត និងដើម្បីធានាមិនឲ្យមានការរំខានដល់កិច្ចដំណើរការនីតិវិធី ។

ចំពោះការពិនិត្យរាល់៦ខែម្ដង និងការពិនិត្យលើករណីទាំងអស់នោះ គឺដើម្បីធានាថាជនជាប់ចោទ ស្ថិតនៅក្នុងស្ថានភាពជាក់លាក់មួយ ។ ដោយយោងលើការបកស្រាយខាងលើនេះ តំណាងសហព្រះរាជអាជ្ញាយល់ថា ការស្នើសុំរបស់ខ្លួន គឺជាការសមហេតុផល និងដើម្បីធានាថាជនជាប់ចោទត្រូវបានដាក់ឲ្យស្ថិតនៅក្នុងស្ថានភាពប្រាកដប្រជា ។

### ក) ការអនុវត្តវិធានការដែលស្នើដោយសហព្រះរាជ អាជ្ញា

ទាក់ទងនឹងការអនុវត្តវិធានការ ដែលអង្គជំនុំជម្រះសាលាដំបូងស្នើឲ្យសហព្រះរាជអាជ្ញាពន្យល់ថា តើវិធានការទាំងនោះអាចឲ្យជនជាប់ចោទរំលោភលើវិធានការ និងទោសពិន័យដែលយកមកប្រើប្រាស់ក្នុងករណីមានការរំលោភបំពានដែរឬទេ? តំណាងសហព្រះរាជអាជ្ញាជាតិ ឆវិន្ទ បានជូនសេចក្ដីសន្និដ្ឋានថា អង្គជំនុំជម្រះបានប្រព្រឹត្តកំហុសមួយទាក់ទងនឹងឆន្ទានុសិទ្ធិរបស់តុលាការ ដែលបានប្រើប្រាស់នៅក្នុងបញ្ហានេះ ។ ទោះបីជាជនជាប់ចោទត្រូវបានដាក់ទណ្ឌកម្មចំពោះការប្រព្រឹត្តដោយបំពានលើវិធានការទាំងនោះក៏ដោយ ក៏មិនមែនមានន័យថា វិធានការទាំងនោះមិនអាចដាក់ឲ្យអនុវត្តតាមបាននោះឡើយ ។ ម្យ៉ាងវិញទៀត មិនមានហេតុផលណាមួយដែលជនជាប់ចោទមិនអាចអនុវត្តនូវលក្ខខណ្ឌទាំងនោះ បើទោះបីជាជនជាប់ចោទមានបញ្ហាស្មារតីក៏ដោយ ។ បន្ថែមពីលើនេះ ជនជាប់ចោទក៏អាចអនុវត្តវិធានការតាមរយៈអាណាព្យាបាលរបស់ខ្លួនបានដែរ ។ ចំពោះទណ្ឌកម្មដែលយកមកអនុវត្តក្នុងករណីដែលជនជាប់ចោទមិនគោរពតាមការកំណត់របស់តុលាការនោះ តំណាងសហព្រះរាជអាជ្ញានឹងចង្អុលបង្ហាញនូវវិធាន៣៥ ដែលតម្រូវឲ្យមានការពិនិត្យលើឆន្ទៈក្នុងការបំពាននោះ ។ ទាក់ទងនឹងអាណាព្យាបាលទូទៅ តំណាងសហព្រះរាជអាជ្ញាបានលើកឡើងថា ការស្នើសុំរបស់លោកស្រី អៀង វិជីជា គឺធ្វើឡើងនៅចំពោះមុខតុលាការរាជធានីភ្នំពេញ ហើយនៅក្នុងករណីនេះលោកស្រី អៀង វិជីជា មានតួនាទីគោរពតាមវិធានរបស់តុលាការក្រុងភ្នំពេញ ។

តំណាងសហព្រះរាជអាជ្ញាបានបដិសេធនូវការលើកឡើងរបស់មេធាវីការពារក្ដីដែលអះអាងថា សហព្រះរាជអាជ្ញាបានស្នើសុំមិនឲ្យប្រើប្រាស់វិធានការរបស់តុលាការក្រុងភ្នំពេញ និងស្នើសុំឲ្យដាក់វិធានការតឹងរឹងតាមវិធីអាណាព្យាបាលទូទៅ ។ ជាងនេះទៅទៀត តំណាងសហព្រះរាជអាជ្ញាបានជំទាស់នឹងសំណើរបស់មេធាវីការពារជនជាប់ចោទ ដែលបានស្នើសុំឲ្យតុលាការកំពូលបដិសេធលើវិធានដែលបង្គាប់ដោយតុលាការរាជធានីភ្នំពេញ លើផ្នែកមួយនៃដីកាសម្រេចពាក់ព័ន្ធនឹងការតែងតាំងអាណាព្យាបាល ដោយអះអាងថា នេះមិនមែនជាសមត្ថកិច្ចរបស់

តុលាការនៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាឡើយ ។ ចំពោះការលើកឡើងរបស់មេធាវីការពារក្តីដែលថា ការដាក់ទណ្ឌកម្មលើអាណាព្យាបាល គឺមិនមានមូលដ្ឋានច្បាប់នោះ តំណាងសហព្រះរាជអាជ្ញាបានលើកឡើងថា ទោះបីជាមិនមានមូលដ្ឋានច្បាប់ ប៉ុន្តែអ្នកអាណាព្យាបាលត្រូវមានកាតព្វកិច្ចក្នុងការអនុវត្តរាល់វិធានដែលកំណត់ដោយតុលាការ ។

ចុងក្រោយ តំណាងសហព្រះរាជអាជ្ញានៅតែរក្សាជំហររបស់ខ្លួនក្នុងការស្នើសុំឲ្យតុលាការកំពូលបដិសេធលើវិធានការនៃសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូង លើការដោះលែងជនជាប់ចោទ ដោយរក្សានូវលក្ខខណ្ឌដែលខ្លួនបានស្នើកាលពីថ្ងៃទី៣១ ខែសីហា ដើម្បីជាប្រយោជន៍សាធារណៈ ។

### ២) សេចក្តីសន្និដ្ឋានរបស់មេធាវីការពារក្តីទាក់ទងនឹងលក្ខខណ្ឌចំពោះការដោះលែង អៀង ធីរិទ្ធ

បន្ទាប់ពីការធ្វើសេចក្តីសន្និដ្ឋានរបស់សហព្រះរាជអាជ្ញា ប្រធានអង្គជំនុំជម្រះតុលាការកំពូល ចៅក្រម គង់ ស្រីម បានផ្ទេរវេទិកាជូនក្រុមមេធាវីការពារក្តីជនជាប់ចោទ អៀង ធីរិទ្ធ ដើម្បីធ្វើសេចក្តីសន្និដ្ឋានតប ។ មេធាវីជាតិការពារក្តីជនជាប់ចោទ អៀង ធីរិទ្ធ គឺលោក ផាត់ ពៅស៊ាង បានចាប់ផ្តើមដោយស្នើឲ្យតុលាការកំពូលបដិសេធបណ្តឹងសាទុក្ខភ្លាមៗរបស់សហព្រះរាជអាជ្ញា និងបដិសេធសារណាបន្ថែមរបស់ព្រះរាជអាជ្ញា ដោយស្នើឲ្យអង្គជំនុំជម្រះតុលាការកំពូលតម្កល់ទុកនូវសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាការដំបូង ព្រមទាំងដកចេញនូវលក្ខខណ្ឌដែលដាក់ដោយតុលាការកំពូលក្នុងអំឡុងពេលរង់ចាំសវនាការនេះ ។ ទាក់ទងនឹងសំណើខាងលើមេធាវី ផាត់ ពៅស៊ាង បានផ្តល់នូវហេតុផលថា អង្គជំនុំជម្រះមិនមានកំហុសក្នុងការដោះលែងជនជាប់ចោទដោយគ្មានលក្ខខណ្ឌទេ ដោយសំអាងថា ការដាក់ឲ្យស្ថិតនៅក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការត្រូវអនុវត្តក្នុងករណី ដែលមានមូលដ្ឋានច្បាប់ត្រឹមត្រូវតែប៉ុណ្ណោះ ។ លោកមេធាវីបានស្នើឲ្យអង្គជំនុំជម្រះអនុវត្តនូវវិធានដែលបង្កើតឡើងដើម្បីធានាថា សិទ្ធិរបស់ចុងបណ្តឹងសាទុក្ខ (អៀង ធីរិទ្ធ) មិនត្រូវបានដាក់កំហិតដោយពុំមានមូលហេតុត្រឹមត្រូវ ។

បន្ទាប់មក លោកមេធាវីបានលើកឡើងពីស្ថានភាពកាន់តែធ្ងន់ធ្ងរនៃជំងឺរបស់ជនជាប់ចោទ អៀង ធីរិទ្ធ ដែលមិនអាចមានលទ្ធភាពចូលរួមសវនាការដោយអះអាងថា ជនជាប់ចោទ អៀង ធីរិទ្ធ មានជំងឺវង្វេងវង្វាន់មិនអាចមានលទ្ធភាពចូលរួមសវនាការ ។ បន្ថែមពីលើនេះ ទោះបីជា អៀង ធីរិទ្ធ ត្រូវបានទទួលការព្យាបាលតាមសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងក៏ដោយ មិនមានលទ្ធផលណាមួយដែលបង្ហាញថា ការចងចាំរបស់ជនជាប់ចោទរូបនេះបានធូរស្បើយជាងមុនដែរ ។ ផ្ទុយទៅវិញ ស្ថានភាពបញ្ញាស្មារតីរបស់ អៀង ធីរិទ្ធ មានសភាពកាន់តែធ្ងន់ធ្ងរឡើងៗ ។

លោកមេធាវី ពៅស៊ាង បានបន្តថា តំណាងសហព្រះរាជអាជ្ញាបានយល់ស្របថា ដោយសារបញ្ហាសុខភាពជនជាប់ចោទ អៀង ធីរិទ្ធ នឹងមិនអាចចូលរួមក្នុងកិច្ចដំណើរការនីតិវិធីបានទេ ហើយតាម រយៈការពិនិត្យរបស់អ្នកជំនាញលើបញ្ហាសុខភាពរបស់ អៀង ធីរិទ្ធ មិនបានបង្ហាញថានឹងមានសវនាការលើជនជាប់ចោទឡើយ ។ ម្យ៉ាងទៀត មិនមានវិធានការផ្លូវច្បាប់ ឬយុត្តិសាស្ត្រណាដែលបង្គាប់ឲ្យមានការរឹតត្បិតលើសិទ្ធិសេរីភាពរបស់ជនជាប់ចោទឡើយ ទោះបីវិធាន៦៥(១) បានកំណត់ពីលក្ខខណ្ឌដែលដាក់ក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការ ដើម្បីធានាវត្តមានរបស់ជនជាប់ចោទ និងដើម្បីការពារអ្នកដទៃក៏ដោយ ប៉ុន្តែករណីនេះមិនចាំបាច់ឡើយក្នុងករណី អៀង ធីរិទ្ធ ។ លោកមេធាវីបន្តលើកយកការបកស្រាយ របស់អង្គជំនុំជម្រះលើរឿងក្តីថាលិក មកធ្វើការបកស្រាយថា ក្នុងការស្នើសុំឲ្យមានការដោះលែងជាបណ្តោះអាសន្ន ដោយបញ្ជាក់ថាមូលហេតុនៃការសុំដោះលែង និងមូលហេតុដែលនាំឲ្យមានការឃុំខ្លួនក្នុងពន្ធនាគារ គឺជាការដាក់លក្ខខណ្ឌសន្មត់ថានឹងមានការជំនុំជម្រះក្តី ហើយជនជាប់ចោទនឹងខកខានមិនបានចូលរួមសវនាការ ។ ប៉ុន្តែក្នុងករណីដែលតំណាងសហព្រះរាជអាជ្ញាលើកឡើងពីភាពចាំបាច់នៃការឃុំខ្លួនជនជាប់ចោទ អៀង ធីរិទ្ធ នោះ គឺជាការរំលោភសិទ្ធិរបស់ជនជាប់ចោទ ដោយសារមិនមានមូលដ្ឋានផ្នែកច្បាប់ជាក់លាក់ ។

បន្ទាប់មក មេធាវីអន្តរជាតិការពារក្តីជនជាប់ចោទ អៀង ធីរិទ្ធ គឺលោកស្រី ដាយអាណា អេលីស បានបន្តពីសហភាគារបស់ខ្លួន ដោយបដិសេធការលើកឡើងរបស់តំណាងសហព្រះរាជអាជ្ញាដែលថា មេធាវីការពារក្តីស្នើសុំឲ្យតុលាការបដិសេធការ

សម្រេចអំពីអាណាព្យាបាលទូទៅ ។ បន្ទាប់មក មេធាវី អេលីស បានបន្តលើកឡើងអំពីលក្ខខណ្ឌដែលត្រូវបានដាក់ និងរបាយការណ៍របស់វេជ្ជបណ្ឌិត ដែលបញ្ជាក់ថាស្ថានភាពសុខភាពរបស់ អៀង ធីរិទ្ធ មិនអាចត្រឡប់មកល្អបានឡើយ ប្រសិនបើមិនមានយន្តការ ឬមធ្យោបាយណាមួយដើម្បីព្យាបាលជំងឺ ។ មេធាវី អេលីស បានបន្តលើកឡើងអំពីលក្ខខណ្ឌនៃការជូនដំណឹងពីអាសយដ្ឋានថា ហាក់បីដូចជាបង្ហាញថា មានការកាត់ទោសនៅពេលក្រោយ ហើយបញ្ហានេះមិនមានវិធានណាមួយដើម្បីដាក់លក្ខខណ្ឌ ហើយម្យ៉ាងទៀត ក្នុងករណីដែលមានការរំលោភលើកិច្ចការរដ្ឋបាលនោះ ជនជាប់ចោទគឺជាអ្នកទទួលខុសត្រូវដោយផ្ទាល់ ។ លោកស្រីមេធាវីបានបន្ថែមថា ដោយសារតែជនជាប់ចោទមិនអាចមានលទ្ធភាពចូលរួមសវនាការ ដូច្នេះការដាក់លក្ខខណ្ឌ គឺទាល់តែមានការបង្ហាញថាមានការបំពានពីជនជាប់ចោទដោយចេតនា ហើយក្នុងករណីដែលជនជាប់ចោទមិនយល់ដឹង និងមិនយល់អំពីលក្ខខណ្ឌទាំងឡាយ ដូច្នេះការដាក់លក្ខខណ្ឌ គឺជាការមាក់ងាយដល់ប្រព័ន្ធយុត្តិធម៌ទៅវិញ ។ ហេតុនេះក្នុងពេលដែលជនជាប់ចោទមិនទាន់ត្រូវបានរកឃើញថាមានទោស នោះសិទ្ធិរបស់ជនជាប់ចោទមិនអាចត្រូវរំលោភបំពានបានឡើយ ។

ទាក់ទងនឹងអាណាព្យាបាលវិញមេធាវី អេលីស បានលើកឡើងថា អាណាព្យាបាលមានសិទ្ធិអំណាចថែទាំ និងធានាការរក្សាផលប្រយោជន៍សាធារណៈជំនួសឲ្យជនជាប់ចោទដែលមិនមានការយល់ដឹង ប៉ុន្តែអ្នកអាណាព្យាបាលមិនមានកាតព្វកិច្ចធានាឲ្យបុគ្គលអនុវត្តវិធានការដោយបង្ខំនោះឡើយ ដោយយោងលើមាត្រា២៨ នៃក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ ២០០៧ ។ បន្ថែមពីលើនេះ មេធាវី អេលីស បានលើកឡើងទាក់ទងនឹងការស្នើសុំឲ្យមានការជ្រើសតាំងអាណាព្យាបាល ដោយអះអាងថា សហព្រះរាជអាជ្ញារងជាតិ យ៉ែត ចរិយា បានស្នើសុំឲ្យមានការតែងតាំងលោកស្រី អៀង វិជិដា ធ្វើជាអាណាព្យាបាលខណៈពេលដែលខ្លួនគ្រាន់តែស្នើសុំមើលថែម្តាយតែប៉ុណ្ណោះ ។



ជនជាប់ចោទ អៀង ធីរិទ្ធ អមដោយកូនស្រី អៀង វិជិដា (រូបស្តាំ) អង្គុយក្រោយមេធាវីការពារក្តីរបស់ខ្លួន (ប្រភពរូបថត ៖ អ.វ.ត.ក)

ចំពោះរឿងក្តីទាំងបីដែលតំណាងសហព្រះរាជអាជ្ញាបានលើកឡើងនោះមិនមានចែងនៅក្នុងយុត្តិសាស្ត្រអន្តរជាតិឡើយ ហើយមិនមានភាពស៊ីសង្វាក់នឹងករណីជាក់ស្តែង ដោយសាររឿងក្តីទាំងនោះមិនបានលើកឡើងពីសម្បទាក្នុងការចូលរួមសវនាការ ។ ម្យ៉ាងទៀត រឿងក្តីទាំងនោះ គឺមានអង្គហេតុផ្សេងៗគ្នា ដូច្នេះ មេធាវី អេលីស នៅតែរក្សាជំហររបស់ខ្លួនថា ការដាក់លក្ខខណ្ឌចំពោះបុគ្គលដែលមិនមានការយល់ដឹង គឺជាការមិនត្រឹមត្រូវ

ហើយខ្លួនស្នើសុំឲ្យតុលាការកំពូលតម្កល់សេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូង ។

បន្ទាប់ពីក្រុមមេធាវីការពារក្តី អៀង ធីរិទ្ធ បានបញ្ចប់ការធ្វើសេចក្តីសន្និដ្ឋានរបស់ខ្លួន ប្រធានអង្គជំនុំជម្រះតុលាការកំពូល ចៅក្រម គង់ ស្រ៊ឹម បានបង្គាប់ឲ្យអនុរក្សពន្ធនាគារនាំជនជាប់ចោទមកបន្ទប់សវនាការដើម្បីធ្វើការសាកសួរ ។ ប៉ុន្តែដោយសារស្ថានភាពសុខភាពរបស់ អៀង ធីរិទ្ធ មិនអំណោយផល ចៅក្រម គង់ ស្រ៊ឹម បានអនុញ្ញាតឲ្យជនជាប់ចោទអង្គុយនៅក្នុងកៅអីធម្មតារបស់ខ្លួន ដោយមិនចាំបាច់អង្គុយក្នុងកៅអីរាងក្រចកសេះទេ និងថា អៀង ធីរិទ្ធ អាចទៅសម្រាកបានក្នុងករណីចាំបាច់ ។

**៣) ការសាកសួរជនជាប់ចោទ អៀង ធីរិទ្ធិ និងអាណាព្យាបាលដោយអង្គជំនុំជម្រះតុលាការកំពូល**

ជាដំបូងប្រធានអង្គជំនុំជម្រះតុលាការកំពូល ចៅក្រម គង់ ស្រ៊ឹម បានសាកសួរអំពីសុខទុក្ខរបស់ជនជាប់ចោទ ដោយចោទសួរថា តើលោកស្រីសុខសប្បាយជាទេ? ជនជាប់ចោទ អៀង


ប្រធានអង្គជំនុំជម្រះតុលាការកំពូល គង់ ស្រ៊ឹម
(ប្រភព ៖ មជ្ឈមណ្ឌលឯកសារកម្ពុជា)

ធីរិទ្ធ បានឆ្លើយតបនឹងសំណួរនេះថា "ខ្ញុំអត់អីទេ ។ ខ្ញុំសុខសប្បាយជាទេចាស៎" ។ បន្ទាប់មកលោកប្រធានបានបន្តសួរទាក់ទងនឹងបញ្ហាសុខភាព ហើយជនជាប់ចោទ អៀង ធីរិទ្ធ បានឆ្លើយថា "ល្អជាងមុន ។ ព្រោះអ្នកដែលទទួលខ្ញុំហ្នឹង គេជាម្ចាស់ផ្ទះផង គេម្ចាស់ទឹកដីផង ឲ្យខ្ញុំនៅឲ្យបានសុខស្រួលឲ្យឆាប់ជា ។ ចាស៎ ដូច្នេះគាត់ជួយ ។ គាត់ជួយច្រើន ព្រោះគេមើលឃើញយើងត្រូវការថ្នាំអីៗហ្នឹងគេរកគ្រូមកឲ្យបានធ្វើឲ្យខ្ញុំឆាប់ជាគ្រាន់បើឥឡូវហ្នឹង" ។

បន្ទាប់មកលោកប្រធានអង្គជំនុំជម្រះបានផ្ទេរវេទិកាជូនចៅក្រមអន្តរជាតិ ហ្វូរេន មុមបា ដើម្បីសាកសួរបន្ត ។ ចៅក្រម មុមបា បានចាប់ផ្តើមដោយសាកសួរថា តើលោកនឹងព្រមមកតុលាការទេក្នុងករណីដែលតុលាការស្នើឲ្យជនជាប់ចោទត្រលប់មកតុលាការវិញនោះ? ជនជាប់ចោទ អៀង ធីរិទ្ធ មិនបានឆ្លើយតបត្រូវនឹងសំណួរឡើយ ប៉ុន្តែបែរជាឆ្លើយថា សភាពការរស់នៅរបស់ខ្លួនមួយរយៈពេលនេះ គឺមានជំងឺញឹកញាប់ ដូច្នេះខ្លួនមិនបានរស់នៅក្នុងព្រៃទេ ហើយជំងឺក៏មិនជាដែរ ។ ឆ្លើយតបនឹងសំណួរដែលទាក់ទងនឹងអាសយដ្ឋានអចិន្ត្រៃយ៍នៅទីក្រុងភ្នំពេញវិញ អៀង ធីរិទ្ធ បានឆ្លើយថា "នៅភ្នំពេញមាន ហើយនៅកន្លែងថ្មីនេះដែលគេថា កន្លែងដែលគេថាកន្លែងដែលគេជួយព្យាបាលពួកខ្ញុំបាននោះ ខ្ញុំក៏បានមកៗតាមនឹងដែរ ។ មកតាមហ្នឹងក៏តាំងពីស្តេចគេ


អៀង ធីរិទ្ធ កំពុងឆ្លើយតបសំណួររបស់ចៅក្រម
(ប្រភព ៖ មជ្ឈមណ្ឌលឯកសារកម្ពុជា)

តាំងពីអីគេ គេមកទទួលស្គាល់ជួយមើល ។ ខ្ញុំចង់ជម្រាបប៉ុណ្ណឹង" ។

បន្ទាប់មកចៅក្រមរូបនេះបានសួរទៀតថា តើលោកស្រីមានមិត្តភក្តិនៅក្រៅប្រទេសដែរឬទេ? ជាថ្មីម្តងទៀត អៀង ធីរិទ្ធ បានបញ្ជាក់ថា "ខ្ញុំមានមិត្តភក្តិដែលជាសាស្ត្រាចារ្យ ដែលមាន

គេគោរព ហើយអ្នកទាំងនោះដឹងថាខ្ញុំមិនបានធ្វើអ្វីផ្តេសផ្តាស ទេតាំងពីតូចដល់ធំ ហើយបានទៅរៀនដល់ប្រទេសបារាំងទៀត ដែលមានគ្រូពេញចិត្តថែមទៀត» ។ ចៅក្រម មុមបា បានបន្តសួរទៀតថា តើលោកស្រីមានបំណងចង់ទៅបរទេសទេ? អៀង ធិរិទ្ធ បានបញ្ជាក់ថា «ខ្ញុំមិនទាន់មានបំណងទេដោយសារនៅទីនេះ មានគេមើលថែ ហើយអ្នកមើលថែនោះជួយនាងខ្ញុំពេលមានតម្រូវការ និងជួយកុំឲ្យខ្ញុំភ្លេចភាសាបរទេស ដោយសារប្រទេសយើងតូចមានមនុស្សតិច ។ ជាងនេះទៅទៀត ខ្ញុំសប្បាយចិត្ត និងមិនចង់ឲ្យបាត់បង់ភាសារបរទេសនោះទេ» ។ ជាចុងក្រោយចៅក្រម មុមបា បានសាកសួរថា តើលោកស្រីបានទទួលការព្យាបាលវេជ្ជសាស្ត្រដែរឬទេ? ឆ្លើយតបនឹងសំណួរនេះ អៀង ធិរិទ្ធ បានឆ្លើយថា «នៅកន្លែងដែលខ្ញុំរស់នៅ គឺមានអ្នកនៅជួយដោយសារគេដឹងពីស្ថានភាពជំងឺរបស់ខ្ញុំ ហើយនៅពេលខ្លះខ្ញុំធ្វើការច្រើនពេក មិនចង់ពិសារបាយ ដូច្នេះមានអ្នកជួយឲ្យខ្ញុំពិសារបាយបានច្រើន និងធ្វើឲ្យខ្លួនអាចជាបាន» ។

បន្ទាប់មកចៅក្រមអន្តរជាតិមួយរូបទៀត គឺលោកស្រី មីឡាត បានបន្តសាកសួរជនជាប់ចោទ អៀង ធិរិទ្ធ ទៀតថា តើមានគ្រូតពិនិត្យផ្នែកសន្តិសុខដែរឬទេ? ឆ្លើយតបនឹងសំណួរនេះ ជនជាប់ចោទ អៀង ធិរិទ្ធ បាននិយាយដោយមិនច្បាស់លាស់ថា «មើលទាំងអស់គ្នាដូចជាអត់មានទេណា៎ ។ ខ្ញុំពេលដែលខ្ញុំមករស់នៅក្នុងប្រទេសអស់លោកនេះ គឺខ្ញុំរស់នៅតាមធម្មតាៗទេ គេមិនដែលបែកចែកថាខ្ញុំហ្នឹង ជាមនុស្សខាងសន្តិសុខខាងអីទេ គេអត់ទេ ។ ហើយអ្នកណាដែលគេចេះខ្មែររួចហើយគេច្រើនតែមកនិយាយជាមួយខ្ញុំ ព្រោះខ្ញុំភ្លាប់បានពាក្យអង់គ្លេសច្រើនបន្តិចៗ អីចឹងទៅពាក្យអង់គ្លេសដែលលោកនេះ គាត់អ្នកធ្វើនោះណា ។ ដល់អីចឹងទៅគេៗគ្រាន់តែឃើញថាយើងអាចចេះភាសាបរទេសបាន ។ ខ្ញុំគ្រាន់តែសូមជម្រាបប៉ុណ្ណឹងទេ» ។

ចំពោះសំណួរបន្ទាប់លោកស្រីចៅក្រមបានបន្តសួរទៀតថា តើមានការរំខានដល់ខ្លួនដែរឬទេ ក្នុងការដែលមានការត្រួតពិនិត្យផ្នែកសន្តិភាព និងសន្តិសុខ? ជនជាប់ចោទ អៀង ធិរិទ្ធ បានបន្តថា «ទើបនឹងចាប់ផ្តើមទេពេលនោះ គឺបានធ្វើហើយ ។ ខ្ញុំបានចាប់ផ្តើមធ្វើហើយ ។ ដោយកន្លែងដែលយើងរស់នៅ ហ្នឹងមានសុទ្ធតែបរទេសៗ ។ ហើយក៏យើងក៏អ្នកជិតខាងយើងទាំងអស់គ្នាដែលគាត់ឃើញថា កូនចៅគាត់ក៏បានរៀនសូត្រស្អីៗជាច្រើន អីចឹងយើងជួយគាត់ គាត់លំបាក កន្លែងណាយើងជួយគាត់កន្លែង ហ្នឹងអីហ្នឹង ។ ខ្មែរយើងទាំងអស់គ្នាហ្នឹង គាត់ក៏ជួយយើងច្រើនណាស់ក្នុងបញ្ហានេះ ។ ដល់អីចឹងទៅបងប្អូនខាងបារាំងនេះដែលនៅកន្លែងដែលខ្ញុំនៅនេះ គាត់ក៏ជួយអ្នកខ្មែរៗដែលមានជំងឺអីប៉ុន្មានគាត់ជួយទាំងអស់ពេលដែលខ្ញុំនៅនោះ គាត់ជួយទាំងអស់តែម្តងគាត់ជួយៗច្រើនមែនទែនបញ្ហាហ្នឹង» ។

សំណួរចុងក្រោយរបស់ចៅក្រម មីឡាត សួរថាតើ អៀង ធិរិទ្ធ ចង់រស់នៅតែម្នាក់ឯងដែរឬទេ? ឆ្លើយតបនឹងសំណួរនេះ អៀង ធិរិទ្ធ បានបញ្ជាក់ថា «ខ្ញុំមិនចង់នៅស្ងៀមស្ងាត់ម្នាក់ឯងទេ ព្រោះពេលអង្គុលខ្ញុំនៅធ្វើការនៅកន្លែងខាងក្រោមហ្នឹង គឺមានបងប្អូនស្បែកសរទាំងក្មេងទាំងចាស់គាត់មកធ្វើការជាមួយខ្ញុំដែរ ។ អីចឹងគាត់មកធ្វើការជាមួយយើងទាំងអស់ហ្នឹង» ។

បន្ទាប់ពីតុលាការបានប្រកាសសំរាក១៥នាទី លោកប្រធានអង្គជំនុំជម្រះតុលាការកំពូលបានបន្តសាកសួរលោកស្រី អៀង វិជិជា បន្តទៀតទាក់ទងនឹងការរស់នៅរបស់លោកស្រីជាមួយជនជាប់ចោទ អៀង ធិរិទ្ធ ។ លោកស្រី វិជិជា បានបញ្ជាក់ថា ខ្លួនរស់នៅជាមួយជនជាប់ចោទជាប់លាប់ពីរបីថ្ងៃក្នុងមួយអាទិត្យ ដើម្បីជួយជនជាប់ចោទក្នុងការហូបចុកថ្នាំពេទ្យ និងធ្វើចលនាហាត់ប្រាណខ្លះ ។ ចៅក្រម មីឡាត បានបន្តសួរទៀតថា តើជនជាប់ចោទ អៀង ធិរិទ្ធ មានមិត្តភក្តិនៅបរទេសដែរឬទេ? ឆ្លើយតបនឹងសំណួរនេះ លោកស្រី អៀង វិជិជា បានបញ្ជាក់ថា ម្តាយរបស់លោកស្រី (ជនជាប់ចោទ អៀង ធិទ្ធិ) មិនមានមិត្តភក្តិនៅបរទេសទេ ហើយពុំមានហេតុផលណាដែលម្តាយរបស់លោកស្រីត្រូវចេញទៅបរទេសនោះទេ ដោយសារតែម្តាយខ្លួនដើរជិតៗស្ទើរតែមិនបានផង ។ ជាងនេះទៅទៀត លោកស្រី វិជិជា បានបញ្ជាក់ថា មិនមានមិត្តភក្តិ ឬសាច់ញាតិនៅបរទេសដែលអាចជួយម្តាយខ្លួននោះឡើយ ។ ចៅក្រម មីឡាត បានបន្តសួរថាតើ អៀង ធិរិទ្ធ អាចផ្លាស់ប្តូរអាសយដ្ឋានដែរឬទេ? ឆ្លើយតបនឹងសំណួរនេះលោកស្រី វិជិជា បានបញ្ជាក់ថា ករណីនេះអាចមានដែរប្រសិនបើម្តាយរបស់ខ្លួន (អៀង ធិរិទ្ធ) មានការ

ធុញទ្រាន់ ។ ម្យ៉ាងវិញទៀត ប្រសិនបើមានការផ្លាស់ប្តូរអាសយដ្ឋាននោះ ពិតជាអាចមានផលវិបាកចំពោះលោកស្រី ប៉ុន្តែប្រសិនបើមានការសម្រេចពីតុលាការទាក់ទងនឹងបញ្ហានេះ លោកស្រី



អៀង វិជិដា កូនស្រីរបស់ជនជាប់ចោទ អៀង ធីរិទ្ធ កំពុងឆ្លើយតបនឹងសំណួររបស់ចៅក្រម

នឹងជម្រាបទៅតុលាការ ។ ចៅក្រម មីឡាត បានបន្តសួរថាតើ អៀង ធីរិទ្ធ ត្រូវការអត្តសញ្ញាណប័ណ្ណដែរឬទេក្នុងការរស់នៅប្រចាំថ្ងៃ? ឆ្លើយតបនឹងសំណួរនេះ លោកស្រី វិជិដា បានបញ្ជាក់ថា ស្ថានភាពបច្ចុប្បន្ននេះម្តាយលោកស្រីអាចរស់នៅដោយមិនចាំបាច់មានអត្តសញ្ញាណប័ណ្ណនោះទេ ដោយសារតែម្តាយខ្លួនមានអាយុច្រើន ដូច្នេះ ការមានអត្តសញ្ញាណប័ណ្ណគឺមិនចាំបាច់ឡើយ ។ ម្យ៉ាងវិញទៀត ការពិនិត្យសុខភាពនៅប្រទេសកម្ពុជាមិនតម្រូវឲ្យមានអត្តសញ្ញាណប័ណ្ណឡើយ ។ បន្ថែមលើនេះទៅទៀត ដោយសារតែម្តាយលោកស្រីនៅតែបន្តទទួលការព្យាបាលពីតុលាការនៅឡើយ ដូច្នេះលោកស្រីបានទាក់ទងតែជាមួយគ្រូពេទ្យដែលធ្លាប់បានស្គាល់ប្រវត្តិម្តាយលោកស្រីតែប៉ុណ្ណោះ ដោយមិនចាំបាច់មានអត្តសញ្ញាណប័ណឡើយ ។ ចៅក្រម មីឡាត បានបន្តសួរថាតើក្នុងករណីដែលមិត្តភក្តិនៅបរទេសផ្ញើរឥវ៉ាន់មកឲ្យ អៀង ធីរិទ្ធ នោះត្រូវការអត្តសញ្ញាណប័ណ្ណដែរឬទេ? ទាក់ទងនឹងបញ្ហានេះ លោកស្រី វិជិដា បានបញ្ជាក់ថា តាមធម្មតាពិតជាតម្រូវឲ្យមាន ប៉ុន្តែនៅពេលបច្ចុប្បន្នមិនមានអ្នកណាផ្ញើឥវ៉ាន់មកម្តាយខ្លួននោះទេ ។ ផ្ទុយទៅវិញ ប្រសិនបើមានទាក់ទងនឹងការចាត់ចែងទ្រព្យសម្បត្តិនោះ លោកស្រីពិតជាត្រូវការឲ្យម្តាយខ្លួនមានអត្តសញ្ញាណប័ណ្ណ ។ បន្ទាប់មក ចៅក្រម មីឡាត បានសាកសួរថាតើត្រូវការឲ្យមានលិខិតឆ្លងដែនសម្រាប់ អៀង ធីរិទ្ធ ដែរឬទេ? ទាក់ទងនឹងបញ្ហានេះ លោកស្រី វិជិដា បានឆ្លើយតបថាចំពោះអត្តសអញ្ញាណប័ណ្ណ និងលិខិតឆ្លងងដែននោះ គឺអាស្រ័យលើការសម្រេចរបស់តុលាការតែប៉ុណ្ណោះ ។

បន្ទាប់មក ចៅក្រម សោម សេរីវុឌ្ឍ បានបន្តការសួរថាតើ អៀង ធីរិទ្ធ នឹងទទួលយកការព្យាបាលផ្នែកវិជ្ជសាស្ត្រណាមួយផ្សេងទៀតដែរឬទេ? ទាក់ទងនឹងការព្យាបាលនេះ លោកស្រី វិជិដា បានបញ្ជាក់ថា កន្លងមកម្តាយលោកស្រីកំពុងស្ថិតនៅក្រោមការព្យាបាលរបស់វេជ្ជបណ្ឌិតជាប្រចាំរាល់ខែ ។ រីឯការពិនិត្យលើបញ្ហាសតិបញ្ញាស្មារតីរបស់ អៀង ធីរិទ្ធ វិញ លោកស្រីបានរៀបរាប់ថា ស្ថានភាពម្តាយរបស់លោកស្រីមិនមានភាពប្រក្រតីទេ ហើយមានការលំបាកសម្រាប់លោកស្រីក្នុងការនាំម្តាយរបស់ខ្លួនទៅ ពិនិត្យសុខភាព ដោយសារពេលខ្លះ អៀង ធីរិទ្ធ មិនចង់ទៅពិនិត្យសុខភាព ។ ដូច្នេះការវាយតម្លៃនេះ លោកស្រីមិនអាចកំណត់បានឡើយ ។

បន្ទាប់មកចៅក្រម ម៉ុង មុន្នីចរិយា បានបន្តសួរថាតើជនជាប់ចោទ អៀង ធីរិទ្ធ មានទំនាក់ទំនងជាមួយជនជាប់ចោទផ្សេងទៀតក្នុងសំណុំរឿង០០២ដែរឬទេ? ទាក់ទងនឹងបញ្ហានេះ លោកស្រី វិជិដា បានបញ្ជាក់ថា មិនមានជនជាប់ចោទណាបានទាក់ទងជាមួយម្តាយលោកស្រីឡើយ ដោយសារម្តាយលោកស្រីមានជំងឺវង្វេងវង្វាន់ ប៉ុន្តែលោកស្រីបានបន្ថែមថា អៀង ធីរិទ្ធ ធ្លាប់ប្រាប់ថាឪពុកលោកស្រី គឺជាម្តាយខ្លួន ។ ជាងនេះទៅទៀត លោកស្រី វិជិដា បានបញ្ជាក់ប្រាប់តុលាការថា ខ្លួនបានយល់ច្បាស់ថា អៀង ធីរិទ្ធ មិនត្រូវឲ្យមានទំនាក់ទំនងជាមួយជនជាប់ចោទផ្សេងទៀតឡើយ ។ បន្ទាប់មកលោកស្រី ចៅក្រម មីឡាត បានបន្តការសួរថា តើការតម្រូវឲ្យមានការត្រួតពិនិត្យសុវត្ថភាព អៀង ធីរិទ្ធ រៀងរាល់សប្តាហ៍ ឬរាល់ខែអាចធ្វើបានដែរឬទេ? ឆ្លើយតបនឹងសំណួរនេះលោកស្រី វិជិដា បានបញ្ជាក់ថា ករណីនេះមានការពិបាកដោយសារពេលខ្លះជនជាប់ចោទចង់ចេញពី

បន្ទប់ ហើយពេលខ្លះមិនចង់ចេញដូច្នេះ ករណីនេះលោកស្រីមិនមានលទ្ធភាពធ្វើបានទេ ។

បន្ទាប់មកលោកប្រធានអនុញ្ញាតឲ្យភាគីធ្វើការសន្និដ្ឋានបន្ថែម ដោយចាប់ផ្តើមពីតំណាងសហព្រះរាជអាជ្ញា ប៉ុន្តែភ្លាមនោះមេធាវី អេលីស បានស្នើសុំឲ្យមានការសាកសួរពីភាពត្រឹមត្រូវនៃចម្លើយរបស់ជនជាប់ចោទ ។ ភ្លាមៗនោះ សហព្រះរាជអាជ្ញា និងអង្គជំនុំជម្រះតុលាការកំពូលបានបដិសេធដោយអនុ-ញ្ញាតឲ្យជនជាប់ចោទ អៀង ធីរិទ្ធ ធ្វើសេចក្តីថ្លែងការណ៍ចុងក្រោយ ។ ផ្ទុយទៅវិញ អៀង ធីរិទ្ធ បានចោទសួរទៅអង្គជំនុំជម្រះតុលាការកំពូលវិញថា «នរណាជនជាប់ចោទ?» ។ បន្ទាប់មកអង្គជំនុំជម្រះតុលាការកំពូលក៏អនុញ្ញាតឲ្យលោកស្រី វិជីដា ធ្វើសេចក្តីថ្លែងការណ៍ជំនួសម្តាយរបស់ខ្លួន ។ លោកស្រី វិជិដា បានថ្លែងថា ៖

«ចាស៎ នាងខ្ញុំសូមថ្លែងអំណរគុណចំពោះលោកប្រធាន ខ្ញុំក៏អត់មានអីវែងឆ្ងាយគ្រាន់តែចង់ជម្រាបដល់អង្គជំនុំជម្រះថាសព្វថ្ងៃនេះ គឺម្តាយខ្ញុំស្ថិតនៅក្នុងសភាពមួយដែលគាត់ហៅថា វង្វេង



អ្នកចូលរួមកំពុងដើរចេញពីសាលសវនាការ (ប្រភព ៖ មជ្ឈមណ្ឌលឯកសារកម្ពុជា)

វង្វាន់ស្មារតី ហើយមិនអាចចងចាំអ្វីបានទាំងអស់សូម្បីតែជាកូនរបស់គាត់ហ្នឹង ពេលខ្លះគាត់ហៅបង ពេលខ្លះគាត់ហៅប៉ា ពេលខ្លះហៅម៉ាក់អីចឹងទៅតាមតែគាត់នឹកឃើញ ។

ហើយមួយទៀត លទ្ធភាពដែលគាត់មកចូលរួមនៅកន្លែងនេះក៏គាត់បានខំប្រឹងប្រែងអូសទាញអីអីចឹងគឺថា ពេលណាគាត់ចង់ដើបពីសម្រាកក៏ដើបពេលណាអត់ គឺថាវាពិបាកក្នុងការ ដែលនាំមកម្តងៗហ្នឹងគឺមានការពិបាក មិនមែនថាគេចវេះទេ តែដោយសារស្មារតីសុខភាពរបស់គាត់គឺចុះខ្សោយទ្រុឌទ្រោមមែនទែន ហើយម្យ៉ាងអាយុវ័យរបស់គាត់ចាស់ ។ ហើយក្នុងនាមជាកូនគឺទោះបីជាយ៉ាងណាក្តីក៏ខិតខំជួយជ្រោមជ្រែង និងថែទាំ ហើយក៏សូមអរគុណដែរចំពោះអង្គជំនុំជម្រះ និងលោកប្រធានដែលបានអនុគ្រោះ ហើយបានយល់ដល់សុខភាពរបស់ម្តាយខ្ញុំដែលគាត់មិនអាចអង្គុយបាន ។ សូមថ្លែងអំណរគុណ ហើយដែលមានការយល់ចំពោះទុក្ខធុរៈរបស់ម្តាយខ្ញុំ ហើយចំពោះខ្លួនខ្ញុំមិនមានស្អីដែលជាសេចក្តីសន្និដ្ឋានអីវែងឆ្ងាយទេ ។ សូមអស់ប៉ុណ្ណឹងចាស៎ ។»

### ៤) សេចក្តីសម្រេចរបស់អង្គជំនុំជម្រះតុលាការកំពូលទាក់ទងនឹងលក្ខខណ្ឌចំពោះការដោះលែងជនជាប់ចោទ អៀង ធីរិទ្ធ

នៅថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០១២ គឺមួយខែបន្ទាប់ពីសវនាការស្តីពីបណ្តឹងឧទ្ធរណ៍ចំពោះលក្ខខណ្ឌ ដោះលែងជនជាប់ចោទ អៀង ធីរិទ្ធ អង្គជំនុំជម្រះតុលាការកំពូលនៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា បានចេញសេចក្តីសម្រេចទាក់ទងនឹងលក្ខខណ្ឌទាំងនោះ ។

នៅក្នុងសេចក្តីសម្រេចបិទផ្លូវតវ៉ានេះ អង្គជំនុំជម្រះតុលាការកំពូលបានសម្រេចទទួលយកបណ្តឹងសាទុក្ខរបស់សហព្រះរាជអាជ្ញាដោយផ្នែក និងបានបដិសេធត្រង់ចំណុច ដែលអង្គជំនុំជម្រះសាលាដំបូងមិនទទួលយកសំណើដែលសហព្រះរាជអាជ្ញា ស្នើឲ្យដាក់វិធានការត្រួតពិនិត្យតាមផ្លូវតុលាការលើ អៀង ធីរិទ្ធ ។ អង្គជំនុំជម្រះតុលាការកំពូល ក៏បានសម្រេចបដិសេធសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូង ចុះថ្ងៃទី១៣ ខែកញ្ញា ឆ្នាំ២០១២ ត្រង់ចំណុចដែលថា "ក្នុងអំឡុងពេលផ្អាកកិច្ចដំណើរការនីតិវិធី ដោយគ្មានកំណត់ពេលលើជនជាប់ចោទ អៀង ធីរិទ្ធ អង្គជំនុំជម្រះសាលាដំបូងមិនអាចអនុវត្តយុត្តាធិការរបស់ខ្លួនលើជនជាប់ចោទ និងខ្វះនូវមូលដ្ឋានច្បាប់ក្នុងការសម្រេចដាក់លក្ខខណ្ឌដោយបង្ខំលើការដោះលែងជនជាប់ចោទ" ។ អង្គជំនុំជម្រះតុលាការកំពូលបានរកឃើញនូវភាពផ្ទុយគ្នាចំនួនពីរ ដែលមាននៅក្នុងសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូង ដែលថាខ្លួនមិនអាចអនុវត្តនូវយុត្តាធិការលើជនជាប់ចោទ អៀង ធីរិទ្ធ បន្ទាប់ពីទទួលការដោះលែង ដោយសារតែការផ្អាកកិច្ចដំណើរការនីតិវិធីមានលក្ខណៈអចិន្ត្រៃយ៍ (១) ការយល់ឃើញរបស់ខ្លួនថា កិច្ចដំណើរការនីតិវិធីអាចត្រូវបានចាប់ផ្តើមឡើងវិញ ប្រសិនបើយល់ឃើញថា ជនជាប់ចោទមានសម្បទាគ្រប់គ្រាន់នៅពេលក្រោយ និង(២) ការព្រមព្រៀងរបស់ខ្លួនក្នុងការអនុវត្តវិធានការមួយចំនួនក្នុងគោលបំណងធ្វើយ៉ាងណាឲ្យកិច្ចដំណើរការនីតិវិធីនេះអាចដំណើរការឡើងវិញបាន ប្រសិនបើមានការវិវឌ្ឍន៍ផ្នែកវេជ្ជសាស្ត្រ ។ អង្គជំនុំជម្រះតុលាការកំពូល ក៏បានកត់សម្គាល់ដែរថា មិនដូចតុលាការដែលប្រើប្រាស់ប្រព័ន្ធច្បាប់ខមិនឡ (Common Law), ប្រព័ន្ធច្បាប់ស៊ីវិល ដូចជានៅក្នុងអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ពុំមានឆន្ទានុសិទ្ធិមិនបន្តបណ្តឹងអាជ្ញា ដែលខ្លួនបានចាប់ផ្តើមធ្វើរួចទៅហើយ នោះទេ លើកលែងតែមានហេតុផល ដែលចែងយ៉ាងជាក់លាក់ក្នុងច្បាប់ ៖ "ច្បាប់ដែលអាចយកមកអនុវត្តនៅចំពោះអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា មិនបានចែងអំពីលទ្ធភាពបញ្ចប់ដំណើរនីតិវិធីនៅក្នុងករណី ដែលរកឃើញថា ជនជាប់ចោទមិនមានសម្បទាចូលរួមនៅក្នុងសវនាការនោះទេ" ប៉ុន្តែបានចែងអំពីលទ្ធភាពផ្អាកដំណើរការនីតិវិធីក្នុងកាលៈទេសៈជាក់លាក់មួយចំនួនដោយសារតែឧបសគ្គ" ដើម្បីបន្តកិច្ចដំណើរការនីតិវិធី ។

ដោយកត់សម្គាល់លើ"ភាពតានតឹង"រវាងសិទ្ធិជាសារវ័ន្តមូលដ្ឋានរបស់ជនជាប់ចោទ ដែលទំនងជាមិនអាចនាំយកទៅជំនុំជម្រះបាន និងផលប្រយោជន៍យុត្តិធម៌ ក្នុងការចោទប្រកាន់ជនជាប់ចោទពីបទឧក្រិដ្ឋធ្ងន់ធ្ងរ" អង្គជំនុំជម្រះតុលាការកំពូលបានពិនិត្យយ៉ាងល្អិតល្អន់លើវិធាន និងការអនុវត្ត ដែលមាននៅក្នុងកម្រិតអន្តរជាតិ ក៏ដូចជាការអនុវត្តនៅក្នុងស្រុកដែរ" ដើម្បីសម្រេចថាតើការអនុវត្តនូវស្តង់ដារអន្តរជាតិ អាចតម្រូវឲ្យមានការបញ្ចប់នីតិវិធីបុយ៉ាងណា? ក្នុងចំណោមការយល់ឃើញរបស់ខ្លួន គឺថា"ដំណោះស្រាយបន្ទន់ ឬផ្អាកនីតិវិធីបណ្តោះអាសន្នប្រឆាំងនឹងជនជាប់ចោទ ដែលពុំមានសម្បទាគ្រប់គ្រាន់ក្នុងការចូលរួមជំនុំជម្រះ និងបន្តការអនុវត្តនូវយុត្តាធិការត្រូវបានគាំទ្រដោយតុលាការអន្តរជាតិជាច្រើនរួចមកហើយ" ដូចជាតុលាការពិសេសសម្រាប់ឧក្រិដ្ឋកម្មធ្ងន់ធ្ងរនៅទីម័រខាងកើត, តុលាការឧក្រិដ្ឋកម្មអន្តរជាតិ និងប្រព័ន្ធតុលាការក្នុងស្រុកជាច្រើនទៀត ដោយរួមទាំងបារាំង ដែលក្រុមរបស់ខ្លួន ផ្តល់ជាគំរូដល់វិស័យនីតិវិធីកម្ពុជា ។

ជារួម អង្គជំនុំជម្រះតុលាការកំពូលយល់ឃើញថា "កិច្ចដំណើរការនីតិវិធីប្រឆាំងនឹងជនជាប់ចោទ ដែលពុំមានសម្បទាគ្រប់គ្រាន់ជាអចិន្ត្រៃយ៍ត្រូវបានបញ្ចប់ ហើយតុលាការបានបោះបង់ចោលនូវយុត្តា ធិការលើជនជាប់ចោទ គឺនូវតែជាករណីពិសេស" ។ យុត្តាធិការ"អនុញ្ញាតឲ្យតុលាការចាត់វិធានការនានា ដែលត្រូវបានចាត់ទុកថាចាំបាច់ និងសមស្របនៅក្នុងកាលៈទេសៈទាំងនោះ ដើម្បីអាចបន្តកិច្ចដំណើរការនីតិវិធី ប្រសិនបើមាន

ទិកាស» ដោយសារតែលក្ខខណ្ឌវេជ្ជសាស្ត្ររបស់ជនជាប់ចោទ និងវិទ្យាសាស្ត្រ ផ្នែកវេជ្ជសាស្ត្រ គឺ«អាចផ្លាស់ប្តូរតាមពេលវេលា» និង«អាស្រ័យលើកំហុសរបស់មនុស្ស និងអាកប្បកិរិយាពុំស្មោះត្រង់របស់ជនជាប់ចោទ ។

បន្ទាប់មក អង្គជំនុំជម្រះតុលាការកំពូល បានពិចារណាលើអំណះអំណាងរបស់អង្គជំនុំជម្រះសាលាដំបូងដែលថាពុំមាន «មូលដ្ឋានផ្នែកគតិយុត្តិជាក់លាក់ក្នុងការត្រួតពិនិត្យតាមផ្លូវតុលាការក្នុងអំឡុងពេលផ្អាកកិច្ចដំណើរការនីតិវិធី ។ ជាដំបូង អង្គជំនុំជម្រះតុលាការកំពូលបានកត់សម្គាល់ថា «ការផ្អាកកិច្ចដំណើរការនីតិវិធីមិនបានរារាំងតុលាការក្នុងការធ្វើចំណាត់ការលើដំណើរការនីតិវិធី និងអនុវត្តវិធានការ ដើម្បីធានាការបន្តនីតិវិធីសុច្ចរិតភាពរបស់ខ្លួនឡើយ» ។ បន្ទាប់មកអង្គជំនុំជម្រះតុលាការកំពូលបានរកឃើញថាមានមូលដ្ឋានគតិយុត្តិជាផ្លូវការសម្រាប់អនុវត្តវិធានការទូទៅដែលទាក់ទងនឹងការឃុំខ្លួន និងការត្រួតពិនិត្យតាមផ្លូវតុលាការនៅក្នុងក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជា និងវិធានផ្ទៃក្នុងរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ។


ជុំ មុី ដើមបណ្តឹងរដ្ឋប្បវេណីក្នុងសំណុំរឿង០០១ និងជាជនរងគ្រោះនៅមន្ទីរស-២១ ឬគុកទួលស្លែង (ប្រភពរូបថត ៖ ទីភ្នាក់ងារសារព័ត៌មាន រ៉យទ័រ)

ជាចុងបញ្ចប់ អង្គជំនុំជម្រះតុលាការកំពូលបានសម្រេចឲ្យមានរបបនៃការត្រួតពិនិត្យតាមផ្លូវតុលាការ ដែលតម្រូវឲ្យជនជាប់ចោទ អៀង ធីរិទ្ធ ត្រូវបំពេញដូចតទៅ ៖

១) ជូនដំណឹងដល់ការិយាល័យរដ្ឋបាលមុនពេលផ្លាស់ប្តូរអាស័យដ្ឋានស្នាក់នៅបច្ចុប្បន្នរបស់ជន ជាប់ចោទ ២) មិនឲ្យចាកចេញពីព្រះរាជាណាចក្រកម្ពុជាដោយគ្មានការអនុញ្ញាតពីអង្គជំនុំជម្រះសាលាដំបូងនោះទេ ៣) ទទួលការត្រួតពិនិត្យផ្នែកវេជ្ជសាស្ត្ររៀងរាល់ប្រាំមួយខែម្តង ដោយអ្នកជំនាញផ្នែកវេជ្ជសាស្ត្រ ដែលត្រូវបានចាត់តាំងដោយអង្គជំនុំជម្រះសាលាដំបូង ៤) ត្រូវបង្ហាញខ្លួនសម្រាប់ការត្រួតពិនិត្យផ្នែកសន្តិសុខដែលអនុវត្តដោយនគរបាលយុត្តិធម៌ ឬ អាជ្ញាធរមូលដ្ឋានក្នុងរយៈពេលមួយខែម្តង ដើម្បីបញ្ជាក់ការអនុវត្តនូវវិធានការនៃការត្រួតពិនិត្យតាមផ្លូវតុលាការ ។

ក្នុងសេចក្តីសម្រេចរបស់ខ្លួន អង្គជំនុំជម្រះតុលាការកំពូលបានសម្រេចបដិសេធផ្នែកផ្សេងទៀតនៃបណ្តឹងសាទុក្ខរបស់សហព្រះរាជអាជ្ញា ដោយបង្គាប់ឲ្យប្រគល់លិខិតឆ្លងដែន និងអត្តសញ្ញាណប័ណ្ណជូនជនជាប់ចោទវិញ ។ តុលាការកំពូលក៏បានបង្គាប់ឲ្យនគរបាលយុត្តិធម៌ធ្វើការត្រួតពិនិត្យជាប្រចាំខែនូវអាស័យដ្ឋានដែលជនជាប់ចោទផ្តល់ជូនតុលាការដើម្បីបញ្ជាក់ថា អៀង ធីរិទ្ធ ស្នាក់នៅអាស័យដ្ឋានដដែល និងមិនចាកចេញពីប្រទេស ។ ព្រមទាំងតម្រូវឲ្យនគរបាលយុត្តិធម៌រាយការណ៍អំពីការគំរាមកំហែងណាមួយចំពោះសុវត្ថិភាពរបស់ អៀង ធីរិទ្ធ ដោយផ្អែកតាមកាតព្វកិច្ចរបស់រដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា ដើម្បីធានានូវសន្តិសុខរបស់ជនជាប់ចោទ អៀង ធីរិទ្ធ ទៅអង្គជំនុំជម្រះសាលាដំបូង ។

ជាចុងក្រោយ អង្គជំនុំជម្រះតុលាការកំពូលបានបង្គាប់ឲ្យលុបចោលនូវវិធានការបណ្តោះអាសន្នដែលប្រធានអង្គជំនុំជម្រះសាលាដំបូងបានបង្គាប់នៅក្នុងដីកាសម្រេចលើសំណើរបស់សហព្រះរាជអាជ្ញាសុំផ្អាកសេចក្តីសម្រេចដោះលែងជនជាប់ចោទ អៀង ធីរិទ្ធ ។

# សវនាការស្ដីពីបញ្ហាសុខភាពរបស់ជនជាប់ចោទ អៀង សារី
## ថ្ងៃទី៨ ខែវិច្ឆិកា ឆ្នាំ២០១២

ចាន់ ប្រាថ្នា

### សេចក្ដីផ្ដើម

នៅថ្ងៃទី៨ ខែវិច្ឆិកា ឆ្នាំ២០១២ អង្គជំនុំជម្រះសាលាដំបូងនៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា បានបើកសវនាការដើម្បីស្ដាប់សក្ខីកម្មរបស់សាស្ត្រាចារ្យ ចន ខាំប៊ែល អំពីស្ថានភាពសុខភាព របស់ជនជាប់ចោទ អៀង សារី ។ សាស្ត្រាចារ្យ ខាំប៊ែល មានវ័យ៦៦ឆ្នាំ ជាជនជាតិណូវែលហ្សឺឡង់ ជាអ្នកជំនាញផ្នែកជំងឺបេះដូង និងជំងឺមនុស្សចាស់ ដែលមានបទពិសោធជាច្រើនឆ្នាំ ។ លោកត្រូវបានអង្គជំនុំជម្រះសាលាដំបូងចាត់តាំងឲ្យពិនិត្យតាមដានសុខភាពរបស់ជនជាប់ចោទ អៀង សារី និងវាយតម្លៃអំពីលទ្ធភាពក្នុងការចូលរួមការជំនុំជម្រះក្ដី ។ គួរបញ្ជាក់ថា ជារឿយៗជនជាប់ចោទ អៀង សារី បានស្នើសុំចូលរួមសវនាការពីចម្ងាយតាមប្រព័ន្ធសោតទស្សន៍ ដែលត្រូវបានរៀបចំនៅក្នុងបន្ទប់រង់ចាំ ដោយអះអាងថា ខ្លួនមានបញ្ហាសុខភាពមិនអាចចូលរួមសវនាការដោយផ្ទាល់បាន ។ លើសពីនេះទៀត ប៉ុន្មានខែចុងក្រោយនេះ សវនាការបានប្រព្រឹត្តទៅដោយអវត្តមានជនជាប់ចោទ អៀង សារី ដោយជនជាប់ចោទរូបនេះត្រូវបានតម្រូវឲ្យទទួលការព្យាបាលនៅមន្ទីរពេទ្យមិត្តភាពខ្មែរ-សូវៀត ក្រោយពីមានការសង្គ្រោះបន្ទាន់កាលពីថ្ងៃទី៧ ខែកញ្ញា ឆ្នាំ២០១២ ។

ដោយការពិភាក្សាផ្ដោតសំខាន់តែលើបញ្ហាសុខភាពរបស់ជនជាប់ចោទ អៀង សារី ដូច្នេះការចូលរួមរបស់ក្រុមមេធាវីការពារក្ដីជនជាប់ចោទ ខៀវ សំផន និង នួន ជា ត្រូវបានអង្គជំនុំជម្រះកម្រិតត្រឹមជាអ្នកសង្កេតការណ៍តែប៉ុណ្ណោះ ហើយពុំមានសិទ្ធិចោទសំណួរ ឬធ្វើសេចក្ដីសន្និដ្ឋានណាមួយនៅក្នុងអំឡុងពេលសវនាការនេះឡើយ ។

សវនាការបានប្រព្រឹត្តទៅអស់រយៈពេល១ថ្ងៃកន្លះ ដោយចាប់ផ្ដើមសួរអ្នកជំនាញតាមលំដាប់ពីចៅក្រមនៃអង្គជំនុំជម្រះ ក្រុមមេធាវីការពារក្ដីជនជាប់ចោទ អៀង សារី តំណាងសហព្រះរាជអាជ្ញា និងចុងក្រោយ គឺការធ្វើសេចក្ដីសន្និដ្ឋានបញ្ចប់របស់ភាគី ។



ជនជាប់ចោទ អៀង សារី នៅក្នុងបន្ទប់សវនាការ (ប្រភពរូបថត ៖ អ.វ.ត.ក)

## ១) ប្រវត្តិនីតិវិធី

នៅថ្ងៃទី៧ ខែកញ្ញា ឆ្នាំ២០១២ ជនជាប់ចោទ អៀង សារី ត្រូវបានបញ្ជូនទៅព្យាបាលនៅមន្ទីរពេទ្យមិត្តភាពខ្មែរ-សូវៀត ជាបន្ទាន់ដោយសារតែជនជាប់ចោទមានជំងឺបេះដូងដែលបណ្តាលឲ្យវិលមុខ និងហត់ខ្លាំង ។ អៀង សារី ត្រូវបានបន្តទទួលការព្យាបាលរហូតដល់ថ្ងៃទី២១ ខែកញ្ញា ឆ្នាំ២០១២ ។ បន្ទាប់មក អង្គជំនុំជម្រះបានបើកសវនាការស្តាប់សក្ខីកម្មរបស់វេជ្ជបណ្ឌិតពីររូប គឺលោក លឹម ស៊ីវុត្ថា និងលោក គី ប៊ូស្ង ដែលជាគ្រូពេទ្យទទួលបន្ទុកតាមដានសុខភាពរបស់ អៀង សារី ជាប្រចាំ ។

យោងតាមសក្ខីកម្មរបស់វេជ្ជបណ្ឌិតទាំងពីររូបខាងលើបានបង្ហាញថា បន្ទាប់ពីទទួលការសង្គ្រោះបន្ទាន់ ស្ថានភាពសុខភាពរបស់ អៀង សារី ពាក់ព័ន្ធនឹងជំងឺបេះដូង និងសម្ពាធឈាម គឺមានលក្ខណៈប្រក្រតីឡើងវិញ ហើយពុំមានសញ្ញាណាមួយដែលបញ្ជាក់ថាជំងឺទាំងនេះនឹងមានការប្រែប្រួលខ្លាំងទេ ។ ប៉ុន្តែ មូលហេតុដែល អៀង សារី ត្រូវបានតម្រូវឲ្យទទួលការសម្រាកព្យាបាលនៅមន្ទីរពេទ្យបន្តនោះ គឺដោយសារតែមានការរកឃើញជំងឺថ្មីមួយទៀត គឺការតៀ្បតសរសៃឈាមនៅត្រង់ឆ្អឹងកង-ក ដែលធ្វើឲ្យឈាមមិនអាចទៅចិញ្ចឹមខួរក្បាលបានគ្រប់គ្រាន់ និងបណ្តាលឲ្យកើតជំងឺវិលមុខញឹកញាប់ ។ លោកវេជ្ជបណ្ឌិត លឹម ស៊ីវុត្ថា បានបង្ហាញនូវក្តីបារម្ភយ៉ាងខ្លាំងអំពីស្ថានភាពជំងឺនេះ ដោយបញ្ជាក់ថា ការព្យាបាលដោយប្រើថ្នាំ គឺនឹងត្រូវប្រើពេលយូរ ហើយមិនប្រាកដថានឹងបានធូរស្រាលឡើយ ។ ចំណែកការព្យាបាលដោយធ្វើការវះកាត់ គឺអាចប្រើរយៈពេលខ្លី ប៉ុន្តែប្រឈមហានិភ័យខ្ពស់ ពីព្រោះ អៀង សារី មានជំងឺបេះដូង ហើយឆ្អឹងកង-កទាំងអស់បានពុក ដែលកត្តាទាំងនេះអ្នកជំងឺមិនអាចទ្រាំបាននៅពេលទទួលការវះកាត់ ។

នៅថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០១២ ប្រធានអង្គជំនុំជម្រះសាលាដំបូងបានជូនដំណឹងដល់ភាគីថា លោកនឹងផ្តល់រាល់របាយការណ៍វេជ្ជសាស្ត្ររបស់ អៀង សារី ចាប់ពីថ្ងៃទី៧ ខែកញ្ញា ឆ្នាំ២០១២ (ថ្ងៃចូលមន្ទីរពេទ្យសង្គ្រោះបន្ទាន់) និងប្រតិចារិកនៃសវនាការសួរដេញដោលលោកវេជ្ជបណ្ឌិត លឹម ស៊ីវុត្ថា និង គី ប៊ូស្ង ជូនលោកសាស្ត្រាចារ្យ ចន ខាំប៉ែល ដើម្បីពិនិត្យ និងវាយតម្លៃ ។ បន្ទាប់ពីបានពិនិត្យរបាយការណ៍ទាំងនោះ លោក ចន ខាំប៉ែល គូសបញ្ជាក់ជូនអង្គជំនុំជម្រះថា លោកពិបាកជឿជាក់អំពីមូលហេតុនៃការប្រែប្រួលស្ថានភាពសុខភាពរបស់ជនជាប់ចោទ អៀង សារី ។ ដោយមានការបញ្ជាក់ខុសគ្នាដូច្នេះ នៅថ្ងៃទី៨



វេជ្ជបណ្ឌិត លឹម ស៊ីវុត្ថា និងវេជ្ជបណ្ឌិត គី ប៊ូស្ង គ្រូពេទ្យពិនិត្យ និងព្យាបាលជំងឺជនជាប់ចោទ អៀង សារី
(ប្រភព ៖ មជ្ឈមណ្ឌលឯកសារកម្ពុជា)

ខែតុលា ឆ្នាំ២០១២ ប្រធានអង្គជំនុំជម្រះបានកោះអញ្ជើញសាស្ត្រាចារ្យ ចន ខាំប៊ែល ឲ្យមកពិនិត្យ និងវាយតម្លៃអំពីស្ថានភាពសុខភាពរបស់ជនជាប់ចោទ អៀង សារី រួមទាំងស្វែងរកលទ្ធភាពណាមួយដើម្បីធ្វើកោសល្យវិច័យវេជ្ជសាស្ត្របន្ថែម ហើយត្រូវធ្វើរបាយការណ៍ជូនអង្គជំនុំជម្រះ និងទុកលទ្ធភាពឲ្យភាគីមានឱកាសសួរដេញដោលសាស្ត្រាចារ្យ ខាំប៊ែល ។

**២) ការសួរដេញដោលសាស្ត្រាចារ្យ ចន ខាំប៊ែល ស្តីពីរបាយការណ៍វាយតម្លៃស្ថានភាពសុខភាព អៀង សារី**

**២.ក) ការសួរដេញដោលដោយអង្គជំនុំជម្រះ**

មុនពេលអនុញ្ញាតឲ្យចៅក្រមផ្សេងៗចោទសំណួរប្រធានអង្គជំនុំជម្រះ គឺលោកចៅក្រម និល ណុន បានស្នើឲ្យសាស្ត្រាចារ្យ ខាំប៊ែល បង្ហាញដោយសង្ខេបអំពីរបាយការណ៍ចុងក្រោយស្តីពីបញ្ហាសុខភាពរបស់ជនជាប់ចោទ អៀង សារី ដែលលោកបានផ្តល់ជូនអង្គជំនុំជម្រះនាថ្ងៃទី៦ ខែវិច្ឆិកា ឆ្នាំ២០១២ ។ ឆ្លើយតបនឹងសំណើនេះសាស្ត្រាចារ្យ ខាំប៊ែល បញ្ជាក់ថា អៀង សារី មានការចុះខ្សោយផ្នែករាងកាយជាងមុន ប៉ុន្តែផ្នែកបញ្ញាស្មារតី ឬសមត្ថភាពនៃការចងចាំ គឺមិនមានការប្រែប្រួលគួរឲ្យកត់សម្គាល់ឡើយ ។

ពាក់ព័ន្ធនឹងការចុះខ្សោយផ្នែករាងកាយ សាស្ត្រាចារ្យ ខាំប៊ែល បញ្ជាក់ថា អៀង សារី មានការចុះខ្សោយផ្នែកសាច់ដុំដោយសារមិនបានធ្វើលំហាត់ប្រាណ ឬធ្វើចលនា អស់រយៈពេលជាងពីរខែ ក្នុងអំឡុងពេលសម្រាកនៅមន្ទីរពេទ្យ ។ ចំពោះការវិលមុខដែល អៀង សារី តែងតែត្អូញត្អែរ លោកសាស្ត្រាចារ្យបញ្ជាក់ថា មូលហេតុដែលនាំឲ្យកើតជំងឺនេះ គឺដោយសារតែមានបញ្ហាលើប្រព័ន្ធឈាមដែលមានតួនាទីក្នុងការរក្សាប្រព័ន្ធលំនឹងពោល គឺមានបញ្ហានៅក្នុងប្រហោងសរសៃឈាមទាំងនោះ ។ ដូច្នេះនៅពេលអ្នកជំងឺងាកចុះឡើង អង្គុយ ឬក្រោកឈរ គឺនឹងធ្វើឲ្យប៉ះពាល់ដល់លំហូរឈាមដែលបណ្តាលឲ្យមានការវិលមុខ ។ បន្ថែមលើនេះការចុះខ្សោយបេះដូង និងការធ្លាក់ចុះនៃសម្ពាធឈាមក៏ជាមូលហេតុមួយដែលបណ្តាលឲ្យមានការវិលមុខដែរ ។ ចំពោះការរកឃើញរបស់លោកវេជ្ជបណ្ឌិត លឹម ស៊ីវុត្ថា ដែលថា ការវិលមុខរបស់ អៀង សារី គឺបណ្តាលមកពីការខ្វះឈាមទៅចិញ្ចឹមខួរក្បាល លោក ខាំប៊ែល បញ្ជាក់ថា លោកមិនបានរកឃើញសញ្ញាណាមួយដែលបញ្ជាក់ថា អៀង សារី មានបញ្ហាកង្វះឈាមក្នុងការចិញ្ចឹមខួរក្បាលឡើយ ។ ជាក់ស្តែងលោកពិនិត្យឃើញថា សរសៃឈាមដែលទទួលបន្ទុកបញ្ជូនឈាមទៅចិញ្ចឹមខួរក្បាលទាំងផ្នែកខាងមុខ និងខាងក្រោយ គឺពុំមានការខូចខាតឡើយ ។

ពាក់ព័ន្ធនឹងផ្នែកបញ្ញាស្មារតីវិញ សាស្ត្រាចារ្យ ខាំប៊ែល បញ្ជាក់ថា សមត្ថភាពចងចាំរបស់ជនជាប់ ចោទ អៀង សារី គឺមិនមានការប្រែប្រួលគួរឲ្យកត់សម្គាល់ឡើយ ។ លទ្ធផលនៃការធ្វើកោសល្យវិច័យវេជ្ជសាស្ត្របានបង្ហាញថា សតិបញ្ញា ឬការចងចាំរបស់ អៀង សារី គឺពុំមានការខុសគ្នាជាដុំកំភួនទៅនឹងរបាយការណ៍វេជ្ជសាស្ត្រដែលបានធ្វើក្នុងខែកញ្ញា ឆ្នាំ២០១២ឡើយ ។ គួរបញ្ជាក់ថា របាយការណ៍ខែកញ្ញា ឆ្នាំ២០១២ ដែលបានធ្វើឡើងដោយសាស្ត្រាចារ្យ ខាំប៊ែល វេជ្ជបណ្ឌិត ស៊ីណា ហ្វាហ្វែល និងវេជ្ជបណ្ឌិត ហួត លីនណា បានបញ្ជាក់ថា អៀង សារី មានសម្បទាគ្រប់គ្រាន់ក្នុងការចូលរួមការជំនុំជម្រះក្តី ។ សាស្ត្រាចារ្យ ខាំប៊ែល បន្ថែមថា ការចុះខ្សោយនៃផ្នែករាងកាយ គឺមិនបានបង្កឲ្យប៉ះពាល់ដល់សមត្ថភាពនៃការចងចាំ និងការផ្ចង់អារម្មណ៍របស់ អៀង សារី ឡើយ ។ ចុងក្រោយលោកបានបញ្ជាក់ថា យោងតាមការពិនិត្យវេជ្ជសាស្ត្ររបស់លោក គឺបានបង្ហាញថាពុំមានលក្ខខណ្ឌណាមួយដែលតម្រូវឲ្យ អៀង សារី ត្រូវបន្តព្យាបាលនៅមន្ទីរពេទ្យមិត្តភាពខ្មែរ-សូវៀត ទៀតឡើយ ។ ពោលគឺ អៀង សារី អាចចេញពីមន្ទីរពេទ្យ និងចូលរួម សវនាការបាន ។

បន្ទាប់ពីលោក ខាំប៊ែល បានបញ្ជាក់ដោយសង្ខេបអំពីរបាយការណ៍ស្តីពីស្ថានភាពសុខភាពរបស់ជនជាប់ចោទ អៀង សារី ប្រធានអង្គជំនុំជម្រះបានប្រគល់វេទិកាជូនលោកស្រីចៅក្រម ស៊ីលវៀ ខាតវ៉ាយត៍ ដើម្បីចោទសំណួរបន្ថែម ។ សំណួរជាច្រើនរបស់លោកស្រីចៅក្រម គឺផ្តោតសំខាន់អំពីគុណវុឌ្ឍិរបស់សាស្ត្រាចារ្យ ខាំប៊ែល ។ ឆ្លើយតបនឹងសំណួរនេះ សាស្ត្រាចារ្យ ខាំប៊ែល បញ្ជាក់ថា លោកមានបទពិសោធជាច្រើនឆ្នាំក្នុងការព្យាបាលជំងឺមនុស្សចាស់ ហើយបច្ចុប្បន្នលោកនៅតែបន្តព្យាបាលមនុស្សចាស់ជាច្រើន ។ ពាក់ព័ន្ធនឹងការពិនិត្យ និងវាយតម្លៃអំពីស្ថានភាពសុខភាពរបស់ជនជាប់ចោទ អៀង សារី សាស្ត្រាចារ្យ ខាំប៊ែល

បញ្ជាក់ថា របាយការណ៍ចុងក្រោយរបស់លោក គឺមានភាពស្រប គ្នាជាមួយរបាយការណ៍របស់លោកវេជ្ជបណ្ឌិត គុជ ហាក់ និង វេជ្ជបណ្ឌិតហ៊ុលីពណាគម័ង់កាំង (ធ្វើក្នុងឆ្នាំ២០០៨) របាយការណ៍ របស់វេជ្ជបណ្ឌិត កាស៊ិន បូណាត និងវេជ្ជបណ្ឌិត ប្រ៊ីនឌីង (ធ្វើក្នុង ឆ្នាំ២០០៩) របាយការណ៍របស់លោកផ្ទាល់ (ខាំប៊ែល) ដែលធ្វើ នៅខែមិថុនា ឆ្នាំ២០១១ និងរបាយការណ៍ចុះខែកញ្ញាឆ្នាំ២០១២ (ដែលធ្វើដោយលោកវេជ្ជបណ្ឌិត ហួត លីនណា វេជ្ជបណ្ឌិត ស៊ីណា ហ្វាហ្សែល និងសាស្ត្រាចារ្យចន ខាំប៊ែល) ។ សាស្ត្រាចារ្យ ខាំប៊ែល បានអះអាងថា បន្ទាប់ពីពិនិត្យមើលរបាយការណ៍ទាំងនេះ និង របាយការណ៍ចុងក្រោយរបស់លោក គឺបានបញ្ជាក់ថា សតិបញ្ញា និង សមត្ថភាពនៃការចងចាំរបស់ អៀង សារី ពុំមានការប្រែប្រួល ឡើយ ។

ពាក់ព័ន្ធនឹងសំណួររបស់លោកស្រីចៅក្រមដែលថា តើត្រូវ ការអ្នកជំនាញផ្សេងទៀត ដើម្បីវាយតម្លៃបន្ថែមអំពីសតិបញ្ញា ស្មារតីរបស់ជនជាប់ចោទ អៀង សារី ក្នុងការចូលរួមសវនាការ ដែរឬយ៉ាងណា? សាស្ត្រាចារ្យ ខាំប៊ែល បានបញ្ជាក់ថា របាយ ការណ៍ចុងក្រោយរបស់លោកបានបញ្ជាក់យ៉ាងច្បាស់ថា សតិ បញ្ញារបស់ជនជាប់ចោទ អៀង សារី គឺមិនមានការប្រែប្រួល ឡើយ ។ ដូច្នេះ លោកមិនត្រូវការអ្នកជំនាញបន្ថែមឡើយ ព្រោះ អៀង សារី ទើបតែត្រូវបានពិនិត្យយ៉ាងល្អិតល្អន់អំពីសតិបញ្ញា ស្មារតី ដោយអ្នកជំនាញផ្នែកវិកលវិទ្យានៅក្នុងខែកញ្ញា ឆ្នាំ ២០១២ ដែលបានបង្ហាញថា មានសម្បទាគ្រប់គ្រាន់ក្នុងការចូល រួមការជំនុំជម្រះ ។ ក្នុងការធ្វើកោសល្យវិច័យអំពីសមត្ថភាពបញ្ញា ស្មារតីរបស់ជនជាប់ចោទ អៀង សារី សាស្ត្រាចារ្យ ខាំប៊ែល បាន អនុវត្តនូវវិធីសាស្ត្របីយ៉ាងរួមមាន ទី១) ការសួរនាំអំពីសមាជិក គ្រួសារ ទី២) ការចងចាំអំពីព្រឹត្តការណ៍ផ្ទាល់ខ្លួន និងទី៣) ការធ្វើ កោសល្យវិច័យអំពីកម្រិតអប្បមានៃការចងចាំ (M.M.S.E) ។ សាស្ត្រាចារ្យ ខាំប៊ែល បញ្ជាក់ថា លទ្ធផលនៃការធ្វើកោសល្យ វិច័យ គឺទទួលបានពិន្ទុហួសពីការរំពឹងទុក ពោលគឺទទួលបានពិន្ទុ ២៦លើ៣០ ដែលបញ្ជាក់ថា អៀង សារី មានសម្បទាគ្រប់ គ្រាន់ក្នុងការចូលរួមការជំនុំជម្រះ ។

ពាក់ព័ន្ធនឹងការចូលរួមសវនាការនេះ សាស្ត្រាចារ្យ ខាំប៊ែល បញ្ជាក់ថា អៀង សារី អាចធ្វើការផ្ចង់អារម្មណ៍ក្នុងការតាមដាន នីតិវិធីរបស់តុលាការបានរយៈពេល១ម៉ោង ទៅ១ម៉ោងកន្លះ ។ ប៉ុន្តែ ដើម្បីឲ្យមានភាពងាយស្រួលក្នុងការតាមដានសវនាការ អៀង សារី គប្បីត្រូវបានអនុញ្ញាតឲ្យតាមដានតាមរយៈប្រព័ន្ធ សោតទស្សន៍នៅបន្ទប់រង់ចាំ ព្រោះបន្ទប់នេះជនជាប់ចោទអាច ទម្រេតខ្លួនបានស្រួល ។ សាស្ត្រាចារ្យ ខាំប៊ែល បានផ្ដល់អនុ- សាសន៍ថា អៀង សារី គប្បីទទួលការថែទាំឲ្យជិតដល់ជាងមុន ព្រោះជនជាប់ចោទមានវ័យចំណាស់ និងមានជំងឺបេះដូង ។ ជាង នេះទៅទៀត ត្រូវធ្វើលំហាត់ប្រាណ ឬធ្វើចលនាផ្សេងៗ ដើម្បីឲ្យ សាច់ដុំរបស់អ្នកជំងឺមានភាពប្រសើរឡើងវិញ ។

### ២.១) ការសួរដេញដោលដោយក្រុមមេធាវីការពារក្តី អៀង សារី

ក្នុងអំឡុងពេលនៃការសួរដេញដោលដោយក្រុមមេធាវីការ ពារក្តីជនជាប់ចោទ អៀង សារី គឺមានសភាពតានតឹងជាខ្លាំង ។ បញ្ហាសំខាន់នោះគឺថា លោកមេធាវីអន្តរជាតិ ម៉ៃឃើល កាណា វ៉ាស មានបំណងឲ្យកូនក្តីរបស់ខ្លួនទទួលបាននូវការពិនិត្យវាយតម្លៃ


មេធាវីការពារក្តី ម៉ៃឃើល កាណាវ៉ាស
(ប្រភព : មជ្ឈមណ្ឌលឯកសារកម្ពុជា)

អំពីសម្បទាក្នុងការចូលរួមសវនាការពីវេជ្ជបណ្ឌិតមួយ រូបផ្សេង ទៀត ។ មេធាវី កាណាវ៉ាស បានព្យាយាមបង្ហាញឈ្មោះវេជ្ជ បណ្ឌិត ហិលដេ ប៊ីស៊ិន ដែល មកពីសកលវិទ្យាល័យ ហាវើដ គឺ

ជាអ្នកជំនាញដែលមានគុណវុឌ្ឍិខ្ពស់ក្នុងការវាយតម្លៃអំពីសម្បទារបស់ អៀង សារី ក្នុងការចូលរួមសវនាការ ។ ជាងនេះទៅទៀត លោក កាណាវ៉ាស បានព្យាយាមម្តងហើយ ម្តងទៀតឲ្យសាស្ត្រាចារ្យ ខាំប៊ែល ផ្តល់យោបល់ថា ប្រសិនបើលោក ប៊ឺស៊ីន មានឱកាសបានពិនិត្យ របាយការណ៍សុខភាពទាំងអស់របស់ អៀង សារី នោះនឹងធ្វើឲ្យការវាយតម្លៃអំពីសម្បទាក្នុងការចូលរួមសវនាការកាន់តែមានសុក្រិតភាពថែមទៀត ។ គួរបញ្ជាក់ថា លោក ប៊ឺស៊ីន បានផ្តល់របាយការណ៍មួយទាក់ទងនឹងសម្បទារបស់ អៀង សារី ក្នុងការចូលរួមសវនាការ ។ ថ្វីត្បិតរបាយការណ៍នោះមិនត្រូវបានយកមកជជែកដេញដោលក្នុងសវនាការ ប៉ុន្តែរបាយការណ៍នោះទំនងជាបង្ហាញថា អៀង សារី ពុំមាន សម្បទាគ្រប់គ្រាន់ក្នុងការចូលរួមសវនាការ ដែលលទ្ធផលនេះ គឺជួយគ្នានឹងការរកឃើញរបស់សាស្ត្រាចារ្យ ចន ខាំប៊ែល ។ គួរបញ្ជាក់ថា នៅថ្ងៃទី១៧ ខែធ្នូ ឆ្នាំ២០១២ អង្គជំនុំជម្រះសាលាដំបូងបានចេញផ្សាយលិខិតរបស់លោក ប៊ឺស៊ីន ដែលបានផ្ញើរជូនក្រុមមេធាវីការពារក្តីជនជាប់ចោទ អៀង សារី កាលពីថ្ងៃទី៧ ខែវិច្ឆិកា ឆ្នាំ២០១២ ។ នៅក្នុងលិខិតនោះ លោក ប៊ឺស៊ីន បានលើកឡើងថា "...ផ្អែកលើបទពិសោធន៍របស់ខ្ញុំអស់រយៈពេលចំនួនជាង ៣០ឆ្នាំ ជាអ្នកជំនាញវិកលវិទ្យានីតិសាស្ត្រក្នុងវិស័យ សិក្សាស្រាវជ្រាវ និងដែលបានការទទួលស្គាល់ពីតុលាការ ខ្ញុំសូមអះអាងថា វិធីសាស្ត្ររបស់វេជ្ជបណ្ឌិត Campblell ស្ថិតក្នុងលំដាប់ថ្នាក់ដែលពុំអាចជឿជាក់បានខ្លាំងជាងគេ ។ ហើយអាចប្រមើលឃើញថា ភាពពុំអាចឲ្យជឿជាក់បាននេះ ពុំគោរពដល់សិទ្ធិរបស់ជនជាប់ចោទដែលបាត់បង់សមត្ថភាពក្នុងការមានលទ្ធភាពជួយដល់មេធាវីក្នុងតុលាការនេះឡើយ" ។ អាចរកមើលលម្អិតក្នុងឯកសារដែលមានចំណងជើងថា "លិខិតពី Harold J. Bursztajn, MD ជូនចំពោះមេធាវីការពារក្តី អៀង សារី ទាក់ទងនឹង អៀង សារី ចុះថ្ងៃទី៧ ខែវិច្ឆិកា ឆ្នាំ២០១២" លេខឯកសារ E238/6 ។

ទោះបីជាយ៉ាងណាក៏ដោយ លោកព្រះរាជអាជ្ញារង វីល្លៀម ស្មីត បានជំទាស់យ៉ាងខ្លាំង ដោយលោកបានលើកឡើងថា ការសម្រេចចាត់តាំងអ្នកជំនាញបន្ថែមដើម្បីពិនិត្យសម្បទារបស់ អៀង សារី ក្នុងការចូលរួមសវនាការ គឺជាសិទ្ធិរបស់អង្គជំនុំជម្រះ ។ ដូច្នេះការដែលសួរសាស្ត្រាចារ្យ ខាំប៊ែល ថាគប្បី ឲ្យអ្នកជំនាញផ្សេងៗទៀត ពិនិត្យ ឬមិនពិនិត្យ គឺមិនសមស្របឡើយ ។ ម្យ៉ាងវិញទៀតក៏មិនអាចឲ្យសាស្ត្រាចារ្យ ខាំប៊ែល ឆ្លើយដោយស្មានៗថា ប្រសិនបើលោក ប៊ឺស៊ីន បានពិនិត្យរបាយការណ៍សុខភាព របស់ អៀង សារី ទាំងអស់ដូចខ្លួន (សាស្ត្រាចារ្យ ខាំប៊ែល) នោះនឹងមានការរកឃើញលទ្ធផលដូច ឬខុសគ្នាជាមួយនឹងខ្លួនដែរ ។ ជាលទ្ធផលប្រធានអង្គជំនុំជម្រះបានបង្គាប់ឲ្យលោក កាណាវ៉ាស រៀបចំសំណួររបស់ខ្លួនឲ្យបានត្រឹមត្រូវ ដោយលោកបញ្ជាក់ថា "លោកមេធាវីហាក់ដូចជាការប្រើប្រាស់សំណួរ នៅតែប្រភេទសំណួរក្នុងបំណងឲ្យលោកសាស្ត្រាចារ្យ ខាំប៊ែល ដែលជាអ្នកជំនាញពាក់ព័ន្ធនឹងការធ្វើរបាយការណ៍អំពីបញ្ហាសុខភាពរបស់លោក អៀង សារី នាពេលនេះ គាត់ឆ្លើយដោយស្មានៗ..." ។ ទោះបីជាយ៉ាងណា សាស្ត្រាចារ្យ ខាំប៊ែល បញ្ជាក់ថា លោកមិនត្រូវការអ្នកជំនាញផ្នែកវិកលវិទ្យា បន្ថែមទៀតឡើយ ពីព្រោះរបាយការណ៍របស់វេជ្ជបណ្ឌិត ស៊ីណា ហ៊ុហែរុល ដែលជាអ្នកជំនាញផ្នែក ជំងឺវិកលចរិតបានបង្ហាញថា អៀង សារី មានសម្បទាគ្រប់គ្រាន់ក្នុងការចូលរួមសវនាការ ហើយរហូតមកដល់ពេលនេះ លោក (ខាំប៊ែល) ពិនិត្យឃើញថា ផ្នែកសតិបញ្ញារបស់ អៀង សារី គឺពុំមានការប្រែប្រួលឡើយ ។

បន្ទាប់ពីទទួលការណែនាំពីអង្គជំនុំជម្រះ មេធាវី កាណាវ៉ាស បានបន្តសួរសាស្ត្រាចារ្យ ខាំប៊ែល ពាក់ព័ន្ធនឹងការផ្ចង់អារម្មណ៍របស់ អៀង សារី ក្នុងការចូលរួមសវនាការ ។ មេធាវី កាណាវ៉ាស បានលើកឡើងអំពីស្ថានភាពសុខភាពកូនក្តីរបស់ខ្លួន ដែលថា អៀង សារី កំពុងដេកនៅលើគ្រែ ដោយមានប្រព័ន្ធផ្តល់អុកស៊ីហ្សែន... នៅបន្ទប់រង់ចាំខាងក្រោមបន្ទប់សវនាការ បន្ទាប់មកចោទសំណួរថា តើអ្នកដែលមានលក្ខខណ្ឌសុខភាពបែបនេះ អាចមានលទ្ធភាពក្នុងការផ្ចង់អារម្មណ៍ដើម្បីតាមដានសវនាការដែរឬទេ? សាស្ត្រាចារ្យ ខាំប៊ែល បានឆ្លើយតបថា ដោយលោកមិនបានឃើញស្ថានភាពបែបនេះ គឺលោកមិនអាចធ្វើការបញ្ជាក់បានឡើយ ។ ទោះបីជាយ៉ាងណាក៏ដោយ សាស្ត្រាចារ្យ ខាំប៊ែល បញ្ជាក់ថា នៅពេលដែលលោកពិនិត្យ អៀង សារី នៅមន្ទីរពេទ្យ គឺបានបង្ហាញថា អៀង សារី អាចផ្ចង់អារម្មណ៍បានទាំងស្រុង ហើយអាច

ឆ្លើយតបគ្រប់សំណួរបាន ។

ពាក់ព័ន្ធនឹងការផ្ដល់អារម្មណ៍នេះដែរ មេធាវី កាណាវ៉ាស បានបង្ហាញនូវក្ដីបារម្ភយ៉ាងខ្លាំង ដោយលោកបានលើកឡើងថា តាមការបញ្ជាក់របស់លោកវេជ្ជបណ្ឌិត លីម ស៊ីវុត្ថា បានបង្ហាញថា អៀង សារី អាចផ្ដល់អារម្មណ៍បានតែ១០ទៅ១៥នាទីតែប៉ុណ្ណោះ ។ ជាងនេះទៅទៀត អៀង សារី តែងតែដេកលក់ នៅពេលកំពុងតាមដានសវនាការ ។ បន្ទាប់មកមេធាវី កាណាវ៉ាស ចោទសំណួរថា ប្រសិនបើដូចករណីនេះមែន តើ អៀង សារី អាចមានលទ្ធភាពគ្រប់គ្រាន់ក្នុងការណែនាំមេធាវី និងការពារខ្លួនប្រកបដោយប្រសិទ្ធិភាពដែរឬទេ? ជាថ្មីម្ដងទៀត សាស្ត្រាចារ្យ ខាំប៊ែល បញ្ជាក់ថា អៀង សារី ពុំមានបញ្ហាក្នុងការផ្ដល់អារម្មណ៍ឡើយ ហើយអាចផ្ដល់អារម្មណ៍បានរយៈពេលពី១ម៉ោង ទៅ១ម៉ោងកន្លះ ហើយរយៈពេលនេះ គឺសមស្របនឹងរយៈពេលសវនាការរបស់តុលាការ ។ ចំពោះការដែល អៀង សារី តែងតែដេកលក់វិញ លោកសាស្ត្រាចារ្យបញ្ជាក់ថា លោកមិនបានសិក្សាលម្អិតអំពីបញ្ហានេះឡើយ ព្រោះលទ្ធផលនៃការធ្វើកោសល្យវិច័យវេជ្ជសាស្ត្របានបង្ហាញថា អៀង សារី អាចផ្ដល់អារម្មណ៍បានធម្មតា ហើយក៏ពុំមានសញ្ញាណណាមួយដែលបង្ហាញថា អៀង សារី មានការចុះខ្សោយផ្នែកបញ្ញាស្មារតីឡើយ ។ ទោះបីជាយ៉ាងណា សាស្ត្រាចារ្យ ខាំប៊ែល បានបញ្ជាក់ថា នៅពេលលោកធ្វើការពិនិត្យ អៀង សារី នៅមន្ទីរពេទ្យ គឺ អៀង សារី មិនអាចក្រោកអង្គុយ ឬឈរដោយខ្លួនឯងបានឡើយ គឺត្រូវតែមានអ្នកជួយ ។

## ២.ក) ការសួរដេញដោលដោយតំណាងសហព្រះរាជអាជ្ញា

ភាគច្រើននៃសំណួររបស់តំណាងសហព្រះរាជអាជ្ញា គឺផ្ដោតសំខាន់អំពីសម្បទារបស់ជនជាប់ចោទ អៀង សារី ក្នុងការចូលរួមសវនាការ និងមធ្យោបាយ ឬសម្ភារៈផ្សេងៗដែលនឹងត្រូវផ្គត់ផ្គង់សម្រាប់ជនជាប់ចោទ អៀង សារី ដើម្បីបង្កភាពងាយស្រួលក្នុងការតាមដានកិច្ចដំណើរការនីតិវិធីរបស់តុលាការ ។ ទាក់ទងនឹងសម្បទាក្នុងការចូលរួមសវនាការ តំណាងសហព្រះរាជអាជ្ញាបានចោទសួរដោយយោងលើលក្ខខណ្ឌដូចបានកំណត់ក្នុងរឿងក្ដីស្រ្ដូហ្គា ដែលត្រូវបានសម្រេចដោយតុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវីពាក់ព័ន្ធនឹងសម្បទាក្នុងការចូលរួមសវនាការ ។

មុនចូលដល់សំណួរពាក់ព័ន្ធនឹងបញ្ហាសុខភាពរបស់ជនជាប់ចោទ អៀង សារី សហព្រះរាជអាជ្ញារងអន្តរជាតិ វីល្លៀម ស្មីត បានសួរសំណួរមួយចំនួនទាក់ទងនឹងគុណវុឌ្ឍិរបស់លោកសាស្ត្រាចារ្យ ចន ខាំប៊ែល ។ ពោលគឺបទពិសោធការងារក្នុងការធ្វើរបាយការណ៍ពាក់ព័ន្ធនឹងបញ្ហាសម្បទាក្នុងការចូលរួមសវនាការជូនតុលាការ ។ ឆ្លើយតបនឹងសំណួរនេះ សាស្ត្រាចារ្យ ខាំប៊ែល បញ្ជាក់ថា លោកធ្លាប់បានធ្វើរបាយការណ៍ជាច្រើន ទាក់ទងនឹងការកំណត់អំពីសម្បទាក្នុងការចូលរួមសវនាការជូនតុលាការកំពូលនៃប្រទេសនូវែល ហ្សេឡង់ ដើម្បីកំណត់អំពីបញ្ហាស្មារតីរបស់បុគ្គលណាម្នាក់ ។ របាយការណ៍ទាំងនោះ ត្រូវបានតុលាការកំពូលយកធ្វើជាមូលដ្ឋានក្នុងការចេញសាលក្រម ហើយស្ទើររៀងរាល់ខែ តុលាការបានចេញសាលក្រម ដោយយោងលើរបាយការណ៍របស់លោក ។ បន្ទាប់ពីមានការបញ្ជាក់ច្បាស់ដូច្នេះ លោក វីល្លៀម ស្មីត បានចូលដល់សំណួរពាក់ព័ន្ធសមត្ថភាពបញ្ញាស្មារតីរបស់ជនជាប់ចោទ អៀង សារី ។ លោក វីល្លៀម ស្មីត បានបញ្ជាក់ថា ក្នុងការសម្រេចថាជនជាប់ចោទណាម្នាក់អាចមានលទ្ធភាពចូលរួមសវនា


សហព្រះរាជអាជ្ញារងអន្តរជាតិ វីល្លៀម ស្មីត
(ប្រភព : មជ្ឈមណ្ឌលឯកសារកម្ពុជា)

ការបាន ឬមិនបាន គឺត្រូវពិនិត្យមើលសមត្ថភាពនៃការចងចាំ របស់ជនជាប់ចោទ និងថាតើជនជាប់ចោទរូបនេះអាចយល់ដឹង អំពីចំណាត់ការ ឬដំណើរការនីតិវិធីរបស់តុលាការដែរឬយ៉ាងណា? ឆ្លើយតបនឹងការលើកឡើងនេះ សាស្ត្រាចារ្យ ខាំប៊ែល បញ្ជាក់ថា យោងលើរបាយការណ៍ចុះថ្ងៃទី០៣ ខែកញ្ញា ឆ្នាំ២០១២ បាន បង្ហាញថា អៀង សារី មានសមត្ថភាពគ្រប់គ្រាន់ក្នុងការចូលរួម សវនាការ ។ ពោលគឺ អៀង សារី អាចតាមដាន កិច្ចដំណើរការ នីតិវិធីរបស់តុលាការបាន អាចយល់ដឹងអំពីផលវិបាកនៃកិច្ច ដំណើរការនីតិវិធី អាចតតាំងក្តីក្នុងសវនាការបាន។ សាស្ត្រាចារ្យ ខាំប៊ែល បានអះអាងថា ក្នុងការធ្វើរបាយការណ៍នេះ រូបលោក និងសហការីរបស់លោកពីររូបទៀត គឺលោកវេជ្ជបណ្ឌិត ស៊ីណា ហ្សាហែរូល និងលោកវេជ្ជបណ្ឌិត ហួត លីនណា បានចំណាយ ពេលយ៉ាងច្រើន និងធ្វើដោយយកចិត្តទុកដាក់បំផុត ក្នុងការកំណត់ ថា អៀង សារី មានសម្បទាគ្រប់គ្រាន់ក្នុងការចូលរួមសវនាការ ដែរឬយ៉ាងណា ។ ដូចគ្នានឹងរបាយការណ៍នេះដែរ របាយការណ៍ ចុងក្រោយចុះថ្ងៃទី០៦ ខែវិច្ឆិកា ឆ្នាំ២០១២ របស់លោក (ខាំប៊ែល) គឺមិនមានការប្រែប្រួលឡើយ ។ ពោលគឺ អៀង សារី មានសម្បទាគ្រប់គ្រាន់ក្នុងការចូលរួមសវនាការ ព្រោះលទ្ធផល នៃការធ្វើកោសល្យវិច័យវេជ្ជសាស្ត្រ គឺពុំមានភស្តុតាងណាមួយ ដែលបង្ហាញថា ចាប់ពីពេលចេញរបាយការណ៍ថ្ងៃទី០៣ ខែកញ្ញា រហូតមកដល់ពេលចេញរបាយការណ៍ចុងក្រោយបង្អស់ថ្ងៃទី០៦ ខែវិច្ឆិកា ឆ្នាំ២០១២ អៀង សារី មានការចុះខ្សោយផ្នែកបញ្ញា ស្មារតីឡើយ ។

សំណួរចុងក្រោយរបស់លោក វីល្លៀម ស្មីត គឺពាក់ព័ន្ធបញ្ហា សុខភាពផ្លូវកាយរបស់ អៀង សារី ។ ដូចធ្លាប់បានបញ្ជាក់ជូន លោកស្រីចៅក្រម ស៊ីលវៀ ខាតវ្រ៉ាយត៍ ដែរ សាស្ត្រាចារ្យ ខាំប៊ែល បញ្ជាក់ជូនលោក វីល្លៀម ស្មីត ថា អៀង សារី មានការ ចុះខ្សោយផ្នែករាងកាយគួរឲ្យកត់សម្គាល់ ជាពិសេសពាក់ព័ន្ធនឹង ភាពចុះខ្សោយនៃប្រព័ន្ធសាច់ដុំ ។ ការចុះខ្សោយនេះ គឺបណ្តាល មកពីមិនបានធ្វើលំហាត់ប្រាណ ក្នុងអំឡុងពេល អៀង សារី កំពុង ទទួលការព្យាបាលនៅមន្ទីរពេទ្យមិត្តភាពខ្មែរ-សូវៀត ។ ដូច្នេះ អៀង សារី មិនអាចក្រោកឈរ ឬអង្គុយដោយខ្លួនឯងបានឡើយ គឺត្រូវមានអ្នកជួយគ្រា ។ ទោះបីជាយ៉ាងណា សាស្ត្រាចារ្យ ខាំប៊ែល បានអះអាងថា ជំងឺបេះដូងរបស់ អៀង សារី គឺពុំមាន ការប្រែប្រួលគួរឲ្យកត់សម្គាល់ឡើយ ហើយក៏គ្មានភស្តុតាង ឬ សញ្ញាណណាមួយដែលបញ្ជាក់ថា ជំងឺនេះនឹងមានការវិវត្តន៍ទៅ លឿនគួរឲ្យព្រួយបារម្ភណ៍នោះដែរ ។ ប៉ុន្តែជំងឺនេះគឺត្រូវពិនិត្យ តាមដានឲ្យបានជិតដល់ ពីព្រោះការចុះខ្សោយនៃបេះដូង គឺអាច បណ្តាលឲ្យមានបញ្ហាក្នុងការច្របាច់ឈាមទៅចិញ្ចឹមផ្នែកផ្សេងៗ នៃរាងកាយ ។

សាស្ត្រាចារ្យ ខាំប៊ែល បញ្ជាក់យ៉ាងច្បាស់ថា ការចុះខ្សោយ នៃសមត្ថភាពផ្លូវកាយ និងបញ្ហា ជំងឺបេះដូងរបស់ អៀង សារី គឺមិនធ្វើឲ្យប៉ះពាល់ដល់ការផ្តង់អារម្មណ៍ក្នុងការចូលរួមសវនាការ ឡើយ ។

ចុងក្រោយសាស្ត្រាចារ្យ ខាំប៊ែល បានផ្តល់អនុសាសន៍ថា ដើម្បីបង្កភាពងាយស្រួលដល់ អៀង សារី ក្នុងការចូលរួមតាមដាន កិច្ចដំណើរការនីតិវិធីរបស់តុលាការ អង្គជំនុំជម្រះគប្បីអនុញ្ញាត ឲ្យជនជាប់ចោទរូបនេះ ចូលរួមតាមដានសវនាការពីចម្ងាយតាម រយៈប្រព័ន្ធសោតទស្សន៍នៅបន្ទប់រង់ចាំ ។ ប្រសើរជាងនេះទៀត គឺគប្បីផ្តល់គ្រែដែលអាចឲ្យជនជាប់ចោទទម្រេតខ្លួនតាមដានកិច្ច ដំណើរការសវនាការបាន ហើយអ្វីដែលសំខាន់បំផុតនោះ គឺ អៀង សារី ត្រូវធ្វើលំហាត់ប្រាណឲ្យបានញឹកញាប់ ដើម្បីធ្វើឲ្យប្រព័ន្ធ សាច់ដុំមានភាពប្រសើរឡើងវិញ ។ ចំពោះសេវាថែទាំសម្រាប់ អៀង សារី គឺត្រូវយកចិត្តទុកដាក់ជាងមុន ពោលគឺ រាល់ពេលដែល អៀង សារី ធ្វើចលនាគឺត្រូវមានអ្នកជួយអមបើពុំនោះទេនឹង បណ្តាលឲ្យមានគ្រោះថ្នាក់ (បាក់ឆ្អឹង) ក្នុងករណី អៀង សារី ដួល ព្រោះឆ្អឹងស្ទើរតែទាំងអស់របស់ អៀង សារី គឺមានការពុកផុយ ។

### **៣) សេចក្តីសន្និដ្ឋានរបស់ភាគីទាក់ទងនឹងរបាយការណ៍វាយតម្លៃស្ថានភាពសុខភាព អៀង សារី**

បន្ទាប់ពីការសួរដេញដោលដោយភាគីអង្គជំនុំជម្រះបាន អនុញ្ញាតឲ្យភាគីដែលពាក់ព័ន្ធធ្វើសេចក្តីសន្និដ្ឋានបិទបញ្ចប់ ដោយ ចាប់ផ្តើមពីក្រុមមេធាវីការពារក្តីជនជាប់ចោទ អៀង សារី បន្ទាប់ មកតំណាងសហព្រះរាជអាជ្ញា និងចុងក្រោយគឺក្រុមមេធាវី តំណាងដើមបណ្តឹងរដ្ឋប្បវេណី ។

### ៣.ក) សេចក្តីសន្និដ្ឋានរបស់ក្រុមមេធាវីការពារក្តី អៀង សារី

មុននឹងចូលដល់ធ្វើសេចក្តីសន្និដ្ឋានលើចំណុចជាក់លាក់អំពីបញ្ហាសម្បទារបស់ជនជាប់ចោទ អៀង សារី លោកមេធាវីអន្តរជាតិ ម៉ៃឃើល ការណាវ៉ាស បានលើកឡើងនូវទ្រឹស្តីរបស់លោក ថូម៉ាស ចេហ្វឺសុន (Thomas Jefferson) ជាកំពូលប្រធានាធិបតី និងជាអ្នករៀបចំសេចក្តីប្រកាសឯករាជ្យរបស់ សហរដ្ឋអាមេរិក ដែលថា«ការបញ្ចេញនូវមតិ និងការយល់ឃើញដ៏ស្មោះត្រង់ មិនទាមទារអ្វីឲ្យលើសពីការពន្យល់ និងការយល់គ្នាទៅវិញទៅមក ដើម្បីធ្វើឲ្យយើងទាំងអស់គ្នារួបរួមគ្នានៅក្នុងមធ្យោបាយមួយចំនួន ដែលធ្វើឲ្យពួកយើងអាចធ្វើដំណើរទៅជាមួយគ្នាបាន» ។ យោងលើទ្រឹស្តីនេះ មេធាវី ការណាវ៉ាស បានលើកឡើងថា ការស្វែងយល់អំពីភាពពិតប្រាកដនៃបញ្ហាសុខភាពរបស់ អៀង សារី គឺជាដំណោះស្រាយដែលអាចទទួលយកបាន និងប្រកបដោយយុត្តិធម៌ ដែលធ្វើឲ្យភាគីទាំងអស់អាចយល់គ្នាទៅវិញទៅមក ដើម្បីរួមគ្នាក្នុងការដោះស្រាយបញ្ហាទាំងនេះ ។ លោកមេធាវីបានសង្កត់ធ្ងន់ថា បញ្ហាសុខភាពរបស់ អៀង សារី នាពេលបច្ចុប្បន្ន គឺប្រាកដណាស់ដែលធ្វើឲ្យប៉ះពាល់ដល់សិទ្ធិទទួលបានការជំនុំជម្រះក្តី ប្រកបដោយត្រឹមត្រូវ និងយុត្តិធម៌ ដែលត្រូវបានធានាដោយរដ្ឋធម្មនុញ្ញកម្ពុជា និងកតិកាសញ្ញាអន្តរជាតិ ស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ ។

ពាក់ព័ន្ធនឹងរបាយការណ៍របស់សាស្ត្រាចារ្យ ខាំប៉ែល ចុះថ្ងៃទី០៦ ខែវិច្ឆិកា ឆ្នាំ២០១២ មេធាវី ការណាវ៉ាស បានបង្ហាញជំហរថា មិនគប្បីទទួលយកទស្សនៈរបស់សាស្ត្រាចារ្យ ខាំប៉ែល ដោយគ្មានលក្ខខណ្ឌឡើយ ។ ផ្ទុយមកវិញ អង្គជំនុំជម្រះគប្បីជំរុញឲ្យមានអ្នកជំនាញថ្មីម្នាក់ទៀត ដែលមិនជាប់ពាក់ព័ន្ធ ឬមិនមានទំនាក់ទំនងជាមួយសាស្ត្រាចារ្យ ខាំប៉ែល ក្នុងការពិនិត្យ អៀង សារី ដើម្បីផ្តល់នូវការវាយតម្លៃដែលមានលក្ខណៈឯករាជ្យ ។ លោកមេធាវីនៅតែទទូចសុំអង្គជំនុំជម្រះចាត់តាំងវេជ្ជបណ្ឌិត ប៊ីស៊ិន ធ្វើការពិនិត្យវាយតម្លៃបញ្ហាសុខភាពរបស់ អៀង សារី បន្ថែមទៀត ដើម្បីកំណត់អំពីសម្បទាក្នុងការចូលរួមសវនាការឲ្យបានច្បាស់លាស់ ដើម្បីជៀសវាងការបង្កខបសគ្គដល់កិច្ចដំណើរការសវនការនៅពេលអនាគត ។ ចុងក្រោយមេធាវី ការណាវ៉ាស បញ្ជាក់ថា ប្រសិនបើសំណើរបស់ខ្លួនត្រូវបានបដិសេធ នោះសុំឲ្យអង្គជំនុំជម្រះចេញសេចក្តីសម្រេចជាលាយលក្ខណ៍អក្សរ និងមានសំអាងហេតុច្បាស់លាស់ ។

បន្ទាប់ពីមេធាវី ការណាវ៉ាស បានបញ្ចប់ការធ្វើសេចក្តីសន្និដ្ឋានរបស់ខ្លួន លោកស្រីចៅក្រម ខាតវ៉្រាយត៍ ស្នើមេធាវី ការណាវ៉ាស បញ្ជាក់ឲ្យបានច្បាស់ថា តាមជំហររបស់ខ្លួន (ការណាវ៉ាស) អៀង សារី មាន ឬមិនមានសម្បទាគ្រប់គ្រាន់ក្នុងការចូលរួមសវនាការ? ឆ្លើយតបនឹងសំណើនេះ មេធាវី ការណាវ៉ាស បញ្ជាក់ថា "ខ្ញុំសូមបញ្ជាក់ឲ្យច្បាស់លាស់ជំហររបស់យើងខ្ញុំគឺថា គាត់មិនមានសម្បទាគ្រប់គ្រាន់នោះទេ ។ គាត់មិនអាចចូលរួមសវនាការដោយមានន័យគ្រប់គ្រាន់ផ្អែកទៅតាមបទដ្ឋានអន្តរជាតិនោះទេ ដែលអង្គជំនុំជម្រះនេះត្រូវតែគោរពតាម ហើយគោរពរដ្ឋធម្មនុញ្ញកម្ពុជា..." ។ លោកមេធាវី បានបន្ថែមថា ប្រសិនបើអង្គជំនុំជម្រះជឿជាក់តាមការលើកឡើងរបស់លោក ខាំប៉ែល គឺមានន័យថា កំពុងចាប់បង្ខំ អៀង សារី ឲ្យធ្វើការចាប់អារម្មណ៍ និងយកចិត្តទុកដាក់ទៅលើកិច្ចដំណើរការនីតិវិធីរបស់តុលាការ ។ លើសពីនេះទៀត ក្នុងករណីអង្គជំនុំជម្រះសម្រេចថា អៀង សារី មានសម្បទាគ្រប់គ្រាន់ក្នុងការចូលរួមសវនាការ នោះលោកនឹងស្នើសុំឲ្យបំបែកកូនក្តីរបស់លោកចេញពីសំណុំរឿង០០២/ ០១ ជាមិនខាន ។ មេធាវី ការណាវ៉ាស បានបន្ថែមថា "...យើងអាចធ្វើយ៉ាងណាឲ្យគាត់នេះ មកក្នុងបន្ទប់សវនាការនេះដើម្បីចូលរួម ហើយពិនិត្យមើលថា តើគាត់ងោក ឬមួយយ៉ាងណា? ហើយយើងក៏ត្រូវសួរខ្លួនឯងថា តើនេះជាបទដ្ឋានដែលបានគោរពតាមត្រឹមត្រូវដែរឬទេ?..." ។ ចុងក្រោយលោក មេធាវីបានស្នើសុំអង្គជំនុំជម្រះអនុញ្ញាតឲ្យ អៀង សារី ចូលរួមដោយផ្ទាល់នៅបន្ទប់សវនាការ ឬតភ្ជាប់រូបភាពរបស់ជនជាប់ចោទ តាមរយៈប្រព័ន្ធសោទស្សន៍ពីបន្ទប់ឃុំខ្លួននៅខាងក្រោមសាលសវនាការ ដើម្បីឲ្យសាធារណៈជនបានឃើញអំពីស្ថានភាពរបស់ អៀង សារី ក្នុងការចូលរួមសវនាការ ។

ពាក់ព័ន្ធនឹងការអះអាងថា អៀង សារី មិនមានសម្បទាគ្រប់គ្រាន់នេះ មេធាវី ការណាវ៉ាស បញ្ជាក់ថា លោកបានជួបផ្ទាល់ជាមួយ អៀង សារី ដើម្បីសួរនាំ និងផ្តល់ឯកសារឲ្យពិនិត្យមួយ

ចំនួន ពាក់ព័ន្ធនឹងអង្គហេតុដែលសាក្សី ឬដើមបណ្តឹងរដ្ឋប្បវេណី បានផ្តល់សក្ខីកម្មក្នុងសវនាការ ។ ប៉ុន្តែលោកអាចជួបពិភាក្សា បានតែ៥ ទៅ១០នាទីតែប៉ុណ្ណោះ លើសពីនេះ អៀង សារី មិន អាចផ្តង់អារម្មណ៍បានឡើយ ពោលគឺ អៀង សារី ត្អូញថា វិលមុខ និងហេវហត់ខ្លាំង ។

### ៣.ខ) សេចក្តីសន្និដ្ឋានរបស់សហព្រះរាជអាជ្ញា

ក្នុងការធ្វើសេចក្តីសន្និដ្ឋានពាក់ព័ន្ធនឹងបញ្ហាសុខភាពរបស់ អៀង សារី សហព្រះរាជអាជ្ញារង អន្តរជាតិ វីល្លៀម ស្មីត បាន យោងស្ទើរទាំងស្រុងលើរបាយការណ៍ និងសក្ខីកម្មរបស់លោក វេជ្ជបណ្ឌិត ចន ខាំបែល ។ លោក វីល្លៀម ស្មីត បានលើកឡើងថា យោងតាមរបាយការណ៍របស់សាស្ត្រាចារ្យ ខាំបែល គឺបាន បង្ហាញយ៉ាងច្បាស់ថា ជនជាប់ចោទ អៀង សារី មានសម្បទា គ្រប់គ្រាន់ក្នុងការចូលរួមសវនាការ ។ របាយការណ៍បានបញ្ជាក់ថា ស្ថានភាពសុខភាពរបស់ អៀង សារី គឺមានសភាពនឹងនរធម្មតា ពោលគឺមិនមានការប្រែប្រួលខ្លាំងឡើយ ។ ទោះបីជាយ៉ាងណា ក៏ដោយ លោក វីល្លៀម ស្មីត បានទទួលស្គាល់ថា សុខភាពរបស់ ជនជាប់ចោទ អៀង សារី គឺមានការធ្លាក់ចុះជាងមុនបន្តិច ហើយ តម្រូវឲ្យមានការថែទាំដោយមានការយកចិត្តទុកដាក់ជាងមុន ។ លោក វីល្លៀម ស្មីត អះអាងបន្ថែមថា ដើម្បីដោះស្រាយបញ្ហា ទាំងនេះ អង្គជំនុំជម្រះអាចអនុវត្តតាមអនុសាសន៍របស់សាស្ត្រា ចារ្យ ខាំបែល ដែលថា អៀង សារី គប្បីអនុញ្ញាតឲ្យតាមដាន សវនាការពីចម្ងាយតាមរយៈប្រព័ន្ធសោទស្សន៍ និងផ្តល់សេវា ថែទាំឲ្យបានជិតដល់ជាងមុន ។

ចំពោះករណីដែលមេធាវី កាណាវ៉ាស លើកឡើងថា លោក អាចជជែកពិភាក្សាជាមួយ អៀង សារី បានរយៈពេលតែ ៥ ទៅ ១០នាទីនោះ លោក វីល្លៀម ស្មីត បញ្ជាក់ថា នេះគឺជាការលើក ឡើងរបស់មេធាវីការពារក្តីជនជាប់ចោទ ។ សាស្ត្រាចារ្យ ខាំបែល បានបញ្ជាក់ថា ក្នុងអំឡុងនៃការសួរនាំម្តងៗដែលមានរយៈពេល ជិត១ម៉ោង គឺ អៀង សារី អាចផ្តង់អារម្មណ៍ផ្តល់បទសម្ភាសន៍ បាន ។ ទោះបី ជាយ៉ាងណាក៏ដោយ លោក វីល្លៀម ស្មីត បញ្ជាក់ថា កត្តាទាំងនេះគឺមិនមែនជាបញ្ហាឡើយ ។ បញ្ហាសំខាន់នោះ គឺអង្គ ជំនុំជម្រះត្រូវសម្រេចថា អៀង សារី មានសម្បទាគ្រប់គ្រាន់ ដើម្បីចូលសវនាការ ឬអត់ ដោយយោងទៅលើរបាយការណ៍ និងសក្ខីកម្មរបស់អ្នកជំនាញដែលចាត់តាំងដោយអង្គជំនុំជម្រះ ។ លោក វីល្លៀម ស្មីត បានអះអាងជាថ្មីថា អៀង សារី មាន សតិបញ្ញាគ្រប់គ្រាន់ក្នុងការតាមដានសវនាការណែនាំមេធាវី របស់ខ្លួន និងអាចយកចិត្តទុកដាក់ក្នុងការដាមដានការផ្តល់សក្ខីកម្ម របស់សាក្សីបាន ។ លោកបានបន្ថែមថា របាយការណ៍ចុះថ្ងៃទី៣ ខែកញ្ញា ឆ្នាំ២០១២ ដែលធ្វើដោយសាស្ត្រាចារ្យ ខាំបែល វេជ្ជ បណ្ឌិត ស៊ីណា ហ្វាហ្សែល និងវេជ្ជបណ្ឌិត ហ្វូត លីនណា គឺបាន អនុលោមតាមយុត្តិសាស្ត្រ ក្នុងរឿងក្តី "ស្ត្រូហ្គា" ដែលបាន សម្រេចដោយតុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់អតីតប្រទេស យូហ្គោស្លាវី ពាក់ព័ន្ធនឹងការកំណត់សម្បទាក្នុងការការចូលរួម សវនាការ ។

ចុងក្រោយលោក វីល្លៀម ស្មីត ស្នើសុំអង្គជំនុំជម្រះចេញ សេចក្តីសម្រេចពាក់ព័ន្ធនឹងបញ្ហាសុខភាពរបស់ អៀង សារី ឲ្យបាន លឿនបំផុតតាមដែលអាចធ្វើបាន ហើយក្នុងអំឡុងពេលនៃការ ពិចារណាសុំឲ្យអង្គជំនុំជម្រះបន្តកិច្ចដំណើរការនីតិវិធីស្តាប់សក្ខីកម្ម របស់សាក្សី និងដើមបណ្តឹងរដ្ឋប្បវេណីជាធម្មតា ទោះបីជាជន ជាប់ចោទ អៀង សារី មានវត្តមាននៅទីណាក៏ដោយ ពោលគឺទោះ នៅបន្ទប់សវនាការ បន្ទប់រងចាំ ឬនៅមន្ទីរពេទ្យក៏ដោយ ។

### ៣.គ) សេចក្តីសន្និដ្ឋានរបស់មេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី

ដូចគ្នានឹងសេចក្តីសន្និដ្ឋានរបស់តំណាងសហព្រះរាជអាជ្ញា ដែរ លោកស្រីមេធាវី អេលីហ្សាបេត ស៊ីម៉ូណូហ្វត បានយោងទៅ លើរបាយការណ៍របស់សាស្ត្រាចារ្យ ខាំបែល ដែលថា អៀង សារី មានសម្បទាគ្រប់គ្រាន់ទាំងផ្លូវកាយ និងផ្លូវបញ្ញាស្មារតី ក្នុងការ ចូលរួមសវនាការ ។ ជាងនេះទៅទៀត សាស្ត្រាចារ្យ ខាំបែល បានបញ្ជាក់ថា ពុំមានលក្ខខណ្ឌណាដែលតម្រូវឲ្យ អៀង សារី ត្រូវបន្តព្យាបាលនៅមន្ទីរពេទ្យមិត្តភាពខ្មែរ-សូវៀត ទៀត ឡើយ ។ លោកស្រីមេធាវីបានយល់ស្របទាំងស្រុងចំពោះការ លើកឡើងរបស់លោក វីល្លៀម ស្មីត ដែលថា របាយការណ៍របស់ សាស្ត្រាចារ្យ ខាំបែល គឺមានលក្ខណៈពេញលេញ និងអាចទទួល យកបានដោយមិនចាំបាច់ចាត់តាំងអ្នកជំនាញបន្ថែមឡើយ ។

លោកស្រីមេធាវី បានលើកឡើងអំពីគុណវុឌ្ឍិរបស់សាស្ត្រាចារ្យ ខាំប៊ែល ដែលធ្លាប់ចេញរបាយការណ៍ពាក់ព័ន្ធនឹងសម្បទា របស់ជនជាប់ចោទ អៀង ធីរិទ្ធ ដោយបញ្ជាក់ថា *« លោក ខាំប៊ែល បានចេញរបាយការណ៍ពាក់ព័ន្ធ ទៅនឹងសុខភាពរបស់លោកស្រី អៀង ធីរិទ្ធ ហើយទាំងមេធាវីការពារក្តីរបស់លោកស្រី អៀង ធីរិទ្ធ ដែលជាភរិយារបស់លោក អៀង សារី នេះ គឺថាបានយល់ស្រប ថា ជាឯកសារអាចយកជាការបាន មានសំអាងហេតុត្រឹមត្រូវ ដើម្បីឲ្យអង្គជំនុំជម្រះចេញសេចក្តីសម្រេចពាក់ព័ន្ធនឹងអសម្បទារបស់លោកស្រី អៀង ធីរិទ្ធ...»* ។

ចុងក្រោយលោកស្រីមេធាវី អេលីហ្សាបេត ស៊ីម៉ូណូហុត ស្នើសុំឲ្យអង្គជំនុំជម្រះចេញសេចក្តីសម្រេចពាក់ព័ន្ធនឹងសម្បទារបស់ អៀង សារី ឲ្យបានឆាប់បំផុត ហើយសុំឲ្យអង្គជំនុំជម្រះសម្រេចបដិសេធចោលនូវសំណើរបស់ក្រុមមេធាវីការពារក្តីជនជាប់ចោទ អៀង សារី ។

### ៣.ឃ) សេចក្តីសន្និដ្ឋានតបរបស់ក្រុមមេធាវីការពារក្តី អៀង សារី

ដូចបានបញ្ជាក់រួចហើយថា ក្រុមមេធាវីការពារក្តីជនជាប់ចោទ អៀង សារី គឺត្រូវបានអនុញ្ញាតឲ្យធ្វើសេចក្តីសន្និដ្ឋានតបទៅនឹងសេចក្តីសន្និដ្ឋានរបស់តំណាងសហព្រះរាជអាជ្ញា និងក្រុមមេធាវីតំណាង ដើមបណ្តឹងរដ្ឋប្បវេណី ។ ឆ្លើយតបនឹងការលើកឡើងរបស់មេធាវីដើមបណ្តឹងរដ្ឋប្បវេណី ដែលថាមេធាវីការពារក្តីជនជាប់ចោទ អៀង ធីរិទ្ធ ធ្លាប់បានទទួលស្គាល់គុណវុឌ្ឍិរបស់សាស្ត្រាចារ្យ ខាំប៊ែល ដែលបានវាយតម្លៃអំពីសម្បទារបស់ជនជាប់ចោទ អៀង ធីរិទ្ធ មេធាវី កាណាវ៉ាស បានលើកឡើងថា រឿងក្តី របស់ជនជាប់ចោទ អៀង ធិរិទ្ធ និងកូនក្តីរបស់លោក គឺបែកដាច់ពីគ្នា ។ ដូច្នេះការទទួលគុណវុឌ្ឍិរបស់សាស្ត្រាចារ្យ ខាំប៊ែល ដោយក្រុមមេធាវីការពារក្តី អៀង ធិរិទ្ធ គឺជារឿងមួយផ្សេង ។ ចុងក្រោយលោក កាណាវ៉ាស ពោលថា *«...យើងមិនលើកឡើងពាក់ព័ន្ធនឹងលោកស្រី អៀង ធីរិទ្ធ នោះទេ គឺគាត់មិនមែនជាកូនក្តីរបស់យើងខ្ញុំ ហើយយើងមិនមែនធ្វើការច្របូកច្របល់គ្នា យកប៉ោមមកប្រៀបធៀបជាមួយ ក្រូចនោះទេ គឺយើងបានបែងចែកច្បាស់លាស់ណាស់រឿងក្តីនេះ...»* ។

ឆ្លើយតបនឹងសេចក្តីសន្និដ្ឋានរបស់លោក វីល្លៀម ស្មីត ដែលថា អៀង សារី មានសម្បទាគ្រប់គ្រាន់ដើម្បីចូលរួមសវនាការ មេធាវី កាណាវ៉ាស បានលើកឡើងថា នេះគឺគ្រាន់តែជាពាក្យដែលចេញពីមាត់របស់សាស្ត្រាចារ្យ ខាំប៊ែល តែប៉ុណ្ណោះ ។ មេធាវីបន្ថែមថា នៅពេលសាស្ត្រាចារ្យ ខាំប៊ែល កំពុងធ្វើ ការពិនិត្យវាយតម្លៃអំពីស្ថានភាពសុខភាពរបស់ អៀង សារី គឺក្រុមរបស់លោក ដែលជាមេធាវីការពារក្តី មិនត្រូវបានអនុញ្ញាតឲ្យចូលរួមឡើយ ។ ជាងនេះទៅទៀត ដំណើរការនៃការពិនិត្យ និងវាយតម្លៃនោះ គឺមិនត្រូវបានថតជាខ្សែអាត់សំឡេង ឬខ្សែវីដេអូ ដើម្បីឲ្យភាគីបានពិនិត្យមើលអំពីស្ថានភាពរបស់ អៀង សារី នៅពេលនោះដែរ ។ លោកមេធាវីអះអាងថា ដំណើរការជំនុំជម្រះក្តីលើជនជាប់ចោទ អៀង សារី ដែលមានវ័យ៨៨ឆ្នាំ ហើយមានជំងឺជាច្រើនមុខ គឺពិតប្រាកដណាស់ដែលជនជាប់ចោទរូបនេះនឹងមិនអាចចូលរួមសវនាការឲ្យបានពេញលេញ ដូចមនុស្សដែលមានសុខភាពរឹងពឹងធម្មតាឡើយ ។ ជាថ្មីម្តងទៀត មេធាវី កាណាវ៉ាស ស្នើសុំអង្គជំនុំជម្រះចាត់តាំងអ្នកជំនាញផ្សេងបន្ថែមទៀត ហើយប្រសិនបើអាចធ្វើបានការធ្វើកោសល្យវិច័យដោយអ្នកជំនាញថ្មីនេះ គឺត្រូវមានការថតខ្សែអាត់ ឬវីដេអូ ដើម្បីឲ្យលោកអាចពិនិត្យមើលដំណើរការនៃការធ្វើកោលសល្យវិច័យនេះ ។

### បញ្ហាផ្សេងៗ

មុនពេលភាគីចាប់ផ្តើមធ្វើសេចក្តីសន្និដ្ឋានបិទបញ្ចប់ មេធាវីហ្សាស្ពើ ប៉ៅ ដែលជាមេធាវីអន្តរជាតិរបស់ជនជាប់ចោទ នួន ជា បានព្យាយាមក្រោកឈរម្តងហើយម្តងទៀត ប៉ុន្តែមិនត្រូវបានប្រធានអង្គជំនុំជម្រះអនុញ្ញាឲ្យធ្វើសេចក្តីថ្លែងអ្វីឡើយ ដោយលោកប្រធានបញ្ជាក់ថា ភាគីដែលមិនពាក់ព័ន្ធនឹងការពិភាក្សាអំពីបញ្ហាសុខភាពរបស់ អៀង សារី គឺមិនមានសិទ្ធិធ្វើសេចក្តីថ្លែងអ្វីទាំងអស់ ។ ជាងនេះទៅទៀត មេធាវីអន្តរជាតិ អេនទ្រូ អ៊ីនូហ្វ៊ី បានរំខានដំណើរការនីតិវិធីរបស់តុលាការម្តងរួចហើយ ។ ដូច្នេះប្រសិនបើមានអ្វីចង់លើកឡើង គឺត្រូវរង់ចាំរហូតកិច្ចដំណើរការសន្និដ្ឋានបិទរបស់ភាគីត្រូវបានធ្វើចប់សព្វគ្រប់ជាមុនសិន ។ បន្ទាប់មក ប្រធានអង្គជំនុំជម្រះប្រគល់វេទិកាជូនក្រុមមេធាវីការពារក្តីជនជាប់ចោទ អៀង សារី ដើម្បីធ្វើសេចក្តីសន្និដ្ឋានបិទ ។

ចាប់ផ្តើមភ្លាម មេធាវី ម៉ៃឃើល កាណាវ៉ាស បាន លើកឡើងថា "...មេធាវីលោក នួន ជា មានបញ្ហាមួយចំនួនដែលចង់លើកឡើងក្នុងសវនាការនេះដើម្បី និយាយទាក់ទងទៅនឹងកូនក្តីរបស់គាត់ ដោយសារកូនក្តីរបស់គាត់មានបញ្ហាវិលមុខ ។ នេះគឺជាអ្វីដែល មេធាវីការពារក្តីលោក នួន ជា ចង់ជម្រាបទៅអង្គជំនុំជម្រះ" ។ ទោះបីជាយ៉ាងណាក៏ដោយ ប្រធានអង្គជំនុំជម្រះនៅតែប្រកាន់ជំហរដូចបានកំណត់នៅក្នុងសេចក្តីសម្រេចរបស់ខ្លួនលើកមុន ពោលគឺអនុញ្ញាតឲ្យមេធាវី ហ្សាស្ពើ ប៉ោ លើកឡើងនៅពេលសេចក្តីសន្និដ្ឋានបិទរបស់ភាគីត្រូវបានបញ្ចប់ ។ គួរបញ្ជាក់ថា បន្ទាប់ពីបញ្ចប់ការធ្វើសេចក្តីសន្និដ្ឋានរបស់ភាគី ប្រធានអង្គជំនុំជម្រះបានអនុញ្ញាតឲ្យក្រុមមេធាវីការពារក្តី នួន ជា លើកឡើងអំពីបញ្ហាផ្សេងៗ ដែលពាក់ព័ន្ធនឹងកូនក្តីរបស់ខ្លួន ។ ភ្លាមៗនោះ មេធាវី ហ្សាស្ពើ ប៉ោ បញ្ជាក់ថា កូនក្តីរបស់លោកមានបញ្ហាសុខភាព ហើយលោកមានបំណងស្នើសុំអង្គជំនុំជម្រះ ចាត់តាំងគ្រូពេទ្យឲ្យពិនិត្យកូនក្តីរបស់ខ្លួនជាបន្ទាន់ ដើម្បីវាយតម្លៃថា តើ នួន ជា អាចមានស្មារតីគ្រប់ គ្រាន់ក្នុងការតាមដានសវនាការស្តាប់សក្ខីកម្មរបស់សាក្សី ដែលនឹងត្រូវធ្វើបន្ទាប់ពីការពិភាក្សាបញ្ហាសុខ ភាពរបស់ អៀង សារី ត្រូវបានបញ្ចប់ ។ ចុងក្រោយ មេធាវី ហ្សាស្ពើ ប៉ោ បានសង្កត់ធ្ងន់ថា "...ប្រសិនបើខ្ញុំបាននិយាយពីមុន គឺខ្ញុំមានឱកាសនឹងស្នើសុំឲ្យវេជ្ជបណ្ឌិតធ្វើការតាំងពី ២ម៉ោងមុនមក ម្ល៉េះ..." ។

## ៤) សេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងស្តីពីបញ្ហាសម្បទារបស់ អៀង សារី

បន្ទាប់ពីមានសវនាការសួរដេញដោលសាស្ត្រាចារ្យ ចន ខាំប៊ែល អំពីសម្បទារបស់ អៀង សារី ដូចបានរៀបរាប់ខាងលើ នៅថ្ងៃទី២៦ ខែវិច្ឆិកា ឆ្នាំ២០១២ អង្គជំនុំជម្រះសាលាដំបូងបានចេញសេចក្តីសម្រេចថា ជនជាប់ចោទ អៀង សារី មានសម្បទាគ្រប់គ្រាន់ក្នុងការចូលរួមសវនាការ ដោយបញ្ជាក់ថា ជនជាប់ចោទមានលទ្ធភាពអាចចូលរួមយ៉ាងមានប្រសិទ្ធភាពក្នុងការការពារខ្លួន ។ អង្គជំនុំជម្រះ បានយោងលើរបាយការណ៍វេជ្ជសាស្ត្រដែលបានផ្តល់ជាបន្តបន្ទាប់ ដូចជា របាយការណ៍ចុះខែកញ្ញា ឆ្នាំ២០០៩, ខែមិថុនា ឆ្នាំ២០១១, ខែកញ្ញា ឆ្នាំ២០១២ និង របាយការណ៍ចុងក្រោយចុះថ្ងៃទី០៦ ខែវិច្ឆិកា ឆ្នាំ២០១២ ។ របាយការណ៍ទាំងនេះបានបង្ហាញថា សតិបញ្ញា ឬការចងចាំរបស់ជនជាប់ចោទ អៀង សារី គឺមិនមានការប្រែប្រួលឡើយបើប្រៀបធៀបទៅនឹងវ័យរបស់ជនជាប់ចោទរូបនេះ ។ អង្គជំនុំជម្រះបានបន្ថែមថា យោងតាមរបាយការណ៍ជនជាប់ចោទ អៀង សារី អាចផ្ចង់អារម្មណ៍ឆ្លើយសំណួររបស់វេជ្ជបណ្ឌិតបានរយៈពេលពី១ម៉ោង ទៅ១ម៉ោងកន្លះ ។ ដូច្នេះរយៈពេលនេះគឺសមស្របទៅនឹងរយៈពេលនៃកិច្ចដំណើរការសវនាការរបស់អង្គជំនុំជម្រះ ។

នៅក្នុងសេចក្តីសម្រេចនេះដែរ អង្គជំនុំជម្រះបានបដិសេធសំណើរបស់មេធាវីការពារក្តី ដែលសុំតែងតាំងអ្នកជំនាញម្នាក់បន្ថែមទៀត ដើម្បីវាយតម្លៃឡើងវិញទៅលើសម្បទារបស់ជនជាប់ចោទក្នុងការចូលរួមសវនាការ ។ អង្គជំនុំជម្រះបានផ្តល់សំអាងហេតុថា មេធាវីមិនបានជំទាស់ទៅនឹងរបាយការណ៍ថ្មីៗរបស់អ្នកជំនាញដែលត្រូវបានតែងតាំងដោយតុលាការ ហើយក៏ពុំបានផ្តល់មូលដ្ឋានណាមួយដែលអាចឲ្យអង្គជំនុំជម្រះសម្រេចបដិសេធដោយសមហេតុផលចំពោះរបាយការណ៍របស់អ្នកជំនាញទាំងនោះដែរ ។ ជាងនេះទៅទៀត មេធាវីការពារក្តីក៏ពុំបានផ្តល់សំអាងហេតុឲ្យបានសមរម្យ ដើម្បីឲ្យអង្គជំនុំជម្រះអាចយកមកធ្វើជាមូលដ្ឋានក្នុងការសម្រេចផ្លាស់ប្តូរអ្នកជំនាញដែរ ។ អង្គជំនុំជម្រះបដិសេធបន្ថែមលើសំណើរបស់មេធាវីការពារក្តីដែលសុំឲ្យថតអំពីស្ថានភាពជនជាប់ចោទ អៀង សារី និងសំណើសុំផ្តល់គ្រែពេទ្យសម្រាប់ជនជាប់ចោទចូលរួមសវនាការតាមរយៈប្រព័ន្ធសោទស្សន៍នៅបន្ទប់រង់ចាំ ។ ទោះបីជាយ៉ាងណាក៏ដោយ អង្គជំនុំជម្រះបានបង្គាប់អង្គភាពសុខាភិបាល និងមន្ទីរពេទ្យនៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ឲ្យអនុវត្តតាមអនុសាសន៍របស់សាស្ត្រាចារ្យ ខាំប៊ែល ដែលថា ជនជាប់ចោទគប្បីអនុញ្ញាតឲ្យចូលរួមសវនាការពីចម្ងាយតាមរយៈប្រព័ន្ធសោទស្សន៍នៅបន្ទប់រង់ចាំ ដោយដាក់ឲ្យទម្រេតខ្លួនដើម្បីងាយស្រួលក្នុងការដកដង្ហើម ។ ជាងនេះទៅទៀត ត្រូវមានអ្នកជួយគ្រានៅពេលជនជាប់ចោទចូលបន្ទប់ទឹក ហើយត្រូវមានកម្មវិធីធ្វើលំហាត់ប្រាណព្រមទាំងផ្តល់របបអាហារ និងសេវាថែទាំបន្ថែមទៀត ដើម្បីធ្វើឲ្យសុខភាពរបស់ អៀង សារី មានភាពល្អប្រសើរឡើងវិញ ។

# ការអនុវត្តសិទ្ធិនៅស្ងៀមមិនឆ្លើយតបសំណួរនៅអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

បាន ប្រាថ្នា

## *សេចក្តីផ្តើម*

*សិទ្ធិនៅស្ងៀមមិនឆ្លើយតប* (right to remain silent) *គឺជាសិទ្ធិមួយក្នុងចំណោមសិទ្ធិជាមូលដ្ឋាន សំខាន់ៗ ផ្សេងទៀតរបស់ជនជាប់ចោទ ដែលត្រូវបានធានាដើម្បីទទួលបានការជំនុំជម្រះក្តីដោយត្រឹមត្រូវ និងយុត្តិធម៌ ។ សិទ្ធិនេះត្រូវបានទទួលស្គាល់យ៉ាងទូលំទូលាយ នៅក្នុងមជ្ឈដ្ឋានច្បាប់ជាតិ និងអន្តរជាតិ ។ ហើយត្រូវបានអនុវត្តនៅតុលាការអន្តរជាតិមួយចំនួនដូចជា តុលាការព្រហ្មទណ្ឌអន្តរជាតិ* (ICC) *តុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវី* (ICTY) *តុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់ប្រទេសរវ៉ាន់ដា* (ICTR) *និងតុលាការពិសេសសម្រាប់ប្រទេសសេរ៉ាឡេអូន* (SCSL) *។*

*នៅពេលជនសង្ស័យ ឬជនជាប់ចោទសម្រេចជ្រើសរើសយកសិទ្ធិនៅស្ងៀមមិនឆ្លើយតបនោះខ្លួននឹងមិនអាចត្រូវបានបង្ខំឲ្យឆ្លើយតបសំណួររបស់ភាគីណាមួយឡើយ ។ ច្បាប់ស្តីពីការបង្កើតអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាបានបញ្ជាក់ថា ជនជាប់ចោទមិនអាចត្រូវបានបង្ខំឲ្យឆ្លើយប្រឆាំងនឹងខ្លួនឯង ឬបង្ខំឲ្យឆ្លើយសារភាពថាមានកំហុសឡើយ ។ បញ្ញត្តិនេះត្រូវបានអង្គជំនុំជម្រះសាលាដំបូងបកស្រាយថា ជនជាប់ចោទមិនអាចត្រូវបានបង្ខំឲ្យឆ្លើយសំណួរដែលត្រូវបានសួរមកលើខ្លួនឡើយ ។ ដូច្នេះ ជនជាប់ចោទមានសិទ្ធិក្នុងការនៅស្ងៀមមិនឆ្លើយតបនឹងសំណួររបស់ភាគី ។ លើសពីនេះទៀត វិធានផ្ទៃក្នុងរបស់អង្គជំនុំជម្រះវិសាមញ្ញបានតម្រូវថា ជនសង្ស័យ និងជនជាប់ចោទ ត្រូវទទួលបាននូវការជូនដំណឹងអំពីសិទ្ធិរបស់ខ្លួនក្នុងការនៅស្ងៀមមិនឆ្លើយតប នៅគ្រប់កិច្ចដំណើរការនីតិវិធីទាំងអស់ក្នុងរឿងក្តីព្រហ្មទណ្ឌ ។*

*អត្ថបទនេះនឹងបង្ហាញអំពីដំហររបស់ជនជាប់ចោទនីមួយៗ ក្នុងការអនុវត្តសិទ្ធិនៅស្ងៀមមិនឆ្លើយតបសំណួរនៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូងនៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ។ បន្ទាប់មកនឹងបង្ហាញអំពីមូលដ្ឋានច្បាប់ និងទម្រង់ ឬវិសាលភាពនៃការប្រើប្រាស់សិទ្ធិនៅស្ងៀមមិនឆ្លើយតប ហើយចុងក្រោយនឹងលើកឡើងអំពីគុណសម្បត្តិ និងគុណវិបត្តិសម្រាប់ជនជាប់ចោទដែលអនុវត្តសិទ្ធិ នេះ ។*




***និស្សិតកំពុងអានព័ត៌មានសង្ខេបរបស់មេដឹកនាំនៃរបបកម្ពុជាប្រជាធិបតេយ្យ***
***(ប្រភពរូបថតៈ មជ្ឈមណ្ឌលឯកសារកម្ពុជា)***

### ១) សិទ្ធិរបស់ជនជាប់ចោទក្នុងការអនុវត្តសិទ្ធិនៅស្ងៀមមិនឆ្លើយតប

ទោះបីជនជាប់ចោទ អៀង សារី, ខៀវ សំផន និង នួន ជា ស្ថិតនៅក្នុងសំណុំរឿង០០២ តែមួយ ប៉ុន្តែសិទ្ធិក្នុងការប្រើប្រាស់សិទ្ធិនៅស្ងៀមរបស់ជនជាប់ចោទនីមួយៗ គឺមានលក្ខណៈខុសៗគ្នា ។ ខាងក្រោមនេះ គឺជាសេចក្តីសង្ខេបអំពីសិទ្ធិរបស់ជនជាប់ចោទទាំងបីរូបដែលកំពុងប្រើប្រាស់សិទ្ធិនៅស្ងៀមមិនឆ្លើយតបនៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង ។

#### ១.ក) សិទ្ធិរបស់ជនជាប់ចោទ អៀង សារី

នៅថ្ងៃទី២៨ ខែតុលា ឆ្នាំ២០១១ (បន្ទាប់ពីតំណាងសហព្រះរាជអាជ្ញាស្នើសុំឲ្យមានការបញ្ជាក់អំពីចេតនារបស់ជនជាប់ចោទទាំងបីរូបពាក់ព័ន្ធនឹងការផ្តល់សក្ខីកម្ម) ជនជាប់ចោទ អៀង សារី បានជូនដំណឹងជាលាយលក្ខណ៍អក្សរទៅអង្គជំនុំជម្រះសាលាដំបូងថា ខ្លួននឹងមិនផ្តល់សក្ខីកម្មឡើយ ពោលគឺរក្សាសិទ្ធិនៅស្ងៀមមិនឆ្លើយសំណួរទាំងអស់របស់ភាគី ឬអង្គជំនុំជម្រះដែលមានបំណងសួរក្នុងអំឡុងពេលសវនាការទាំងមូល ។ បន្ថែមលើនេះ អៀង សារី បានធ្វើសេចក្តីថ្លែងការណ៍ដោយផ្ទាល់មាត់ម្តងទៀតក្នុង អំឡុងពេលសវនាការថ្ងៃទី១៣ ខែធ្នូ ឆ្នាំ២០១១ ដោយបានបញ្ជាក់ថា "...ខ្ញុំបាទសូមប្រើប្រាស់សិទ្ធិរបស់ខ្ញុំក្នុងរដ្ឋធម្មនុញ្ញ ដោយរក្សាសិទ្ធិនៅស្ងៀមមិនឆ្លើយនឹងសំណួរទាំងឡាយនាពេលនេះ ។ សិទ្ធិនេះមានចែងក្នុងមាត្រា៣១ និង៣៨នៃរដ្ឋធម្មនុញ្ញព្រះរាជាណាចក្រកម្ពុជា ។ ខ្ញុំបាទមានបំណងប្រើប្រាស់សិទ្ធិនេះនៅក្នុងការជំនុំជម្រះទាំងមូល ហើយមិនមានបំណងឆ្លើយតបនឹងសំណួរណាមួយឡើយ" ។

#### ១.ខ) សិទ្ធិរបស់ជនជាប់ចោទ ខៀវ សំផន

ចំពោះជនជាប់ចោទ ខៀវ សំផន បន្ទាប់ពីប្រធានអង្គជំនុំជម្រះបង្គាប់ឲ្យបង្ហាញសិទ្ធិរបស់ខ្លួនឲ្យបានច្បាស់ពាក់ព័ន្ធនឹងការប្រើសិទ្ធិនៅស្ងៀមមិនឆ្លើយតប ខៀវ សំផន បានលើកឡើងថា ខ្លួនមិនមានបំណងឆ្លើយតបនឹងសំណួរណាមួយឡើយពាក់ព័ន្ធនឹងអង្គហេតុស្តីពីប្រវត្តិបក្សកុម្មុយនិស្តកម្ពុជា ដរាបណាសហព្រះរាជអាជ្ញាមិនទាន់បង្ហាញភស្តុតាងពាក់ព័ន្ធនឹងអង្គហេតុនេះ ។ នៅក្នុងសវនាការថ្ងៃទី១២ ខែមករា ឆ្នាំ២០១២ ជនជាប់ចោទ ខៀវ សំផន បានបញ្ជាក់បន្ថែម (តាមរយៈមេធាវីរបស់ខ្លួន) ថា ខ្លួននឹងមិនឆ្លើយសំណួរទាំងអស់ដែលទាក់ទងនឹងអង្គហេតុស្តីពី "ប្រវត្តិសាវតាររបស់ជនជាប់ចោទ" ។ គួរបញ្ជាក់ ថា ជនជាប់ ចោទ ខៀវ សំផន មិនបានបង្ហាញសិទ្ធិរក្សាសិទ្ធិនៅស្ងៀមមិនឆ្លើយតបសំណួរនៅគ្រប់កិច្ចដំណើរការនីតិវិធីជំនុំជម្រះក្តីទាំងមូលដូចជាជនជាប់ចោទ អៀង សារី ឡើយ ។ ពោលគឺគ្រាន់តែបញ្ជាក់ថាខ្លួនមិនឆ្លើយតបចំពោះសំណួរពាក់ព័ន្ធអង្គហេតុស្តីពី "ប្រវត្តិបក្សកុម្មុយនិស្តកម្ពុជា" និង "ប្រវត្តិសាវតាររបស់ជនជាប់ម្នាក់ៗ" ដែលត្រូវយកមកជេញដោលនៅក្នុងសវនាការដំណាក់កាលទីមួយតែប៉ុណ្ណោះ ។

#### ១.គ) សិទ្ធិរបស់ជនជាប់ចោទ នួន ជា

ចំណែកឯជនជាប់ចោទ នួន ជា វិញ ក្នុងអំឡុងពេលនៃកិច្ចដំណើរការសវនាការដំណាក់កាលទីមួយ ខ្លួនមិនបានរក្សាសិទ្ធិនៅស្ងៀមមិនឆ្លើយតបសំណួរឡើយ ពោលគឺ នួន ជា បានឆ្លើយតបគ្រប់ភាគីទាំងអស់ដែលបានចោទសួរមកលើខ្លួន ។ ប៉ុន្តែមកដល់ពេលនេះ ជនជាប់ចោទ នួន ជា បានរក្សាសិទ្ធិនៅស្ងៀម មិនឆ្លើយតបសំណួរ បន្ទាប់ពីអង្គជំនុំជម្រះប្រកាសបញ្ចប់សវនាការដំណាក់កាលទី១ ហើយបន្តជេញដោលលើអង្គហេតុដែលត្រូវជំនុំជម្រះនៅក្នុងដំណាក់កាលទី២ពាក់ព័ន្ធនឹងរចនាសម្ព័ន្ធគ្រប់គ្រងរដ្ឋបាល ប្រព័ន្ធទំនាក់ទំនងការងារ និងតួនាទីជនជាប់ចោទម្នាក់ៗ នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ។ ជនជាប់ចោទ នួន ជា បញ្ជាក់ជូនអង្គជំនុំជម្រះថា ប្រសិនបើអង្គជំនុំជម្រះមិនធ្វើការពិភាក្សាបន្ថែមលើអង្គហេតុពាក់ព័ន្ធនឹងប្រវត្តិបក្សកុម្មុយនិស្តកម្ពុជា និងមិនដោះស្រាយនូវសំណើមួយចំនួនដែលខ្លួនបានស្នើសុំនោះ ខ្លួននឹងរក្សាសិទ្ធិនៅស្ងៀមមិនឆ្លើយតបរាល់សំណួរទាំងអស់ដែលនឹងត្រូវចោទសួរមកលើខ្លួន នៅក្នុងកិច្ចដំណើរការសវនាការដំណាក់កាលទី២នេះ ។

ជាក់ស្តែងរហូតមកដល់ពេលនេះ សំណុំរឿង០០២ដែលកំពុងដំណើរការ នៅអង្គជំនុំជម្រះសាលាដំបូងនៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា គឺមិនមានជនជាប់ចោទណាម្នាក់ឆ្លើយតបនឹងសំណួរដែលភាគីមានបំណងចោទសួរឡើយ ពោលគឺជនជាប់ចោទទាំងអស់បានប្រើប្រាស់សិទ្ធិនៅស្ងៀមមិនឆ្លើយតបសំណួរ ។

## ២) មូលដ្ឋានច្បាប់ និងការបកស្រាយស្តីពីសិទ្ធិនៅស្ងៀមមិនឆ្លើយតប

### ២.ក) មូលដ្ឋានច្បាប់ដែលត្រូវយកមកអនុវត្ត

មូលដ្ឋានច្បាប់ក្នុងការប្រើប្រាស់សិទ្ធិនៅស្ងៀមមិនឆ្លើយតប ត្រូវបានលើកឡើងនៅពេលដែលជនជាប់ចោទ អៀង សារី ជូនដំណឹងទៅអង្គជំនុំជម្រះសាលាដំបូងថា ខ្លួននឹងមិនផ្តល់សក្ខីកម្ម ឬឆ្លើយតបសំណួរណាមួយដែលត្រូវបានចោទសួរដោយភាគីក្នុងអំឡុងពេលកិច្ចដំណើរការសវនាការឡើយ ។ ក្រុមមេធាវីការពារក្តីជនជាប់ចោទ អៀង សារី បានលើកយកបទបញ្ញត្តិមួយចំនួនដែលអនុញ្ញាតឲ្យជនជាប់ចោទអាចប្រើប្រាស់សិទ្ធិនៅស្ងៀមមិនឆ្លើយតបសំណួរនៅចំពោះមុខអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ។ បទបញ្ញត្តិទាំងនោះរួមមាន ៖

ទី១) រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ត្រង់មាត្រា ៣១ ។ មាត្រានេះចែងថា *“ព្រះរាជា ណាចក្រកម្ពុជាទទួលស្គាល់ និងគោរពសិទ្ធិមនុស្សដូចមានចែងក្នុងធម្មនុញ្ញនៃអង្គការសហប្រជាជាតិ សេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្ស និងកតិកាសញ្ញា ព្រមទាំងអនុសញ្ញាទាំងឡាយទាក់ទងទៅនឹងសិទ្ធិមនុស្ស សិទ្ធិនារី និងសិទ្ធិកុមារ”* ។

ទី២) កិច្ចព្រមព្រៀងរវាងរាជរដ្ឋាភិបាលកម្ពុជា និងអង្គការសហប្រជាជាតិស្តីពីការបង្កើតអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ត្រង់មាត្រា១២(២) និងមាត្រា៣៣ថ្មី នៃច្បាប់ស្តីពីការបង្កើតអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ។ មាត្រាទាំងពីរនេះបានចែងស្រដៀងគ្នា ដោយតម្រូវឲ្យអង្គជំនុំជម្រះវិសាមញ្ញត្រូវអនុវត្តយុត្តាធិការរបស់ខ្លួនឲ្យស្របតាមបទដ្ឋានអន្តរជាតិដូចដែលមានចែងក្នុងមាត្រា១៤ និង១៥ នៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ ដើម្បីធានាឲ្យបានការកាត់ក្តីប្រកបដោយត្រឹមត្រូវ និងយុត្តិធម៌ ។

ទី៣) កតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ ត្រង់មាត្រា១៤(៣)(ឆ) និងមាត្រា៣៥(ឆ)ថ្មី នៃច្បាប់បង្កើតអង្គជំនុំជម្រះ ដែលមាត្រាទាំងពីរនេះចែងដូចគ្នាថា ជនជាប់ចោទមានសិទ្ធិ*“មិនត្រូវបានគេបង្ខំឲ្យឆ្លើយប្រឆាំងនឹងខ្លួនឯង ឬបង្ខំឲ្យឆ្លើយសារភាពថាមានកំហុស”* ។

ទី៤) វិធានផ្ទៃក្នុងរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ត្រង់វិធាន២១(១)(ឃ) ។ វិធាននេះចែងថា *“ជនណាដែលត្រូវបានសង្ស័យ ឬត្រូវបានចោទប្រកាន់ ត្រូវចាត់ទុកថាគ្មានទោស ដរាបណាពិរុទ្ធភាពរបស់គេមិនទាន់ត្រូវបានរកឃើញ ។ ជនទាំងនេះមានសិទ្ធិទទួលដំណឹងអំពីបទល្មើសដែលចោទប្រកាន់ចំពោះខ្លួន និងមានមេធាវីការពារតាមការជ្រើសរើសរបស់ខ្លួន ហើយនៅគ្រប់ដំណាក់កាលទាំងអស់នៃកិច្ចដំណើរការនីតិវិធីត្រូវបានផ្តល់ព័ត៌មានអំពីសិទ្ធិនៅស្ងៀមមិនឆ្លើយតប”* ។

យោងតាមមូលដ្ឋានច្បាប់ដូចបានរៀបរាប់នេះ ជនជាប់ចោទ អៀង សារី អះអាងថាខ្លួនមានសិទ្ធិពេញលេញក្នុងការមិនផ្តល់សក្ខីកម្ម ឬរក្សាភាពស្ងៀមស្ងាត់មិនឆ្លើយតបនឹងសំណួរនៅគ្រប់កិច្ចដំណើរការនីតិវិធីរបស់តុលាការ ។

មូលដ្ឋានច្បាប់ដែលបានលើកឡើងដោយ មេធាវីការពារក្តីជនជាប់ចោទ អៀង សារី ពាក់ព័ន្ធនឹងការប្រើប្រាស់សិទ្ធិនៅស្ងៀមមិនឆ្លើយតប គឺមិនត្រូវបានជំទាស់ដោយភាគីណាមួយឡើយ ។ ពោលគឺសិទ្ធិនេះត្រូវបានទទួលស្គាល់យ៉ាងពេញលេញពីសំណាក់សហព្រះរាជអាជ្ញាជាតិ និងអន្តរជាតិ និងអង្គជំនុំជម្រះសាលាដំបូងនៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ។

សហព្រះរាជអាជ្ញាបានបង្ហាញជំហរយ៉ាងច្បាស់ថា ជនជាប់ចោទមានសិទ្ធិនៅស្ងៀមមិនឆ្លើយតបសំណួរដោយអនុលោមតាមវិធាន២១(១)(ឃ) នៃវិធានផ្ទៃក្នុងរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ។ ច្បាស់ជាងនេះទៅទៀត សហព្រះរាជអាជ្ញាបញ្ជាក់ថា ខ្លួននឹងមិនជំទាស់ចំពោះការប្រើប្រាស់សិទ្ធិនៅស្ងៀមមិនឆ្លើយតបនឹងសំណួរឡើយ ។

ដូចគ្នានេះដែរ អង្គជំនុំជម្រះសាលាដំបូងនៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា មិនបានជំទាស់ ឬបដិសេធអំពីមូលដ្ឋានច្បាប់ដែលទាក់ទងនឹងសិទ្ធិនៅស្ងៀមមិនឆ្លើយតបរបស់ជនជាប់ចោទដែលត្រូវបានលើកឡើងដោយមេធាវីការពារក្តីឡើយ ។ បន្ថែមលើនេះ អង្គជំនុំជម្រះសាលាដំបូងបានទទួលស្គាល់ថា ជនជាប់ចោទមានសិទ្ធិនៅស្ងៀមមិនឆ្លើយតបសំណួរដោយយោងទៅមាត្រា៣៥(ឆ)ថ្មី នៃច្បាប់ស្តីពីការបង្កើតអង្គជំនុំជម្រះវិសាមញ្ញ ក្នុងតុលាការកម្ពុជា ។

### ២.៦) ទម្រង់ និងអានុភាពនៃការប្រើប្រាស់សិទ្ធិនៅស្ងៀមមិនឆ្លើយតបសំណួរ

បន្ថែមលើការយល់ដឹងអំពីមូលដ្ឋានច្បាប់ផ្សេងៗដែលត្រូវយកមកអនុវត្ត ការដឹងអំពីទម្រង់ និងអានុភាពនៃការប្រើប្រាស់សិទ្ធិនៅស្ងៀមមិនឆ្លើយតបសំណួរក៏ជាកត្តាសំខាន់ ដើម្បីធានាថាសិទ្ធិនេះត្រូវបានអនុវត្តពេញលេញដែរឬយ៉ាងណា ។

### ២.៦.១) ទម្រង់នៃការប្រើប្រាស់សិទ្ធិនៅស្ងៀមមិនឆ្លើយតបសំណួរ

ការបកស្រាយអំពីទម្រង់ ឬវិសាលភាពនៃការអនុវត្តសិទ្ធិនៅស្ងៀមមិនឆ្លើយតបសំណួរនៅអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា គឺកើតឡើងបន្ទាប់ពីលោកចៅក្រម ហ្សង់ម៉ាក ឡាវើញ ដាក់ឯកសារភស្តុតាងនៅចំពោះមុខភាគី ហើយលោកចៅក្រមបានព្យាយាមសួរជនជាប់ចោទ ខៀវ សំផន ដើម្បីឲ្យបញ្ជាក់អំពីភាពត្រឹមត្រូវនៃឯកសារទាំងនោះ ។ ក្នុងការដាក់ឯកសារទាំងនោះ លោកចៅក្រមបានអានខ្លឹមសារខ្លីៗ ហើយស្នើឲ្យជនជាប់ចោទ ខៀវ សំផន ធ្វើអត្ថាធិប្បាយ ធ្វើការកត់សម្គាល់ ផ្លាស់ប្តូរយោបល់ បញ្ចេញប្រតិកម្ម ធ្វើការបញ្ជាក់ ឬពន្យល់បន្ថែម... ទៅលើខ្លឹមសារដែលលោកបានអាន ។ ប្រភេទនៃសំណើទាំងនេះត្រូវបានលោក គង់ សំអុន ជាមេធាវីការពារក្តីជនជាប់ចោទ ខៀវ សំផន ធ្វើការជំទាស់យ៉ាងខ្លាំង ដោយលើកឡើងថា កូនក្តីរបស់ខ្លួនកំពុងប្រើប្រាស់សិទ្ធិនៅស្ងៀមមិនឆ្លើយតបនឹងសំណួរ ។ ការព្យាយាមចោទសំណួរម្តងហើយម្តងទៀត ឬស្នើឲ្យផ្តល់យោបល់ ឬធ្វើអត្ថាធិប្បាយទៅលើភស្តុតាង ឬបញ្ហាណាមួយ គឺធ្វើឲ្យប៉ះពាល់ដល់ជនជាប់ចោទក្នុងការអនុវត្តសិទ្ធិនៅស្ងៀមមិនឆ្លើយតប ។ លោកមេធាវីបានបន្ថែមថា “ការស្នើឲ្យលោក ខៀវ សំផន ផ្តល់យោបល់ ឬក៏ធ្វើអត្ថាធិប្បាយនេះ គឺគ្រាន់តែជាការផ្លាស់ប្តូររបៀបសួរប៉ុណ្ណោះ ការតាំងសំណួរហ្នឹងធ្វើគ្រាន់តែមិនឲ្យចេញជាសំណួរ គឺឲ្យទៅជាប្រយោគធម្មតា ដើម្បីឲ្យលោក ខៀវ សំផន ឆ្លើយតប ។ អ៊ីចឹងបានន័យថា សិទ្ធិក្នុងការមិនឆ្លើយហ្នឹង មិនត្រូវបានអនុវត្តទេនៅពេលនេះ គឺដូចគ្នាដដែល ។ បានន័យថា លោក ខៀវ សំផន ត្រូវតែឆ្លើយតប ។ អ៊ីចឹងការធ្វើដដែលៗបែបនេះវាបង្ហាញថា យើងកំពុងតែបង្ខំលោក ខៀវ សំផន ឆ្លើយតប” ។

ពាក់ព័ន្ធបញ្ហានេះដែរ ក្រុមមេធាវីការពារក្តីជនជាប់ចោទ អៀង សារី បានលើកឡើងថា “សំណើឲ្យធ្វើការបញ្ជាក់ផ្តល់យោបល់ ឬឆ្លើយតបទៅនឹងសំណួរ ឬឯកសារនានា គឺជាសំណើសុំឲ្យនិយាយ ពីព្រោះជនជាប់ចោទមិនអាចបញ្ជាក់ ផ្តល់យោបល់ ឬឆ្លើយតប ដោយមិននិយាយបានឡើយ ។ នៅពេលណាជនជាប់ចោទបានបញ្ជាក់យ៉ាងច្បាស់លាស់ក្នុងការប្រើសិទ្ធិនៅស្ងៀមមិនឆ្លើតបនោះ សំណើសុំឲ្យធ្វើការបញ្ជាក់ផ្តល់យោបល់ ឬឆ្លើយតបទៅនឹងសំណួរ ឬឯកសារ គឺជាការបំពានដល់សិទ្ធិជាសារវ័ន្តរបស់ជនជាប់ចោទដែលជាសិទ្ធិទទួលបានការការពារពីរដ្ឋធម្មនុញ្ញក្នុងការនៅស្ងៀមមិនឆ្លើយតប និងសិទ្ធិមិនដាក់ពិរុទ្ធភាពមកលើខ្លួនឯង” ។


មេធាវីការពារក្តី គង់ សំអុន (ប្រភព ៖ មជ្ឈមណ្ឌលឯកសារកម្ពុជា)

ទោះបីជាយ៉ាងណាក្តី ការបកស្រាយអំពីទម្រង់ ឬវិសាលភាពនៃការអនុវត្តសិទ្ធិនៅស្ងៀមមិនឆ្លើយតបសំណួរដោយក្រុមមេធាវីការពារក្តីជនជាប់ចោទ ខៀវ សំផន និង អៀង សារី គឺមិនត្រូវបានអង្គជំនុំជម្រះសាលាដំបូង ឬសហព្រះរាជអាជ្ញាធ្វើការជំទាស់ ឬបដិសេធឡើយ ។ ពោលគឺអង្គជំនុំជម្រះបានបង្ហាញជំហរយល់

ស្របតាមការបកស្រាយរបស់ក្រុមមេធាវីការពារក្តីជនជាប់ចោទ ។ ជាក់ស្តែងអង្គជំនុំជម្រះ បានសម្រេចទទួលយកសំណើរបស់ក្រុមមេធាវីការពារក្តីជនជាប់ចោទ ខៀវ សំផន ដោយសុំឲ្យចៅក្រម ហ្សង់ម៉ាក ឡាវែរីញ បញ្ឈប់ការសួរដេញដោលជនជាប់ចោទតាមរយៈការប្រើវិធីសាស្ត្រដូចបានរៀបរាប់ខាងលើនេះ ។

## ២.១.២) ប្រសិទ្ធភាពនៃការប្រើសិទ្ធិនៅស្ងៀមមិនឆ្លើយតប

សំណួរសួរថា នៅពេលជនជាប់ចោទប្រើប្រាស់សិទ្ធិនៅស្ងៀមមិនឆ្លើយតបសំណួរ តើអង្គជំនុំជម្រះទាញសេចក្តីសន្និដ្ឋានជាអវិជ្ជមានចំពោះជនជាប់ចោទដែរឬទេ?

### ២.១.២.១) អំណះអំណាងរបស់ក្រុមមេធាវីការពារក្តី

ក្រុមមេធាវីការពារក្តី អៀង សារី អះអាងថា “នៅពេលជនជាប់ចោទប្រើសិទ្ធិនៅស្ងៀមមិនឆ្លើយតប នោះគេមិនអាចទាញសេចក្តីសន្និដ្ឋានដោយអវិជ្ជមានពីការនៅស្ងៀមមិនឆ្លើយតបរបស់ជនជាប់ចោទឡើយ ។ សិទ្ធិរបស់ជនជាប់ចោទក្នុងការនៅស្ងៀមមិនឆ្លើយតប មិនអាចមានន័យពេញលេញឡើយនៅពេលការប្រើសិទ្ធិនេះនាំឲ្យមានការស្តីបន្ទោស ។ ការទាញសេចក្តីសន្និដ្ឋានជាអវិជ្ជមាននៅពេលជនជាប់ចោទប្រើប្រាស់សិទ្ធិនៅស្ងៀមមិនឆ្លើយតប គឺជាការបំពានដល់សច្ចធារណ៍នៃនិរទោស (ភាពគ្មានទោស) និងផ្ទេរបន្ទុកស្វែងរកភស្តុតាងពីការិយាល័យសហព្រះរាជអាជ្ញាទៅជាបន្ទុករបស់មេធាវីការពារក្តី” ។ ក្រុមមេធាវីការពារក្តីបន្ថែមទៀតថា រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជា វិធានផ្ទៃក្នុង កិច្ចព្រមព្រៀងនិងច្បាប់ស្តីពីការបង្កើតអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាមិនបាន ចែងពីលទ្ធភាពដែលអាចទាញសេចក្តីសន្និដ្ឋានជាអវិជ្ជមានចំពោះជនជាប់ចោទដែលប្រើសិទ្ធិនៅស្ងៀមមិនឆ្លើយសំណួរឡើយ ។ ផ្ទុយមកវិញ បញ្ហានេះបានកំណត់នៅក្នុងលក្ខន្តិកៈរបស់តុលាការព្រហ្មទណ្ឌអន្តរជាតិ ដែលបានកំណត់ថា ជនជាប់ចោទមានសិទ្ធិនៅស្ងៀមមិនឆ្លើយតបសំណួរ ហើយការនៅស្ងៀមស្ងាត់នេះមិនត្រូវយកមកពិចារណាក្នុងការកំណត់ថា ជនជាប់ចោទនោះមានពិរុទ្ធភាព ឬគ្មានពិរុទ្ធភាពឡើយ ។ មានការសម្រេចស្រដៀងគ្នារបស់តុលាការកំពូលនៃតុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវីក្នុងរឿងក្តី Celebici និង Delalic ដោយបានសម្រេចថា “...លក្ខន្តិកៈ និងវិធាន មានចែងពីការហាមឃាត់ដាច់ខាត ប្រឆាំងនឹងការចាត់ទុកការនៅស្ងៀមមិនឆ្លើយតប ជាកត្តាមួយក្នុងការកំណត់ពីពិរុទ្ធភាព ឬភាពគ្មានទោស” ។

គួររំពឹកថា សិទ្ធិនៅស្ងៀមមិនឆ្លើយតបសំណួរ ហើយដែលមិនអាចយកមកវិនិច្ឆ័យពីភាពមាន ឬគ្មានពិរុទ្ធភាពរបស់ជនជាប់ចោទ គឺជាសិទ្ធិមួយក្នុងចំណោមសិទ្ធិទាំង៩ ដែលជនជាប់ចោទត្រូវតែមាន (សិទ្ធិដែលត្រូវបានធានាក្នុងកម្រិតអប្បរិមា) ដើម្បីទទួលបានការជំនុំជម្រះក្តីប្រកបដោយយុត្តិធម៌នៅក្នុងតុលាការព្រហ្មទណ្ឌអន្តរជាតិ ។

### ២.១.២.២) សេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូង

ផ្ទុយពីការលើកឡើងរបស់ក្រុមមេធាវីការពារក្តីជនជាប់ចោទ អៀង សារី អង្គជំនុំជម្រះសាលាដំបូងអះអាងថា តាមយុត្តិសាស្ត្រអន្តរជាតិដែលពាក់ព័ន្ធបង្ហាញថា ការណ៍ដែលជនជាប់ចោទសម្រេចជ្រើសរើសដោយខ្លួនឯងក្នុងការនៅស្ងៀមមិនឆ្លើយតបសំណួរនោះអាចត្រូវបានប្រើក្នុងការទាញចេញ ជាសេចក្តីសន្និដ្ឋានផ្ទុយ ។ ការអះអាងនៅក្នុងសេចក្តីសម្រេចដោយផ្ទាល់មាត់នេះ អង្គជំនុំជម្រះមិនបានលើកយករឿងក្តីជាក់លាក់ ឬយុត្តិសាស្ត្ររបស់តុលាការអន្តរជាតិណាមួយមកបង្ហាញឡើយ ។

ទោះបីជាយ៉ាងណាក៏ដោយអង្គជំនុំជម្រះបញ្ជាក់ថា ក្នុងការវិនិច្ឆ័យអំពីកំហុសរបស់ជនជាប់ចោទ ខ្លួននឹងមិនផ្អែកទាំងស្រុងលើការទាញសេចក្តីសន្និដ្ឋានផ្ទុយចេញពីការរក្សាសិទ្ធិនៅស្ងៀមមិនឆ្លើយតបសំណួរឡើយ ។ ពោលគឺអង្គជំនុំជម្រះនឹងពិចារណាលើភស្តុតាងទាំងអស់ដែលបានដាក់ចំពោះមុខខ្លួន រួមទាំងសក្ខីកម្មនិងរបៀបដែលជនជាប់ចោទផ្តល់សក្ខីកម្ម ។ តាមអត្ថន័យនៃសេចក្តីសម្រេចនេះបញ្ជាក់ឲ្យឃើញថា នៅពេលដែលជនសង្ស័យឬជនជាប់ចោទរក្សាសិទ្ធិនៅស្ងៀមមិនឆ្លើយតបសំណួរនោះអង្គជំនុំជម្រះនៅតែអាចមានលទ្ធភាពទាញសេចក្តីសន្និដ្ឋានជាអវិជ្ជមានក្នុងកម្រិតណាមួយ ដើម្បីវិនិច្ឆ័យអំពីកំហុសរបស់ជនសង្ស័យឬជនជាប់ចោទបាន ។ ជាក់ស្តែងអង្គជំនុំជម្រះបញ្ជាក់ថា “...នៅពេលដែលជន ជាប់ចោទសម្រេចជ្រើសរើសដោយខ្លួនឯងនូវសិទ្ធិនៅស្ងៀមមិនឆ្លើយតបនឹងការផ្តល់សក្ខីកម្មនោះអង្គជំនុំជម្រះអាចនឹងកត់សម្គាល់អំពីបញ្ហានេះនៅពេលវាយតម្លៃអំពីភាពគួរឲ្យជឿ

ដាក់បានរបស់គាត់» ។

### ៣) គុណសម្បត្តិ និងគុណវិបត្តិនៃការប្រើប្រាស់សិទ្ធិនៅស្ងៀមមិនឆ្លើយតប

មានសំណួរជាច្រើនត្រូវបានចោទសួរឡើងជុំវិញការប្រើប្រាស់សិទ្ធិនៅស្ងៀមមិនឆ្លើយតបសំណួររបស់ជនជាប់ចោទក្នុងសំណុំរឿង០០២ នៅអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ។ សំណួរមួយចំនួនក្នុងចំណោមសំណួរទាំងនោះរួមមាន ៖ តើមានផលប្រយោជន៍ និងផលវិបាកអ្វីខ្លះនៅពេលជនសង្ស័យ ឬជនជាប់ចោទសម្រេចប្រើប្រាស់សិទ្ធិនៅស្ងៀមមិនឆ្លើយតបសំណួរ? តើកិច្ចដំណើរការនីតិវិធីរបស់តុលាការនឹងប្រព្រឹត្តទៅដោយរបៀបណា? តើជនជាប់ចោទអាចការពារខ្លួនដោយរបៀបណា?

បញ្ហាទាំងនេះត្រូវបានស្រាយបំភ្លឺតាមរយៈការអនុវត្តជាក់ស្តែងនៅក្នុងកិច្ចដំណើរការជំនុំជម្រះក្តីលើសំណុំរឿង០០២នេះ ។ មានផលប្រយោជន៍ជាច្រើនសម្រាប់ជនជាប់ចោទ ដែលកើតចេញពីការសម្រេចចិត្តប្រើប្រាស់សិទ្ធិនៅស្ងៀមមិនឆ្លើយតបសំណួរ ។ ទី១)រហូតមកដល់ពេលនេះ គ្មានជនជាប់ចោទណាម្នាក់ ត្រូវបានភាគី ឬអង្គជំនុំជម្រះបង្ខំឲ្យសារភាពកំហុស ឬឆ្លើយតបសំណួរណាមួយដែលដាក់បន្ទុកលើខ្លួនឯងឡើយ ។ ក្រុមមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីបានស្នើឲ្យជនជាប់ចោទផ្តល់សក្ខីកម្មអំពីអង្គហេតុដែលបានកើតនៅក្នុងរបបខ្មែរក្រហម ដើម្បីឲ្យប្រជាជនកម្ពុជា និងសាធារណៈយល់ដឹងអំពីមូលហេតុនៃអំពើឧក្រិដ្ឋកម្មដែលបានកើតនៅក្នុងរបបនេះ ។ ប៉ុន្តែសំណើទាំងនេះមិនត្រូវបានពិចារណាឡើយ បន្ទាប់ពីមេធាវីការពារក្តីជនជាប់ចោទបង្ហាញជំហរថា កូនក្តីរបស់ខ្លួនកំពុងប្រើប្រាស់សិទ្ធិនៅស្ងៀមមិនឆ្លើយតបសំណួរ ។ ទី២) ពង្រឹងនូវតួនាទីរបស់សហព្រះរាជអាជ្ញាក្នុងការអនុវត្តកាតព្វកិច្ចបង្ហាញភស្តុតាងដើម្បីបញ្ជាក់អំពីពិរុទ្ធភាពរបស់ជនជាប់ចោទ ។ ទី៣) ពង្រឹងតួនាទីរបស់ការិយាល័យសហចៅក្រមស៊ើបអង្កេត ដែលមានភារកិច្ចចាត់វិធានការស៊ើបសួរ ដើម្បីឈានទៅរកការបង្ហាញការពិតនៃរឿងក្តី ។ ទី៤) ជនជាប់ចោទនៅតែអាចស្នើសុំធ្វើអត្ថាធិប្បាយទៅលើឯកសារភស្តុតាងណាមួយ ដែលត្រូវបានដាក់ចំពោះមុខខ្លួន ។ ជាក់ស្តែង អង្គជំនុំជម្រះសាលាដំបូងនៅតែទុកលទ្ធភាពឲ្យជនជាប់ចោទធ្វើអត្ថាធិប្បាយលើភស្តុតាងណាមួយ ដែលយល់ថាមានប្រយោជន៍សម្រាប់ខ្លួន ទោះបីខ្លួនកំពុងតែប្រើប្រាស់សិទ្ធិនៅស្ងៀមមិនឆ្លើយតបក៏ដោយ ។ ទោះបីជនជាប់ចោទរក្សាសិទ្ធិនៅស្ងៀមមិនឆ្លើយតបសំណួរ ប៉ុន្តែជនជាប់ចោទនៅតែមានសិទ្ធិណែនាំមេធាវីរបស់ខ្លួននៅគ្រប់កិច្ចដំណើរការនីតិវិធីទាំងអស់ ។ មានន័យថា ក្នុងករណីមានភស្តុតាងណាមួយ ឬសក្ខីកម្មរបស់សាក្សីណាម្នាក់ដាក់បន្ទុកមកលើខ្លួន នោះជនជាប់ចោទមានសិទ្ធិណែនាំមេធាវីរបស់ខ្លួន ដើម្បីធ្វើការជំទាស់ ឬបដិសេធចោល ។ ជាក់ស្តែង គឺការអនុវត្តរបស់ជនជាប់ចោទ អៀង សារី ។ ទោះបី ជនជាប់ចោទរូបនេះរក្សាសិទ្ធិនៅស្ងៀមមិនឆ្លើយតបសំណួរទាំងអស់ ប៉ុន្តែក្នុងកិច្ចដំណើរការសវនាការ ជនជាប់ចោទនៅតែធ្វើការណែនាំមេធាវីរបស់ខ្លួនជាប្រចាំ ដើម្បីតទល់ទៅនឹងសាក្សីណាដែលនឹងផ្តល់សក្ខីកម្មដាក់ទាក់ទងនឹងក្រសួងការបរទេស ដែលអាចដាក់បន្ទុកមកលើខ្លួន ។

ប៉ុន្តែទន្ទឹមគ្នានេះដែរ ក៏អាចមានផលអវិជ្ជមានមួយចំនួនសម្រាប់ជនសង្ស័យ ឬជនជាប់ចោទ ដែលប្រើប្រាស់សិទ្ធិនៅស្ងៀមមិនឆ្លើយតបសំណួរនេះ ។ ពោលគឺពាក់ព័ន្ធនឹងតម្លៃ ឬទម្ងន់នៃភស្តុតាង ដែលជនសង្ស័យ ឬជនជាប់ចោទនោះបានផ្តល់ ។ ត្រង់ចំណុចនេះ សហព្រះរាជអាជ្ញាធ្លាប់បានដាក់សំណើសុំទៅអង្គជំនុំជម្រះសាលាដំបូងឲ្យជូនដំណឹងទៅជនជាប់ចោទ ខៀវ សំផន ថា ក្នុងករណីជនជាប់ចោទ ប្រើប្រាស់សិទ្ធិនៅស្ងៀមមិនឆ្លើយតបសំណួរនោះចម្លើយទាំងឡាយណាដែលជនជាប់ចោទរូបនេះបានផ្តល់នៅចំពោះមុខអង្គជំនុំជម្រះ នឹងមិនទំនងផ្តល់តម្លៃជាភស្តុតាងសំខាន់ៗឡើយ ។ ប៉ុន្តែរហូតមកដល់ពេលនេះ បញ្ហាតម្លៃ ឬទម្ងន់នៃភស្តុតាងដែលផ្តល់ដោយជនជាប់ចោទដែលប្រើប្រាស់សិទ្ធិនៅស្ងៀមមិនឆ្លើយតប នៅមិនទាន់មានភាពច្បាស់លាស់នៅឡើយ ព្រោះអង្គជំនុំជម្រះមិនបានចេញសេចក្តីសម្រេចជាក់លាក់ណាមួយអំពីបញ្ហានេះឡើយ ។ ជាងនេះទៅទៀត វិធានផ្ទៃក្នុងរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ក៏មិនបានចែងអំពីបញ្ហានេះដែរ ។

**ពិនិត្យ និងផ្ទៀងផ្ទាត់ដោយ វ៉ាន់ថាន់ ពៅដារ៉ា**

## ពន្យល់ពាក្យសំខាន់ៗ

សមត្ថភាពខាងកាយសម្បទា និងបញ្ញាស្មារតីរបស់ជនជាប់ចោទក្នុងការចូលរួមការជំនុំជម្រះ ៖ គឺជាគោលការណ៍ទូទៅមួយដែលជនជាប់ចោទណាម្នាក់អាចត្រូវយកមកជំនុំជម្រះបានលុះត្រាតែជនជាប់ចោទរូបនោះមានសមត្ថភាពខាងកាយសម្បទា និង បញ្ញាស្មារតីគ្រប់គ្រាន់ ។ គោលការណ៍នេះរួមមាន សមត្ថភាពក្នុងការយល់ដឹងអំពីបទចោទប្រកាន់មកលើខ្លួន, ការយល់ដឹងអំពីមូលហេតុនិងបច្ច័យនៃដំណើរការនីតិវិធី, ការយល់ដឹងអំពីភ័ស្តុតាង, និងសមត្ថភាពក្នុងការបង្គាប់មេធាវីរបស់ខ្លួន និងក្នុងការផ្តល់សក្ខីកម្ម ។


# មជ្ឈមណ្ឌលឯកសារកម្ពុជា

ប្រអប់សំបុត្រលេខ១១១០, ភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា

ទូរស័ព្ទ ៖ (៨៥៥) ២៣ ២១១ ៨៧៥

ទូរសារ ៖ (៨៥៥) ២៣ ២១០ ៣៥៨

អ៊ីម៉ែល ៖ *dccam@online.com.kh*

គេហទំព័រ ៖ *www.dccam.org* ឬ *www.cambodiatribunal.org*



គម្រោងនេះទទួលជំនួយហិរញ្ញវត្ថុពីមូលនិធិ

*John D. and Catherine T. MacArthur Foundation and British Embassy-Cambodia* ។


| ល.រ | ឈ្មោះដើម | ឈ្មោះបដិវត្ត | លេខសម្ងាត់ | ប្រភពឯកសារ |
|---|---|---|---|---|
| ១ | សាឡុត ស | ប៉ុល ពត, បងប៉ុល, បងទី១, | ៨៧០, ៨៧ | D427, E1/56.1 |
| ២ | នួន ជា | នួន ជា, បងនួន, បងទី២ | (អត់ដឹង) | D427 |
| ៣ | គីម ត្រាង | អៀង សារី, វ៉ាន់ | (អត់ដឹង) | D427, E1/21.1 |
| ៤ | ខៀវ សំផន | ហែម, ខាង, ណន | (អត់ដឹង) | D427 |
| ៥ | សុន សេន | ខៀវ, ឃឹម | ៨៩, ៦២ | E1/54.1 |



**ឆាយ ឈុនលី**

បរិញ្ញាបត្រច្បាប់ពីសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ។



**លីម ជ័យច័ត្ត**

បរិញ្ញាបត្រច្បាប់ និងបរិញ្ញាបត្រសេដ្ឋកិច្ច ពីសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច និងជាជ័យលាភីថ្នាក់ជាតិក្នុងការប្រកួតសវនាការប្រឌិតឆ្នាំ២០១០ ។



**ឌី សុជាតា**

បរិញ្ញាបត្រច្បាប់ សិក្សាជាភាសាអង់គ្លេស ពីសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ។



**ចាន់ ប្រាថ្នា**

បរិញ្ញាបត្រច្បាប់ពីសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ។

**សង្កេតការណ៍ ១**
ដំណើរកាត់ទោសមេដឹកនាំខ្មែរក្រហម




**សង្កេតការណ៍ ២**
ដំណើរកាត់ទោសមេដឹកនាំខ្មែរក្រហម




**សង្កេតការណ៍ ៣**
ដំណើរកាត់ទោសមេដឹកនាំខ្មែរក្រហម




**សង្កេតការណ៍ ៤**
ដំណើរកាត់ទោសមេដឹកនាំខ្មែរក្រហម




**សង្កេតការណ៍ ៥**
ដំណើរកាត់ទោសមេដឹកនាំខ្មែរក្រហម




**សង្កេតការណ៍ ៦**
ដំណើរកាត់ទោសមេដឹកនាំខ្មែរក្រហម




**សង្កេតការណ៍ ៧**
ដំណើរកាត់ទោសមេដឹកនាំខ្មែរក្រហម




**សង្កេតការណ៍ ៨**
ដំណើរកាត់ទោសមេដឹកនាំខ្មែរក្រហម



**សង្កេតការណ៍ ៩**
ដំណើរកាត់ទោសមេដឹកនាំខ្មែរក្រហម



**សង្កេតការណ៍ ១០**
ដំណើរកាត់ទោសមេដឹកនាំខ្មែរក្រហម




**សង្កេតការណ៍ ១១**
ដំណើរកាត់ទោសមេដឹកនាំខ្មែរក្រហម




**សង្កេតការណ៍ ១២**
ដំណើរកាត់ទោសមេដឹកនាំខ្មែរក្រហម




**សង្កេតការណ៍ ១៣**
ដំណើរកាត់ទោសមេដឹកនាំខ្មែរក្រហម




**សង្កេតការណ៍ ១៤**
ដំណើរកាត់ទោសមេដឹកនាំខ្មែរក្រហម




**សង្កេតការណ៍ ១៥**
ដំណើរកាត់ទោសមេដឹកនាំខ្មែរក្រហម



**សង្កេតការណ៍ ១៦**
ដំណើរកាត់ទោសមេដឹកនាំខ្មែរក្រហម



មជ្ឈមណ្ឌលឯកសារកម្ពុជា រក្សាសិទ្ធិខែវិច្ឆិកា ឆ្នាំ២០១២